# អនុសញ្ញាទីក្រុងប៊ែន

# ស្តីពីកិច្ចការពារស្នាដៃអក្សរសាស្ត្រនិងសិល្បៈ

### ច្បាប់ទីក្រុងប៉ារីស ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ១៩៧១

### ត្រូវបានធ្វើវិសោធនកម្មនៅថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ១៩៧៩

# អនុសញ្ញាទីក្រុងប៊ែន
# ស្ដីពីកិច្ចការពារស្នាដៃអក្សរសាស្ត្រនិងសិល្បៈ

ច្បាប់ទីក្រុងប៉ារីស
ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ១៩៧១
ត្រូវធ្វើវិសោធនកម្ម
នៅថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ១៩៧៩

# អនុសញ្ញាទីក្រុងប៊ែន

# ស្ដីពីកិច្ចការពារស្នាដៃអក្សរសាស្ត្រនិងសិល្បៈ

ចុះថ្ងៃទី៩ ខែកញ្ញា ឆ្នាំ១៨៨៦
បានបញ្ចប់នៅទីក្រុងប៉ារីស ចុះថ្ងៃទី៤ ខែឧសភា ឆ្នាំ១៨៩៦
ត្រូវបានកែប្រែនៅទីក្រុងបែរឡាំង ចុះថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ១៩០៨
បានបញ្ចប់នៅទីក្រុងប៊ែន ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ១៩១៤
ត្រូវបានកែប្រែនៅទីក្រុងរ៉ូម ចុះថ្ងៃទី២ ខែមិថុនា ឆ្នាំ១៩២៨
នៅទីក្រុងព្រុចសែល ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ១៩៤៨
នៅទីក្រុងស្តុកខុល ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ១៩៦៧
នៅទីក្រុងប៉ារីស ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ១៩៧១
និងត្រូវបានធ្វើវិសោធនកម្ម ចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ១៩៧៩

# មាតិកា


មាត្រា១ ការបង្កើតសហភាព*

មាត្រា២ ស្នាដៃដែលទទួលបានកិច្ចការពារៈ ១-"ស្នាដៃអក្សរសាស្ត្រនិងសិល្បៈ ២-ការតម្រូវឱ្យមានជាទម្រង់ណាមួយ ៣-ស្នាដៃបន្ត ៤-អត្ថបទផ្លូវការ ៥-ការចងក្រង ៦-កាតព្វកិច្ចការពារអ្នកទទួលផលប្រយោជន៍ពីកិច្ចការពារ ៧-ស្នាដៃសិល្បៈអនុវត្ត និងគំនូរឧស្សាហកម្ម ៨-ព័ត៌មាន

មាត្រា២(ស្ទួន) លទ្ធភាពនៃការកម្រិតកិច្ចការពារចំពោះស្នាដៃមួយចំនួនៈ ១-សង្កថាមួយចំនួន ២-ការប្រើប្រាស់បាឋកថានិងសុន្ទរកថាមួយចំនួន ៣-សិទ្ធិចងក្រងស្នាដៃទាំងនេះ

មាត្រា៣ លក្ខខណ្ឌដើម្បីទទួលបានកិច្ចការពារៈ ១-សញ្ជាតិរបស់អ្នកនិពន្ធ ទីកន្លែងនៃការបោះពុម្ពផ្សាយស្នាដៃ ២-លំនៅស្ថានរបស់អ្នកនិពន្ធ ៣-ស្នាដៃដែលបានបោះពុម្ពផ្សាយ ៤-ស្នាដៃដែលបោះពុម្ពផ្សាយស្របពេលជាមួយគ្នា

មាត្រា៤ លក្ខខណ្ឌដើម្បីទទួលបានកិច្ចការពារស្នាដៃភាពយន្ត ស្នាដៃស្ថាបត្យកម្ម និងស្នាដៃសិល្បៈមួយចំនួន

មាត្រា៥ សិទ្ធិដែលបានធានា : ១-និង២-នៅក្រៅប្រទេសដើម ៣-នៅក្នុងប្រទេសដើម ៤-"ប្រទេសដើម"

មាត្រា៦ លទ្ធភាពនៃការកម្រិតចំពោះកិច្ចការពារស្នាដៃមួយចំនួនរបស់ពលរដ្ឋនៃប្រទេសក្រៅសហភាពៈ ១-នៅក្នុងប្រទេសនៃការបោះពុម្ពផ្សាយលើកដំបូង និងនៅប្រទេសផ្សេងទៀត ២-អប្រតិសកម្ម ៣-ការជូនដំណឹង

មាត្រា៦(ស្ទួន) សិទ្ធិសីលធម៌ៈ ១-ដើម្បីទាមទារឋានៈជាអ្នកនិពន្ធដើម្បីជំទាស់នូវការកែប្រែមួយចំនួននិងសកម្មភាពប្រមាថ ២-ក្រោយពេលអ្នកនិពន្ធទទួលមរណភាព ៣-មធ្យោបាយជួសជុលការខូចខាត

មាត្រា៧ រយៈពេលនៃកិច្ចការពារៈ ១-លក្ខណៈទូទៅ ២-ស្នាដៃភាពយន្ត ៣-ស្នាដៃអនាមិកនិងស្នាដៃរហស្សនាម ៤-ស្នាដៃថតរូប និងស្នាដៃសិល្បៈអនុវត្ត ៥-ការចាប់ផ្តើមនៃការរាប់រយៈពេល ៦-រយៈពេលវែង ៧-រយៈពេលខ្លី ៨-ច្បាប់ដែលត្រូវអនុវត្ត "ការប្រៀបធៀប" រយៈពេល

មាត្រា៧(ស្ទួន) រយៈពេលនៃកិច្ចការពារចំពោះស្នាដៃសហការ

មាត្រា៨ សិទ្ធិបកប្រែ

មាត្រា៩ សិទ្ធិផលិតឡើងវិញៈ ១-លក្ខណៈទូទៅ ២-អញ្ញត្រកម្មដែលអាចមាន ៣-ការថតបញ្ចូលជាសំឡេងនិងជារូបភាព


* មាតិកានេះត្រូវបានបន្ថែមដើម្បីជំនួយដល់អ្នកអានប៉ុណ្ណោះ។ នៅក្នុងអត្ថបទដើម(ជាភាសាអង់គ្លេស)នៃអនុសញ្ញានេះពុំមានមាតិកានេះទេ។

មាត្រា ១០ លទ្ធភាពនៃការប្រើប្រាស់ស្នាដៃដោយសេរីមួយចំនួនទៀត: ១-អាគតដ្ឋាន ២-ការបញ្ជាក់ឱ្យបានច្បាស់នៅក្នុងការបង្រៀន ៣-ការបញ្ជាក់ពីប្រភពនិងឈ្មោះអ្នកនិពន្ធ

មាត្រា១០(ស្ទួន) ការប្រើប្រាស់ស្នាដៃដោយសេរីមួយចំនួនទៀតៈ ១-អត្ថបទសារព័ត៌មានមួយចំនួននិងស្នាដៃទូរផ្សាយមួយចំនួន ២-ស្នាដៃដែលអាចមើលឃើញឬស្តាប់ឮដែលទាក់ទងនឹងព្រឹត្តិការណ៍បច្ចុប្បន្នភាព

មាត្រា១១ សិទ្ធិមួយចំនួននៃស្នាដៃនាដកម្មនិងតូរ្យតន្ត្រីៈ ១-សិទ្ធិសម្តែងជាសាធារណៈនិងសិទ្ធិផ្សព្វផ្សាយជាសាធារណៈនូវការសម្តែង ២-ចំពោះការបកប្រែ

មាត្រា១១(ស្ទួន) សិទ្ធិផ្សាយតាមទូរផ្សាយនិងសិទ្ធិប្រហាក់ប្រហែល : ១- ការផ្សាយតាមទូរផ្សាយនិងការផ្សព្វផ្សាយដោយឥតខ្សែ ការផ្សព្វផ្សាយជាសាធារណៈតាមទូរផ្សាយមានខ្សែ ឬការផ្សាយឡើងវិញការ ផ្សាយជាសាធារណៈតាមទូរផ្សាយដោយឧបករណ៍បំពងសំឡេង ឬដោយឧបករណ៍ផ្សេងទៀតដែលមានលក្ខណៈដូចគ្នា ២-អាជ្ញាបណ្ណបញ្ជា ៣-ការថតបញ្ចូល ការថតបញ្ចូលបណ្តោះអាសន្ន

មាត្រា១១(ស្ទួន)៣ សិទ្ធិមួយចំនួននៃស្នាដៃអក្សរសាស្ត្រៈ ១-សិទ្ធិសូត្រជាសាធារណៈ និងសិទ្ធិផ្សព្វផ្សាយជាសាធារណៈនៃការសូត្រ ២-ចំពោះការបកប្រែ

មាត្រា១២ សិទ្ធិយកលំនាំតាម សិទ្ធិសម្រួល និងសិទ្ធិកែប្រែផ្សេងទៀត

មាត្រា១៣ លទ្ធភាពនៃការកម្រិតសិទ្ធិថតបញ្ចូលស្នាដៃតូរ្យតន្ត្រី និងទំនុកច្រៀងដែលមានក្នុងស្នាដៃនេះ ១-អាជ្ញាបណ្ណបញ្ជា ២-វិធានការបណ្តោះអាសន្ន ៣-ការរឹបអូសនូវការនាំចូលច្បាប់ចម្លងដែលធ្វើឡើងដោយគ្មានការអនុញ្ញាតពីអ្នកនិពន្ធ

មាត្រា១៤ សិទ្ធិថតបញ្ចូលជាភាពយន្ត និងសិទ្ធិប្រហាក់ប្រហែល ១-ការយកលំនាំតាមភាពយន្តនិងការផលិតឡើងវិញ ការចែកចាយ ការសម្តែងជាសាធារណៈ ការផ្សព្វផ្សាយជាសាធារណៈតាមខ្សែនៃស្នាដៃដែលយកលំនាំតាម ឬដែលបានផលិតឡើងវិញ ២-ការយកលំនាំតាមការផលិត ភាពយន្ត ៣-គ្មានអាជ្ញាបណ្ណបញ្ជា

មាត្រា១៤(ស្ទួន) បទប្បញ្ញត្តិពិសេសទាក់ទងនឹងស្នាដៃភាពយន្តៈ ១-ការប្រដូចនឹងស្នាដៃដើម ២-ភាពជាម្ចាស់សិទ្ធិ ការកម្រិតសិទ្ធិរបស់អ្នកចូលរួមមួយចំនួន ៣-អ្នកចូលរួមផ្សេងទៀត

មាត្រា១៤(ស្ទួន)៣ សិទ្ធិបន្តចំពោះស្នាដៃសិល្បៈ និងអត្ថបទសរសេរដោយដៃ ១-សិទ្ធិទទួលបានប្រយោជន៍ចំពោះ ការលក់ឡើងវិញ ២-ច្បាប់ដែលត្រូវអនុវត្ត ៣-នីតិវិធី

មាត្រា១៥ សិទ្ធិក្នុងការអនុវត្តសិទ្ធិដែលបានការពារៈ ១-នៅពេលដែលឈ្មោះរបស់អ្នកនិពន្ធត្រូវបានបញ្ជាក់ ឬនៅពេលដែលរហស្សនាមបានបង្ហាញដោយគ្មានការសង្ស័យចំពោះអត្តសញ្ញាណរបស់អ្នកនិពន្ធ ២-ករណីស្នាដៃភាពយន្ត ៣-ករណីស្នាដៃអនាមិកនិងរហស្សនាម ៤-ករណីស្នាដៃមួយចំនួនដែលបានបោះពុម្ពផ្សាយដោយមិនស្គាល់ឈ្មោះអ្នកនិពន្ធ

មាត្រា១៦ ការថតចម្លងដោយការរំលោភបំពានៈ ១-ការរឹបអូស ២-ការរឹបអូសចំពោះការនាំចូល ៣-ច្បាប់ដែលត្រូវអនុវត្ត

មាត្រា១៧ លទ្ធភាពក្នុងការត្រួតពិនិត្យចរាចរណ៍ ការបង្ហាញនិងការតាំងពិព័រណ៍ស្នាដៃ

មាត្រា១៨ ស្នាដៃពេលដែលអនុសញ្ញាចូលជាធរមានៈ ១-អាចការពារបាននៅពេលដែលកិច្ចការពារមិនទាន់ផុតអាជ្ញាយុកាលក្នុងប្រទេសដើម ២-មិនអាចការពារបាននៅពេលដែលកិច្ចការពារបានផុតអាជ្ញាយុកាលនៅក្នុងប្រទេសដែលអះអាងឱ្យការពារ ៣-ការអនុវត្តគោលការណ៍ទាំងនេះ ៤-ករណីពិសេស

មាត្រា១៩ កិច្ចការពារប្រសើរជាងកិច្ចការពារដែលមានចែងនៅក្នុងអនុសញ្ញា

មាត្រា២០ កិច្ចព្រមព្រៀងពិសេស រវាងបណ្ដាប្រទេសនៃសហភាព

មាត្រា២១ បទប្បញ្ញត្តិពិសេសទាក់ទងនឹងប្រទេសកំពុងអភិវឌ្ឍន៍៖ ១-ការយោងទៅលើច្បាប់បន្ថែម ២-ផ្នែកបន្ថែមនៃច្បាប់

មាត្រា២២ សន្និបាតៈ ១-ការបង្កើតនិងសមាសភាព ២-មុខងារ ៣-កូរ៉ុម ការបោះឆ្នោត អ្នកសង្កេតការណ៍ ៤-ការកោះប្រជុំ ៥-បទបញ្ជាផ្ទៃក្នុង

មាត្រា២៣ គណៈកម្មាធិការប្រតិបត្តិៈ ១-ការបង្កើត ២-សមាសភាព ៣-ចំនួនសមាជិក ៤-ការបែងចែកតាមភូមិសាស្ត្រកិច្ចព្រមព្រៀងពិសេស ៥-អាណត្តិការកម្រិតការឈរឈ្មោះឱ្យគេបោះឆ្នោតសាជាថ្មីវិធាននៃការបោះឆ្នោត ៦-មុខងារ ៧-ការកោះប្រជុំ ៨-កូរ៉ុម ការបោះឆ្នោត ៩-អ្នកសង្កេតការណ៍ ១០-បទបញ្ជាផ្ទៃក្នុង

មាត្រា២៤ ការិយាល័យអន្តរជាតិៈ ១-មុខងារទូទៅ អគ្គនាយក ២-ព័ត៌មានទូទៅ ៣-ទស្សនាវដ្ដី ៤-ការផ្ដល់ព័ត៌មានទៅប្រទេសទាំងឡាយ ៥-ការសិក្សានិងសេវាកម្ម ៦-ការចូលរួមប្រជុំ ៧-សន្និសីទស្ដីពីការកែប្រែ ៨-មុខងារផ្សេងៗ

មាត្រា២៥ ហិរញ្ញវត្ថុៈ ១-ថវិកា ២-ការសម្របសម្រួលជាមួយសហភាពផ្សេងទៀត ៣-ធនធាន ៤-ការបង់វិភាគទាន លទ្ធភាពបន្តថវិកាចាស់ ៥-ពន្ធអាករនិងប្រាក់កម្រៃ ៦-មូលនិធិទុនបង្វិល ៧-បុរេប្រទានដោយរដ្ឋាភិបាលម្ចាស់ផ្ទះ ៨-សវនកម្មបញ្ជីគណនី

មាត្រា២៦ វិសោធនកម្មៈ ១-បទប្បញ្ញត្តិដែលអាចធ្វើវិសោធនកម្មដោយសន្និបាត ការស្នើសុំ ២-ការអនុម័ត ៣-ការចូលជាធរមាន

មាត្រា២៧ ការកែប្រែ ១-គោលបំណង ២-សន្និសីទ ៣-ការអនុម័ត

| | |
|---|---|
| មាត្រា២៨ | ការទទួលយក និងការចូលជាធរមាននៃច្បាប់សម្រាប់ប្រទេសនៃសហភាព៖ ១-ការផ្តល់សច្ចាប័ន ការចូលជាសមាជិក លទ្ធភាពនៃការមិនអនុវត្តបទប្បញ្ញត្តិមួយចំនួន ការដកការមិនអនុវត្ត ២-ការចូលជាធរមាន នៃមាត្រា១ដល់មាត្រា២១ និងច្បាប់បន្ថែម ៣-ការចូលជាធរមាន នៃមាត្រា២២ដល់មាត្រា៣៨ |
| មាត្រា២៩ | ការទទួលយកនិងការចូលជាធរមានសម្រាប់ប្រទេសនៅក្រៅសហភាព: ១-ការចូលជាសមាជិក ២-ការចូលជាធរមាន |
| មាត្រា២៩(ស្ទួន) | អានុភាពនៃការទទួលយកច្បាប់ក្នុងគោលបំណងនៃមាត្រា១៤(២) នៃអនុសញ្ញាអង្គការកម្មសិទ្ធិបញ្ញាពិភពលោក |
| មាត្រា៣០ | ឧក្សេសិទ្ធិ: ១-ការកម្រិតលទ្ធភាពនៃការដាក់ឧក្សេសិទ្ធិ ២-ឧក្សេសិទ្ធិលើកមុន ឧក្សេសិទ្ធិចំពោះសិទ្ធិបកប្រែ ការដកឧក្សេសិទ្ធិ |
| មាត្រា៣១ | ការអនុវត្តនៅលើដែនដីមួយចំនួន: ១-សេចក្តីប្រកាស ២-ការដកសេចក្តីប្រកាស ៣-កាលបរិច្ឆេទអានុភាព ៤-ការទទួលស្គាល់ស្ថានភាពអង្គហេតុដែលមិនបានចែង |
| មាត្រា៣២ | ការអនុវត្តច្បាប់នេះនិងច្បាប់ដែលមានពីមុន: ១-រវាងប្រទេសដែលក្លាយជាសមាជិកនៃសហភាពរួចហើយ ២-រវាងប្រទេសដែលនឹងក្លាយជាសមាជិកនៃសហភាព និងប្រទេសផ្សេងទៀតដែលជាសមាជិកនៃសហភាព ៣-ការអនុវត្តច្បាប់បន្ថែមនៅក្នុងទំនាក់ទំនងមួយចំនួន |
| មាត្រា៣៣ | វិវាទ: ១-យុត្តាធិការនៃតុលាការយុត្តិធម៌អន្តរជាតិ ២-ឧក្សេសិទ្ធិចំពោះយុត្តាធិការនេះ ៣-ការដកឧក្សេសិទ្ធិ |
| មាត្រា៣៤ | ការបញ្ចប់បទប្បញ្ញត្តិដែលមានពីមុនមួយចំនួន: ១-ច្បាប់ដែលមានពីមុន ២-ពិធីសារនៃច្បាប់ទីក្រុងស្តុកខុល |
| មាត្រា៣៥ | រយៈពេលនៃការប្រកាសដកខ្លួនចេញពីអនុសញ្ញា: ១-រយៈពេលមិនកំណត់ ២-លទ្ធភាពនៃការប្រកាសដកខ្លួនចេញ ៣-កាលបរិច្ឆេទអានុភាពនៃការប្រកាសដកខ្លួនចេញ ៤-ការផ្អាកការប្រកាសដកខ្លួនចេញ |
| មាត្រា៣៦ | ការអនុវត្តអនុសញ្ញា: ១-កាតព្វកិច្ចអនុម័តវិធានការចាំបាច់ ២-កាលបរិច្ឆេទបង្កើតកាតព្វកិច្ច |
| មាត្រា៣៧ | អវសានប្បញ្ញត្តិ: ១-ភាសានៃច្បាប់ ២-ហត្ថលេខា ៣-ច្បាប់ចម្លងបញ្ជាក់ ៤-ការចុះបញ្ជី ៥-ការជូនដំណឹង |
| មាត្រា៣៨ | អន្តរប្បញ្ញត្តិ: ១-ការអនុវត្តនូវ "បុព្វសិទ្ធិប្រាំឆ្នាំ" ២-ការិយាល័យរបស់សហភាពប្រធានការិយាល័យ ៣-ការទទួលតំណែងបន្តពីការិយាល័យរបស់សហភាព |

# ច្បាប់បន្ថែម

# បទប្បញ្ញត្តិពិសេសស្តីពីប្រទេសកំពុងអភិវឌ្ឍ

មាត្រា១ លទ្ធភាពដែលផ្តល់ឱ្យប្រទេសកំពុងអភិវឌ្ឍៈ ១-អត្ថិភាពនៃលទ្ធភាពមួយចំនួនសេចក្តីប្រកាស ២-រយៈពេលសុពលភាពនៃសេចក្តីប្រកាស ៣-ការបាត់បង់ឋានៈជាប្រទេសកំពុងអភិវឌ្ឍ ៤-ច្បាប់ចម្លងស្នាដៃដែលមានក្នុងស្តុក ៥-សេចក្តីប្រកាសទាក់ទងនិងដែនដីមួយចំនួន ៦-ការកម្រិតនៃបដិការ

មាត្រា២ ការកម្រិតសិទ្ធិបកប្រែៈ ១-អាជ្ញាបណ្ណដែលអាចផ្តល់ឲ្យដោយអាជ្ញាធរមានសមត្ថកិច្ច ២-ដល់៤-លក្ខខណ្ឌក្នុងការផ្តល់អាជ្ញាបណ្ណ ៥-គោលបំណងក្នុងការផ្តល់អាជ្ញាបណ្ណ ៦-ការបញ្ចប់អាជ្ញាបណ្ណ ៧-ស្នាដៃដែលមានភាគច្រើនជារូបភាពពន្យល់ ៨-ស្នាដៃដែលដកចេញពីការធ្វើចរាចរណ៍ ៩-អាជ្ញាបណ្ណសម្រាប់អង្គភាពទូរផ្សាយ

មាត្រា៣ ការកម្រិតសិទ្ធិផលិតឡើងវិញៈ ១-អាជ្ញាបណ្ណដែលអាចផ្តល់ឱ្យដោយអាជ្ញាធរមានសមត្ថកិច្ច ២ដល់៥-លក្ខខណ្ឌក្នុងការផ្តល់អាជ្ញាបណ្ណ ៦-ការបញ្ចប់អាជ្ញាបណ្ណ ៧-ស្នាដៃដែលអនុវត្តក្នុងមាត្រានេះ

មាត្រា៤ បទបញ្ញត្តិរួមស្តីពីអាជ្ញាបណ្ណតាមមាត្រា២និងមាត្រា៣: ១និង២- នីតិវិធី ៣-ការបញ្ជាក់ពីឈ្មោះអ្នកនិពន្ធនិងចំណងជើងនៃស្នាដៃ ៤-ការនាំចេញច្បាប់ចម្លង ៥-ការជូនដំណឹង៦-ប្រាក់សំណង

មាត្រា៥ លទ្ធភាពដទៃទៀតក្នុងការកម្រិតសិទ្ធបកប្រែ៖ ១-របបគតិយុត្តចែងដោយច្បាប់ឆ្នាំ១៨៨៦ និងច្បាប់ឆ្នាំ១៨៩៦ ២-ភាពមិនអាចផ្លាស់ប្តូរបាននៃរបបគតិយុត្តតាមមាត្រា២ ៣-រយៈពេលក្នុងការជ្រើសរើសលទ្ធភាពផ្សេងទៀត

មាត្រា៦ លទ្ធភាពអនុវត្តឬយល់ព្រមអនុវត្តបទប្បញ្ញត្តិមួយចំនួននៃច្បាប់បន្ថែម មុននឹងជាប់កាតព្វកិច្ចដោយច្បាប់នេះ: ១-សេចក្តីប្រកាស ២-កន្លែងតម្កល់និងកាលបរិច្ឆេទអានុភាពនៃសេចក្តីប្រកាសប្រទេសទាំងឡាយនៃសហភាពដែលមានបំណងដូចគ្នា ដើម្បីការពារឱ្យកាន់តែមានប្រសិទ្ធិភាពនិងមានឯកសណ្ឋានភាពនូវសិទ្ធិអ្នកនិពន្ធចំពោះស្នាដៃអក្សរសាស្ត្រ និងសិល្បៈ។ ទទួលស្គាល់នូវសារៈសំខាន់នៃការងាររបស់សន្និសីទ នៅសន្និសីទទីក្រុងស្តុកខុល ឆ្នាំ១៩៦៧។ បានសម្រេចធ្វើការកែប្រែច្បាប់ដែលបានអនុម័តនៅសន្និសីទទីក្រុងស្តុកខុល ដោយរក្សាទុកមិនធ្វើការផ្លាស់ប្តូរ មាត្រា១ ដល់មាត្រា២០ និងមាត្រា២២ ដល់មាត្រា២៦ នៃច្បាប់នេះ។ អាស្រ័យហេតុនេះ ឯកអគ្គរដ្ឋទូតពេញសមត្ថភាព ដែលបានចុះហត្ថលេខាខាងក្រោមនិងបានបង្ហាញនូវលិខិតប្រទានសិទ្ធិដែលត្រូវបានទទួលស្គាល់ថាត្រឹមត្រូវតាមទម្រង់ និងច្បាប់បានយល់ព្រមគ្នាតាមបទប្បញ្ញត្តិដូចខាងក្រោម៖

## មាត្រា១

## ការបង្កើតសហភាព[1]

ប្រទេសទាំងឡាយដែលអនុវត្តអនុសញ្ញានេះ ត្រូវបង្កើតសហភាពមួយ ដើម្បីការពារសិទ្ធិអ្នកនិពន្ធស្នាដៃអក្សរសាស្ត្រនិងសិល្បៈ។

## មាត្រា២

**ស្នាដៃដែលទទួលបានកិច្ចការពារ : ១- "ស្នាដៃអក្សរសាស្ត្រនិងសិល្បៈ" ២- ការតម្រូវឱ្យមានជាទម្រង់ណាមួយ ៣- ស្នាដៃបន្ត ៤- អត្ថបទផ្លូវការ ៥- ការចងក្រង ៦- កាតព្វកិច្ចការពារ អ្នកទទួលផលប្រយោជន៍ពីកិច្ចការពារ ៧- ស្នាដៃសិល្បៈអនុវត្តនិងគំនូរឧស្សាហកម្ម ៨- ព័ត៌មាន**

(១) ពាក្យថា "ស្នាដៃអក្សរសាស្ត្រនិងសិល្បៈ" រួមបញ្ចូលគ្រប់ផលិតផលនៃកម្មសិទ្ធិ អក្សរសាស្ត្រ វិទ្យាសាស្ត្រ និងសិល្បៈ ដែលទោះបីជាការសម្តែងស្នាដៃ មានរបៀបឬទម្រង់បែបណាក៏ដោយ ដូចជាសៀវភៅ កូនសៀវភៅផ្សព្វផ្សាយព័ត៌មាននិងការនិពន្ធផ្សេងទៀត; អត្ថបទបាឋកថា សុន្ទរកថា ធម្មទេសនា និងស្នាដៃផ្សេងទៀតដែលមានប្រភេទដូចគ្នា; ស្នាដៃនាដកម្ម ឬនាដកតន្ត្រី ស្នាដៃរបាំ និងការកម្សាន្តតាមរយៈការសម្តែងកាយវិការ; ការតែងបទភ្លេងដោយមានឬគ្មានទំនុកច្រៀង; ស្នាដៃភាពយន្តដែលបង្ហាញតាមរយៈដំណើរការបញ្ចូលនូវស្នាដៃស្រដៀងគ្នាជាច្រើនបង្កើតបានជាស្នាដៃតែមួយ; ស្នាដៃជាផ្ទាំងគំនូរ គំនូរផាត់ពណ៌ ស្ថាបត្យកម្ម រូបចម្លាក់ផ្ទាំងចម្លាក់ ស្នាដៃថ្មពុម្ពចម្លាក់; ស្នាដៃថតរូបដែលបង្ហាញតាមរយៈដំណើរការបញ្ចូលនូវស្នាដៃស្រដៀងគ្នាជាច្រើនបង្កើតបានជាស្នាដៃតែមួយ; ស្នាដៃសិល្បៈ អនុវត្ត; រូបភាពពន្យល់ ផែនទី ប្លង់ គំនូសវាស និងស្នាដៃទម្រង់បីវិមាត(3D) ទាក់ទងនឹងភូមិសាស្ត្រ ឋានលេខា សាស្ត្រ ស្ថាបត្យកម្ម ឬវិទ្យាសាស្ត្រ។

(២) ប៉ុន្តែវាស្ថិតនៅលើច្បាប់របស់ប្រទេសនៃសហភាពក្នុងការចែងថា ស្នាដៃជាទូទៅ ឬប្រភេទស្នាដៃជាក់លាក់ណាមួយ មិនត្រូវបានការពារឡើយ កាលបើស្នាដៃទាំងនោះមិនត្រូវបានភ្ជាប់ក្នុងទម្រង់សម្ភារៈរូបសាស្ត្រណាមួយ។

(៣) ការបកប្រែ ការយកលំនាំតាម ការសម្រួលតន្ត្រី និងការកែប្រែផ្សេងទៀតនៃស្នាដៃអក្សរសាស្ត្រ ឬសិល្បៈ ត្រូវបានការពារដូចស្នាដៃដើម ដោយមិនប៉ះពាល់ដល់សិទ្ធិអ្នកនិពន្ធស្នាដៃដើម។

(៤) វាស្ថិតនៅលើច្បាប់របស់ប្រទេសនៃសហភាពក្នុងការកំណត់ឲ្យមានកិច្ចការពារទៅលើអត្ថបទផ្លូវការផ្នែកនីតិប្បញ្ញត្តិ ផ្នែករដ្ឋបាល និង ផ្នែកតុលាការ ហើយនិងការបកប្រែជាផ្លូវការនៃអត្ថបទទាំងនេះ។

(៥) ការចងក្រងស្នាដៃអក្សរសាស្ត្រឬសិល្បៈ ដូចជាឯកសារសព្វវចនាធិប្បាយ និងកម្រងស្នាដៃដោយមូលហេតុនៃការជ្រើសរើសនិងរៀបចំជាមាតិកាដែលជាការបង្កើតផ្នែកបញ្ញា ត្រូវបានការពារដូចនេះដោយមិនប៉ះពាល់ដល់សិទ្ធិអ្នកនិពន្ធស្នាដៃនីមួយៗដែលចូលរួមជាផ្នែកៗនៃការចងក្រងនេះឡើយ។

(៦) ស្នាដៃដែលមានចែងនៅក្នុងមាត្រានេះ ត្រូវទទួលបានកិច្ចការពារពីប្រទេសទាំងអស់នៃសហភាព។ កិច្ចការពារនេះ ត្រូវធ្វើឡើងជាប្រយោជន៍របស់អ្នកនិពន្ធនិងអ្នកទទួលសិទ្ធិ។

(៧) ផ្អែកទៅលើបទប្បញ្ញត្តិនៃមាត្រា៧(៤)នៃអនុសញ្ញានេះ វាស្ថិតនៅលើច្បាប់របស់ប្រទេសនៃសហភាព ក្នុងការកំណត់ដែនអនុវត្តនៃច្បាប់ ចំពោះស្នាដៃសិល្បៈអនុវត្ត គំនូរឧស្សាហកម្ម និងម៉ូដែលក៏ដូចជាលក្ខខណ្ឌនានា នៅក្រោមស្នាដៃសិល្បៈអនុវត្ត គំនូរឧស្សាហកម្ម និងម៉ូដែលទាំងនេះ ត្រូវបានការពារ។ ស្នាដៃដែលបាន ការពារក្នុងប្រទេសដើម ដោយគ្រាន់តែជាគំនូរនិងម៉ូដែលត្រូវបានផ្តល់សិទ្ធិទទួលឱ្យប្រទេសមួយផ្សេងទៀតនៃសហភាព ប្រសិនបើកិច្ចការពារពិសេសត្រូវបានផ្តល់ឱ្យនៅក្នុងប្រទេសនោះចំពោះគំនូរនិងម៉ូដែល ប៉ុន្តែបើគ្មានកិច្ចការពិសេសក្នុងប្រទេសនោះទេ ស្នាដៃទាំងនេះត្រូវបានការពារជាស្នាដៃសិល្បៈ។

(៨) កិច្ចការពារក្នុងអនុសញ្ញានេះ មិនអនុវត្តចំពោះព័ត៌មានប្រចាំថ្ងៃឬព្រឹត្តិការណ៍ផ្សេងៗដែលមានលក្ខណៈត្រឹមតែជាសារព័ត៌មាននោះទេ។

## មាត្រា២(ស្ទួន)

**លទ្ធភាពនៃការកម្រិតកិច្ចការពារចំពោះស្នាដៃមួយចំនួន : ១- សង្កថាមួយចំនួន ២- ការប្រើប្រាស់បាឋកថា និងសុន្ទរ- កថាមួយចំនួន ៣- សិទ្ធិចងក្រងស្នាដៃទាំងនេះ**

(១) វាស្ថិតនៅលើច្បាប់របស់ប្រទេសនៃសហភាព ក្នុងការបដិសេធដោយផ្នែកខ្លះៗឬទាំងស្រុងនៃកិច្ចការពារដែលផ្តល់ឱ្យតាមមាត្រាខាងលើចំពោះសង្កថានយោបាយនិងសង្កថាដែលធ្វើឡើងក្នុងនីតិវិធីតុលាការ។

(២) វាស្ថិតនៅលើច្បាប់របស់ប្រទេសនៃសហភាព ក្នុងការកំណត់ពីលក្ខខណ្ឌដែលនៅក្រោមអត្ថបទ បាឋកថា សុន្ទរកថា និងស្នាដៃលក្ខណៈដូចដទៃទៀតដែលបានធ្វើជាសាធារណៈអាចត្រូវបានផលិតឡើងវិញតាមរយៈសារព័ត៌មាន ទូរផ្សាយ ឬត្រូវបាន ផ្សព្វផ្សាយជាសាធារណៈតាមខ្សែនិងត្រូវជាកម្មវត្ថុនៃការផ្សព្វផ្សាយជាសាធារណៈតាមមាត្រា១១ស្ទួន(១) នៃអនុសញ្ញានេះ នៅពេលដែលការប្រើប្រាស់ធ្វើឡើងក្នុងគោលដៅព័ត៌មាន។

(៣) ទោះជាយ៉ាងនេះក្តី អ្នកនិពន្ធនៅតែទទួលបានសិទ្ធិផ្តាច់មុខក្នុងការចងក្រងស្នាដៃរបស់ខ្លួនតាមកថាខណ្ឌខាងលើ។

## មាត្រា៣

**លក្ខខណ្ឌដើម្បីទទួលបានកិច្ចការពារ : ១- សញ្ជាតិរបស់អ្នកនិពន្ធ ទីកន្លែងនៃការបោះពុម្ពផ្សាយស្នាដៃ ២- លំនៅឋានរបស់អ្នកនិពន្ធ ៣- ស្នាដៃដែលបោះពុម្ពផ្សាយ ៤- ស្នាដៃដែលបោះពុម្ពផ្សាយស្របពេលជាមួយគ្នា**

(១) កិច្ចការពារក្នុងអនុសញ្ញានេះអនុវត្តចំពោះ

(ក) អ្នកនិពន្ធដែលជាពលរដ្ឋរបស់ប្រទេសណាមួយនៃសហភាព ទោះជាស្នាដៃរបស់ខ្លួនបានបោះពុម្ពផ្សាយឬមិនបានបោះពុម្ពផ្សាយក៏ដោយ

(ខ) អ្នកនិពន្ធដែលមិនមែនជាពលរដ្ឋរបស់ប្រទេសណាមួយនៃសហភាពដែលស្នាដៃរបស់ខ្លួនបានបោះពុម្ពផ្សាយលើកដំបូងក្នុងប្រទេសណាមួយនៃសហភាព ឬបានបោះពុម្ពស្របពេលជាមួយគ្នានៅក្នុងប្រទេសមួយក្រៅសហភាព និងនៅក្នុងប្រទេសមួយនៃសហភាព។

(២) អ្នកនិពន្ធដែលមិនមែនជាពលរដ្ឋរបស់ប្រទេសណាមួយនៃសហភាព ប៉ុន្តែមាននិវេសនដ្ឋានអចិន្ត្រៃយ៍នៅក្នុងប្រទេសណាមួយនៃសហភាព ក្នុងគោលបំណងនៃអនុសញ្ញានេះ ត្រូវចាត់ទុកជាពលរដ្ឋនៃប្រទេសនោះ។

(៣) ពាក្យថា "ស្នាដៃដែលបានបោះពុម្ពផ្សាយ" មានន័យថា ជាស្នាដៃដែលបានបោះពុម្ពផ្សាយដោយមានការយល់ព្រមពីអ្នកនិពន្ធ ទោះបីបើការផលិតអត្ថបទនោះធ្វើឡើងតាមមធ្យោបាយណាក៏ដោយ ឱ្យតែការដាក់ឱ្យមានអត្ថបទទាំងនេះបានបំពេញសេចក្តីត្រូវការសមហេតុផលរបស់សាធារណជន ដោយមានពិចារណាទៅលើប្រភេទនៃស្នាដៃនោះ។ ការសម្តែងស្នាដៃនាដកម្ម នាដកម្មតូរ្យតន្ត្រី ស្នាដៃភាពយន្តឬស្នាដៃតូរ្យតន្ត្រី ការសូត្រស្នាដៃអក្សរសាស្ត្រជាសាធារណៈ ការផ្សាយតាមខ្សែឬតាមទូរផ្សាយស្នាដៃអក្សរសាស្ត្រនិងសិល្បៈ ការតាំងពិព័រណ៌ស្នាដៃសិល្បៈ និងការបង្កើតស្នាដៃស្ថាបត្យកម្ម មិនចាត់ទុកថាជាការបោះពុម្ពផ្សាយទេ។

(៤) ស្នាដៃមួយត្រូវបានចាត់ទុកថា បានបោះពុម្ពផ្សាយស្របពេលជាមួយគ្នានៅក្នុងប្រទេសជាច្រើនប្រសិនបើស្នាដៃនោះត្រូវបាន បោះពុម្ពផ្សាយនៅក្នុងប្រទេសពីរឬច្រើននៅក្នុងរយៈពេល៣០(សាមសិប)ថ្ងៃចាប់ពីការបោះពុម្ពផ្សាយលើកដំបូង។

## មាត្រា៤

## លក្ខខណ្ឌដើម្បីទទួលបានកិច្ចការពារស្នាដៃភាពយន្ត ស្នាដៃស្ថាបត្យកម្មនិងស្នាដៃសិល្បៈមួយចំនួន

ទោះបីលក្ខខណ្ឌនៃមាត្រា៣មិនត្រូវបានបំពេញក៏ដោយ ក៏កិច្ចការពារក្នុងអនុសញ្ញានេះត្រូវអនុវត្តចំពោះ

(ក) អ្នកនិពន្ធស្នាដៃភាពយន្ត ដែលផលិតករមានទីស្នាក់ការឬនិវេសនដ្ឋានអចិន្ត្រៃយ៍នៅក្នុងប្រទេសណាមួយនៃសហភាព។

(ខ) អ្នកនិពន្ធស្នាដៃស្ថាបត្យកម្មដែលបានសាងសង់ក្នុងប្រទេសមួយនៃសហភាព ឬស្នាដៃសិល្បៈផ្សេងទៀត ដែលភ្ជាប់ទៅនឹងអគារ ឬរចនាសម្ព័ន្ធផ្សេងទៀតនៅក្នុងប្រទេសមួយនៃសហភាព។

## មាត្រា៥

## សិទ្ធិដែលបានធានា : ១និង២- នៅក្រៅប្រទេសដើម ៣- នៅក្នុងប្រទេសដើម ៤-"ប្រទេសដើម"

(១) ចំពោះស្នាដៃដែលបានការពារតាមអនុសញ្ញានេះ នៅក្នុងប្រទេសនៃសហភាពក្រៅពីប្រទេសដើម អ្នកនិពន្ធត្រូវទទួលបានសិទ្ធិទាំងឡាយ ដែលច្បាប់របស់ប្រទេសនីមួយៗផ្តល់ឲ្យឬអាចផ្តល់ឲ្យនាពេលបន្ទាប់ទៅពលរដ្ឋរបស់ខ្លួនព្រមទាំងសិទ្ធិទាំងឡាយដែលអនុសញ្ញានេះបានផ្តល់ឱ្យជាពិសេស។

(២) ការទទួលបាននិងការអនុវត្តសិទ្ធិទាំងនេះ មិនតម្រូវឱ្យគោរពតាមទម្រង់ណាមួយទេ។ ការទទួលបាននិងការអនុវត្តសិទ្ធិទាំងនេះ ត្រូវមានឯករាជ្យភាពពីកិច្ចការពារដែលមាននៅក្នុងប្រទេសដើមនៃស្នាដៃ។ ហេតុដូច្នេះក្រៅពីបទប្បញ្ញត្តិនៃអនុសញ្ញានេះ វិសាលភាពនៃកិច្ចការពារក៏ដូចជាមធ្យោបាយជួសជុលការខូចខាតដែលបានធានាចំពោះអ្នកនិពន្ធដើម្បីការពារសិទ្ធិរបស់គាត់ ត្រូវគ្រប់គ្រងផ្តាច់មុខដោយច្បាប់នៃប្រទេសដែលបានអះអាងឱ្យការពារ។

(៣) កិច្ចការពារនៅក្នុងប្រទេសដើម ត្រូវគ្រប់គ្រងដោយច្បាប់ជាតិ។ ប៉ុន្តែនៅពេលដែលអ្នកនិពន្ធមិនមែនជាពលរដ្ឋនៃប្រទេសដើមដែលស្នាដៃរបស់គាត់ត្រូវបានការពារតាមអនុសញ្ញានេះ អ្នកនិពន្ធក៏ត្រូវទទួលបានសិទ្ធិដូចគ្នានឹងអ្នកនិពន្ធ ដែលជាពលរដ្ឋនៃប្រទេសនោះដែរ។

(៤) ចាត់ទុកថាជាប្រទេសដើមៈ

(ក) ក្នុងករណីដែលស្នាដៃត្រូវបានបោះពុម្ពផ្សាយជាលើកដំបូងក្នុងប្រទេសណាមួយនៃសហភាព ហើយក្នុងករណីប្រទេសនោះដែលច្បាប់របស់ខ្លួនបានផ្តល់នូវកិច្ចការពារខ្លីជាងគេ នៅពេលដែលស្នាដៃត្រូវបោះពុម្ពផ្សាយ ស្របពេលជាមួយគ្នាក្នុងប្រទេសផ្សេងទៀតនៃសហភាព ដែលផ្តល់រយៈពេលការពារផ្សេងៗពីគ្នា។

(ខ) ក្នុងករណីស្នាដៃបានបោះពុម្ពផ្សាយស្របពេលជាមួយគ្នាក្នុងប្រទេសមួយក្រៅសហភាព និងក្នុងប្រទេសមួយនៃសហភាពគឺជាប្រទេសក្នុងសហភាព។

(គ) ក្នុងករណីដែលស្នាដៃមិនបានបោះពុម្ពផ្សាយ ឬ ស្នាដៃត្រូវបានបោះពុម្ពផ្សាយជាលើកដំបូងក្នុងប្រទេសក្រៅសហភាពដោយពុំមានការបោះពុម្ពផ្សាយស្របពេលគ្នានៅក្នុងប្រទេសមួយនៃសហភាពគឺជាប្រទេសនៃសហភាព ដែលមានពលរដ្ឋខ្លួនជាអ្នកនិពន្ធឲ្យតែៈ

(i) នៅពេលដែលជាស្នាដៃភាពយន្តរបស់ផលិតករមានទីស្នាក់ការ ឬដែលមាននិវេសនដ្ឋានអចិន្ត្រៃយ៍ក្នុងប្រទេសមួយនៃសហភាព ប្រទេសនោះនឹងជាប្រទេសដើម និង

(ii) នៅពេលដែលស្នាដៃស្ថាបត្យកម្មដែលបានសាងសង់ក្នុងប្រទេសមួយនៃសហភាព ឬស្នាដៃសិល្បៈផ្សេងៗទៀតដែលភ្ជាប់ទៅនិងអគារឬរចនាសម្ព័ន្ធផ្សេងទៀតនៅក្នុងប្រទេសមួយនៃសហភាព ប្រទេសនោះនឹងជាប្រទេសដើម។

## មាត្រា៦

## លទ្ធភាពនៃការកម្រិតចំពោះកិច្ចការពារស្នាដៃមួយចំនួនរបស់ពលរដ្ឋនៃប្រទេសក្រៅសហភាពមួយចំនួន ១- នៅក្នុងប្រទេសនៃការបោះពុម្ពផ្សាយលើកដំបូងនិងក្រៅប្រទេសផ្សេងទៀត ២- អប្រតិសកម្ម ៣-ការជូនដំណឹង

(១) នៅពេលដែលប្រទេសក្រៅសហភាពណាមួយ ខកខានមិនការពារឲ្យបានគ្រប់គ្រាន់ដល់ស្នាដៃរបស់អ្នកនិពន្ធដែលជាពលរដ្ឋនៃប្រទេសមួយរបស់សហភាព ប្រទេសនេះអាចកម្រិតកិច្ចការពារដែលបានផ្តល់ឱ្យស្នាដៃអ្នកនិពន្ធតាមកាលបរិច្ឆេទនៃការបោះពុម្ពផ្សាយលើកដំបូងដែលជាពលរដ្ឋនៃប្រទេសផ្សេង ហើយមិនមែនជានិវេសនជនអចិន្ត្រៃយ៍ក្នុងប្រទេសមួយនៃសហភាព។ ប្រសិនបើប្រទេសនៃការបោះពុម្ពផ្សាយលើកដំបូងបានទទួលផលប្រយោជន៍ពីសិទ្ធិនេះ ប្រទេសផ្សេងទៀតនៃសហភាព មិនតម្រូវឱ្យផ្តល់ចំពោះស្នាដៃដែលបានដាក់ឱ្យស្ថិតនៅ ក្រោមប្រព្រឹត្តិកម្មពិសេសនូវកិច្ចការពារប្រសើរជាងកិច្ចការពារ ដែលផ្តល់ឲ្យស្នាដៃទាំងនេះក្នុងប្រទេសនៃការ បោះពុម្ពផ្សាយលើកដំបូង។

(២) គ្មានការកម្រិតណាមួយតាមកថាខណ្ឌខាងលើអាចប៉ះពាល់ដល់សិទ្ធិអ្នកនិពន្ធ ដែលអាចទទួលបានចំពោះស្នាដៃដែលបានបោះពុម្ពផ្សាយនៅក្នុងប្រទេសមួយនៃសហភាព មុនពេលការកម្រិតនេះចូលជាធរមាន។

(៣) ប្រទេសទាំងឡាយនៃសហភាពដែលកម្រិតកិច្ចការពារសិទ្ធិអ្នកនិពន្ធតាមមាត្រានេះ ត្រូវជូនដំណឹងទៅអគ្គនាយកនៃអង្គការកម្មសិទ្ធិបញ្ញាពិភពលោក (តទៅហៅថា"អគ្គនាយក") តាមរយៈសេចក្តីប្រកាសជាលាយលក្ខណ៍អក្សរដោយបញ្ជាក់ពីប្រទេសដែលបានកម្រិតកិច្ចការពារ និងបញ្ជាក់ពីការកម្រិតសិទ្ធិអ្នកនិពន្ធដែលជា ពលរដ្ឋនៃប្រទេសទាំងនោះ។ អគ្គនាយកត្រូវជូនដំណឹងអំពីសេចក្តីប្រកាសនេះភ្លាមទៅប្រទេសទាំងអស់នៃសហភាព។

## មាត្រា៦(ស្ទួន)

### សិទ្ធិសីលធម៌ : ១- ដើម្បីទាមទារឋានៈជាអ្នកនិពន្ធ ដើម្បីជំទាស់នូវការកែប្រែមួយចំនួននិងសកម្មភាពប្រមាថផ្សេងៗ ២- ក្រោយពេលអ្នកនិពន្ធទទួលមរណភាព ៣- មធ្យោបាយជួសជុលការខូចខាត

(១) ដោយមានឯករាជ្យស្តីពីសិទ្ធិបេតិកភណ្ឌរបស់អ្នកនិពន្ធ និងទោះបីជាបន្ទាប់ពីការផ្ទេរសិទ្ធិបេតិកភណ្ឌ អ្នកនិពន្ធមានសិទ្ធិទាមទារឋានៈជាអ្នកនិពន្ធនៃស្នាដៃ និងមានសិទ្ធិជំទាស់នូវរាល់ការបំផ្លើស ការកាត់ចោលខ្លឹម-សារ ឬការកែប្រែខ្លឹមសារ ឬសកម្មភាពប្រមាថនៃស្នាដៃដែលធ្វើឱ្យខូចកិត្តិយសឬកេរ្តិ៍ឈ្មោះរបស់អ្នកនិពន្ធ។

(២) សិទ្ធិដែលបានផ្តល់ឱ្យអ្នកនិពន្ធតាមកថាខណ្ឌខាងលើបន្ទាប់ពីមរណភាពរបស់អ្នកនិពន្ធ ត្រូវរក្សាទុកយ៉ាងហោចណាស់ត្រឹមពេលផុតកំណត់នៃសិទ្ធិបេតិកភណ្ឌ ហើយសិទ្ធិនេះនឹងត្រូវបានអនុវត្តដោយបុគ្គលឬស្ថាប័នដែលបានអនុញ្ញាតដោយច្បាប់នៃប្រទេសដែលបានអះអាងឱ្យការពារ។ ប៉ុន្តែនៅពេលដែលផ្តល់សច្ចាប័នឬចូលជាសមាជិកនៃច្បាប់នេះ ប្រទេសដែលមានច្បាប់ដែលមិនចែងអំពីកិច្ចការពារសិទ្ធិទាំងឡាយបន្ទាប់ពីមរណភាពរបស់អ្នកនិពន្ធតាម កថាខណ្ឌខាងលើ អាចចែងថាសិទ្ធិទាំងនេះ លែងត្រូវរក្សាទុកបន្ទាប់ពីមរណភាពរបស់អ្នកនិពន្ធ។

(៣) មធ្យោបាយជួសជុលការខូចខាតដើម្បីរក្សាសិទ្ធិតាមមាត្រានេះត្រូវគ្រប់គ្រងដោយច្បាប់នៃប្រទេសដែលបានអះអាងឲ្យការពារ។

## មាត្រា៧

### រយៈពេលនៃកិច្ចការពារ : ១- លក្ខណៈទូទៅ ២- ស្នាដៃភាពយន្ត ៣- ស្នាដៃអនាមិកនិងស្នាដៃរហស្សនាម ៤- ស្នាដៃថតរូបនិងស្នាដៃសិល្បៈអនុវត្ត ៥- ការចាប់ផ្តើមនៃការរាប់រយៈពេល ៦- រយៈពេលវែង ៧- រយៈពេលខ្លី ៨- ច្បាប់ដែលត្រូវអនុវត្ត "ការប្រៀបធៀប" រយៈពេល

(១) រយៈពេលនៃកិច្ចការពារសិទ្ធិអ្នកនិពន្ធដែលអនុសញ្ញានេះបានផ្តល់ឱ្យ គឺប្រព្រឹត្តទៅមួយជីវិតរបស់អ្នកនិពន្ធព្រមទាំង៥០(ហាសិប)ឆ្នាំ ក្រោយថ្ងៃទទួលមរណភាពរបស់អ្នកនិពន្ធ។

(២) ប៉ុន្តែក្នុងករណីស្នាដៃភាពយន្ត ប្រទេសទាំងឡាយនៃសហភាពអាចកំណត់រយៈពេលការពារផុតកំណត់៥០(ហាសិប)ឆ្នាំ បន្ទាប់ពីស្នាដៃនេះត្រូវបានដាក់ជូនសាធារណជន ដោយមានការអនុញ្ញាតពីអ្នកនិពន្ធ ឬពេលខកខានមិនបានដាក់ជូនសាធារណជនក្នុងរយៈពេល៥០(ហាសិប)ឆ្នាំបន្ទាប់ពីការបង្កើតស្នាដៃ ត្រូវការពារក្នុងរយៈពេល៥០(ហាសិប)ឆ្នាំ បន្ទាប់ពីការបង្កើតស្នាដៃនេះ។

(៣) ចំពោះស្នាដៃអនាមិក ឬរហស្សនាម រយៈពេលនៃកិច្ចការពារដែលអនុសញ្ញានេះបានផ្តល់ឱ្យ គឺប្រព្រឹត្តទៅ៥០(ហាសិប)ឆ្នាំបន្ទាប់ពីស្នាដៃនេះត្រូវបានដាក់ជូនសាធារណជនដោយស្របច្បាប់។ ប៉ុន្តែនៅពេលដែលរហស្សនាមរបស់អ្នកនិពន្ធនោះត្រូវបានគេស្គាល់អត្តសញ្ញាណរបស់គាត់ដោយឥតសង្ស័យ រយៈពេលនៃកិច្ចការពារ គឺរយៈពេលដែលមានចែងក្នុងកថាខណ្ឌ(១)។ ប្រសិនបើអ្នកនិពន្ធនៃស្នាដៃអនាមិកឬរហស្សនាមបានបង្ហាញអត្តសញ្ញាណរបស់ខ្លួនក្នុងរយៈពេលដែលបានលើកឡើងខាងលើ រយៈពេលនៃកិច្ចការពារដែលអាច

អនុវត្តបាន គឺរយៈពេលដែលមានចែងក្នុងកថាខណ្ឌ(១)។ ប្រទេសទាំងឡាយនៃសហភាពមិនបានតម្រូវឱ្យការពារស្នាដៃ អនាមិកឬហស្សនាមនៅពេលដែលមានហេតុផលដែលត្រូវសន្មតថាអ្នកនិពន្ធនៃស្នាដៃទាំងនេះបានទទួលមរណ ភាព៥០(ហាសិប)ឆ្នាំហើយ។

(៤) វាស្ថិតនៅលើច្បាប់របស់ប្រទេសនៃសហភាពក្នុងការកំណត់រយៈពេលការពារស្នាដៃថតរូបនិងស្នាដៃសិល្បៈអនុវត្ត ដោយលុះត្រាតែស្នាដៃទាំងនេះ ត្រូវបានការពារជាស្នាដៃសិល្បៈ ប៉ុន្តែរយៈពេលនៃកិច្ច ការពារត្រូវមានរយៈពេលផុតកំណត់យ៉ាងហោចណាស់រហូតដល់២៥(ម្ភៃប្រាំ)ឆ្នាំបន្ទាប់ពីពេលបង្កើតស្នាដៃ។

(៥) រយៈពេលនៃកិច្ចការពារបន្ទាប់ពីមរណភាពរបស់អ្នកនិពន្ធនិងរយៈពេលដូចមានចែងក្នុងកថាខណ្ឌ(២) កថាខណ្ឌ(៣) និងកថាខណ្ឌ(៤) ត្រូវគិតចាប់ពីកាលបរិច្ឆេទនៃការទទួលមរណភាព ឬកាលបរិច្ឆេទនៃព្រឹត្តិការណ៍ដូចមានចែងក្នុងកថាខណ្ឌខាងលើ ប៉ុន្តែរយៈពេលនេះ តែងតែត្រូវគិតចាប់ពីថ្ងៃទី១ ខែមករានៃឆ្នាំដែលអ្នកនិពន្ធទទួលមរណភាពឬព្រឹត្តិការណ៍ខាងលើ។

(៦) ប្រទេសទាំងឡាយនៃសហភាព អាចផ្តល់រយៈពេលការពារច្រើនជាងរយៈពេលដែលមានចែងក្នុងកថាខណ្ឌខាងលើ។

(៧) ប្រទេសទាំងឡាយនៃសហភាពដែលចងភ្ជាប់ដោយច្បាប់ទីក្រុងរ៉ូមនៃអនុសញ្ញានេះ នៅក្នុងច្បាប់ជាតិរបស់ខ្លួនដែលចូលជាធរមាននៅពេលចុះហត្ថលេខាលើច្បាប់នេះ ដែលផ្តល់រយៈពេលការពារខ្លីជាងអ្វីដែលបានកំណត់ក្នុងកថាខណ្ឌខាងលើមានសិទ្ធិរក្សារយៈពេលនេះនៅពេលផ្តល់សច្ចាប័ន ឬចូលជាសមាជិកនៃ ច្បាប់នេះ។

(៨) ក្នុងករណីណាក៏ដោយ រយៈពេលនេះត្រូវគ្រប់គ្រងដោយច្បាប់នៃប្រទេសដែលបានអះអាងឱ្យការពារ ប៉ុន្តែលើកលែងតែច្បាប់នៃប្រទេសនោះចែងផ្សេងពីនេះ រយៈពេលនេះមិនត្រូវលើសពីរយៈពេលដែលបានកំណត់ដោយប្រទេសដើមនៃស្នាដៃ ។

## មាត្រា៧(ស្ទួន )

## រយៈពេលនៃកិច្ចការពារចំពោះស្នាដៃសហការ

បទប្បញ្ញត្តិនៃមាត្រាខាងលើត្រូវយកមកអនុវត្តផងដែរចំពោះស្នាដៃសហការលុះត្រាតែរយៈពេលដែលរាប់ចាប់ពីមរណភាពរបស់អ្នកនិពន្ធ ត្រូវគិតចាប់ពីមរណភាពរបស់អ្នកនិពន្ធដែលរស់នៅចុងក្រោយគេ។

## មាត្រា៨

## សិទ្ធិបកប្រែ

អ្នកនិពន្ធស្នាដៃអក្សរសាស្ត្រនិងសិល្បៈ ដែលអនុសញ្ញានេះបានការពារ មានសិទ្ធិផ្តាច់មុខក្នុងការធ្វើការបកប្រែ និង អនុញ្ញាតឱ្យបកប្រែស្នាដៃរបស់ខ្លួនស្របទៅតាមរយៈពេលការពារសិទ្ធិស្នាដៃដើម។

## មាត្រា៩

### សិទ្ធិផលិតឡើងវិញ: ១- លក្ខណៈទូទៅ ២- អញ្ញត្រកម្មដែលអាចមាន ៣- ការថតបញ្ចូលជាសំឡេងនិងជារូបភាព

(១) អ្នកនិពន្ធស្នាដៃអក្សរសាស្ត្រនិងសិល្បៈដែលអនុសញ្ញានេះបានការពារ មានសិទ្ធិផ្តាច់មុខក្នុងការអនុញ្ញាតឱ្យផលិតឡើងវិញនូវស្នាដៃទាំងនេះតាមរបៀបឬទម្រង់ណាក៏ដោយ។

(២) វាស្ថិតនៅលើច្បាប់របស់ប្រទេសនៃសហភាព ក្នុងការអនុញ្ញាតឲ្យផលិតឡើងវិញនូវស្នាដៃទាំងនេះ តែក្នុងករណីពិសេសមួយចំនួនលុះត្រាតែការផលិតឡើងវិញ មិនធ្វើឱ្យប៉ះពាល់ដល់អាជីវកម្មជាប្រក្រតីនៃស្នាដៃ និងមិនធ្វើឱ្យខូចខាតដោយមិនសមហេតុផលទៅលើផលប្រយោជន៍ស្របច្បាប់របស់អ្នកនិពន្ធ។

(៣) ការថតបញ្ចូលជាសំឡេងឬជារូបភាព ត្រូវបានចាត់ទុកជាការផលិតឡើងវិញក្នុងគោលបំណងនៃអនុសញ្ញានេះ។

## មាត្រា១០

### លទ្ធភាពនៃការប្រើប្រាស់ស្នាដៃដោយសេរីមួយចំនួនទៀត : ១- អាគតដ្ឋាន ២- ការបញ្ជាក់ឲ្យបានច្បាស់នៅក្នុងការបង្រៀន ៣- ការបញ្ជាក់ពីប្រភពនិងឈ្មោះអ្នកនិពន្ធ

(១) អនុញ្ញាតឱ្យស្រង់អាគតដ្ឋានចេញពីស្នាដៃ ដែលបានផ្សព្វផ្សាយត្រឹមត្រូវតាមច្បាប់ទៅសាធារណជន លុះត្រាតែការស្រង់នេះស្របនឹងការអនុវត្តទៀងត្រង់ ហើយកម្រិតនៃការស្រង់មិនត្រូវធ្វើឱ្យហួសពីគោលដៅដែលត្រូវបំពេញដោយរាប់បញ្ចូលការស្រង់អាគតដ្ឋានពីអត្ថបទសារព័ត៌មាន និងទស្សនាវដ្តីក្នុងទម្រង់ជាការសង្ខេបព័ត៌មាន។

(២) វាស្ថិតនៅលើច្បាប់របស់ប្រទេសនៃសហភាព និងកិច្ចព្រមព្រៀងពិសេសដែលមានស្រាប់ឬដែលនឹងមានរវាងប្រទេសនានានៃសហភាពក្នុងការអនុញ្ញាតឱ្យប្រើប្រាស់ ស្របនឹងគោលដៅដែលត្រូវបំពេញនូវស្នាដៃអក្សរសាស្ត្រ ឬ សិល្បៈ តាមរយៈការបញ្ជាក់ឱ្យបានច្បាស់នៅក្នុងការបោះពុម្ពផ្សាយ ការផ្សាយតាមទូរផ្សាយ ឬការថតបញ្ចូលជា សំឡេងឬជារូបភាពដើម្បីបង្រៀន លុះត្រាតែការប្រើប្រាស់នេះស្របនឹងការអនុវត្តទៀងត្រង់។

(៣) នៅពេលដែលបានប្រើប្រាស់ស្នាដៃតាមកថាខណ្ឌខាងលើនៃមាត្រានេះត្រូវបញ្ជាក់ពីប្រភព និងឈ្មោះអ្នកនិពន្ធប្រសិនបើមានឈ្មោះនិងប្រភព។

## មាត្រា១០(ស្ទួន)

### លទ្ធភាពនៃការប្រើប្រាស់ស្នាដៃដោយសេរីមួយចំនួនទៀត : ១. អត្ថបទសារព័ត៌មានមួយចំនួននិងស្នាដៃទូរផ្សាយមួយចំនួន២- ស្នាដៃដែលអាចស្តាប់ឮឬមើលឃើញ ដែលទាក់ទងនឹងព្រឹត្តិការណ៍បច្ចុប្បន្នភាព

(១) វាស្ថិតនៅលើច្បាប់របស់ប្រទេសនៃសហភាពក្នុងការអនុញ្ញាតឱ្យផលិតឡើងវិញ តាមរយៈសារព័ត៌មាន ការផ្សាយតាមទូរផ្សាយ ឬការផ្សព្វផ្សាយជាសាធារណៈតាមខ្សែនៃអត្ថបទដែលបានបោះពុម្ពផ្សាយរួចហើយក្នុងសារព័ត៌មាន ឬទស្សនាវដ្តីស្តីពីបច្ចុប្បន្នភាពនៃបញ្ហាសេដ្ឋកិច្ច នយោបាយ ឬសាសនា និងការផ្សាយ

ស្នាដៃផ្សេងៗទៀត ដែលមានលក្ខណៈដូចគ្នាក្នុងករណីដែលការផលិតឡើងវិញ ការផ្សាយតាមទូរផ្សាយ ឬក៏ការផ្សព្វផ្សាយទាំងនេះ មិនបានបញ្ជាក់ជាក់លាក់ទេ។ ប៉ុន្តែប្រភពនៃស្នាដៃត្រូវតែបញ្ជាក់ឱ្យបានច្បាស់លាស់។ វិបាកផ្លូវច្បាប់នៃការបំពានកាតព្វកិច្ចនេះ ត្រូវកំណត់ដោយច្បាប់នៃប្រទេសដែលអះអាងឱ្យការពារ។

(២) វាក៏ស្ថិតនៅលើច្បាប់របស់ប្រទេសនៃសហភាពក្នុងការកំណត់លក្ខខណ្ឌនៃការផលិតឡើងវិញ និងការដាក់ជូនសាធារណជននូវស្នាដៃអក្សរសាស្ត្រនិងសិល្បៈដែលមើលឃើញនិងស្ដាប់ឮ ពេលកំពុងមានព្រឹត្តិការណ៍ ក្នុងគោលបំណងផ្ដល់ព័ត៌មាន ចំពោះការរាយការណ៍ព្រឹត្តិការណ៍បច្ចុប្បន្នភាពទាំងឡាយតាមរយៈការថតរូប ការថតបញ្ចូល ជាភាពយន្ត ការផ្សាយតាមទូរផ្សាយ និងការផ្សព្វផ្សាយជាសាធារណៈតាមខ្សែ។

## មាត្រា១១

## សិទ្ធិមួយចំនួននៃស្នាដៃនាដកម្មនិងតូរ្យតន្ត្រី : ១- សិទ្ធិសម្ដែងជាសាធារណៈនិងសិទ្ធិផ្សព្វផ្សាយជាសាធារណៈនូវការសម្ដែង ២- ចំពោះការបកប្រែ

(១) អ្នកនិពន្ធស្នាដៃនាដកម្ម នាដកម្មតូរ្យតន្ត្រី និងតូរ្យតន្ត្រី មានសិទ្ធិផ្ដាច់មុខក្នុងការអនុញ្ញាតឱ្យមានៈ

(i) ការសម្ដែងជាសាធារណៈនូវស្នាដៃរបស់ខ្លួន រួមមានការសម្ដែងជាសាធារណៈតាមវិធីឬរបៀបណាមួយ

(ii) ការផ្សព្វផ្សាយជាសាធារណៈនៃការសម្ដែងស្នាដៃរបស់ខ្លួន។

(២) អ្នកនិពន្ធស្នាដៃនាដកម្ម ឬនាដកម្មតូរ្យតន្ត្រី ត្រូវមានសិទ្ធិដូចគ្នាចំពោះការបកប្រែស្នាដៃទាំងនេះ ក្នុងអំឡុងពេលនៃការអនុវត្តសិទ្ធិលើស្នាដៃដើមរបស់ខ្លួន។

## មាត្រា១១(ស្ទួន)

## សិទ្ធិផ្សាយតាមទូរផ្សាយនិងសិទ្ធិពាក់ព័ន្ធ : ១- ការផ្សាយតាមទូរផ្សាយនិងការផ្សព្វផ្សាយដោយឥតខ្សែ ការផ្សព្វផ្សាយជាសាធារណៈតាមទូរផ្សាយមានខ្សែ ឬការផ្សាយឡើងវិញ ការផ្សាយជាសាធារណៈតាមទូរផ្សាយដោយឧបករណ៍បំពងសំឡេងឬដោយឧបករណ៍ផ្សេងទៀតដែលមានលក្ខណៈដូចគ្នា ២- អាជ្ញាប័ណ្ណបញ្ជា ៣- ការថតបញ្ចូល ការថតបញ្ចូលបណ្ដោះអាសន្ន

(១) អ្នកនិពន្ធស្នាដៃអក្សរសាស្ត្រនិងសិល្បៈ ត្រូវទទួលបានសិទ្ធិផ្ដាច់មុខក្នុងការអនុញ្ញាតៈ

(i) ការផ្សាយតាមទូរផ្សាយនៃស្នាដៃរបស់ខ្លួន ឬការផ្សព្វផ្សាយជាសាធារណៈនូវស្នាដៃទាំងនេះតាមរយៈវិធីណាមួយដោយឥតខ្សែដែលមានបញ្ចូលនូវសញ្ញា សំឡេង ឬរូបភាព

(ii) ការផ្សព្វផ្សាយជាសាធារណៈតាមខ្សែឬការផ្សាយឡើងវិញនៃការផ្សាយស្នាដៃ នៅពេលដែលការផ្សព្វផ្សាយនេះធ្វើឡើងដោយអង្គភាពណាមួយដែលមិនមែនជាអង្គភាពដើម

(iii) ការផ្សព្វផ្សាយជាសាធារណៈតាមរយៈឧបករណ៍បំពងសំឡេង ឬឧបករណ៍បញ្ជូនដែលមានលក្ខណៈដូចគ្នាផ្សេងទៀត ការចាក់ស្នាដៃដោយ សញ្ញា សម្លេង ឬរូបភាព។

(២) វាស្ថិតនៅលើច្បាប់របស់ប្រទេសនៃសហភាពក្នុងការកំណត់ពីលក្ខខណ្ឌនៃការអនុវត្តសិទ្ធិ តាមកថាខណ្ឌខាងលើ ប៉ុន្តែលក្ខខណ្ឌទាំងនេះអាចយកមកអនុវត្តបានតែក្នុងប្រទេសណា ដែលបានចែងនូវលក្ខខណ្ឌទាំងនេះប៉ុណ្ណោះ។ លក្ខខណ្ឌទាំងនេះមិនត្រូវធ្វើឱ្យប៉ះពាល់ក្នុងករណីណាក៏ដោយដល់សិទ្ធិសីលធម៌ឬសិទ្ធិទទួលបានលាភការសមរម្យរបស់អ្នកនិពន្ធ ដែលត្រូវកំណត់ដោយអាជ្ញាធរមានសមត្ថកិច្ច ប្រសិនបើគ្មានការព្រមព្រៀង។

(៣) ប្រសិនបើគ្មានចែងផ្ទុយពីនេះ ការអនុញ្ញាតតាមកថាខណ្ឌ១ នៃមាត្រានេះ មិនត្រូវយកមកអនុវត្តចំពោះការថតបញ្ចូលនូវស្នាដៃដែលបានផ្សាយតាមរយៈឧបករណ៍ថតសំឡេងឬថតរូបភាពឡើយ។ ប៉ុន្តែវាស្ថិតនៅលើច្បាប់របស់ប្រទេសនៃសហភាព ក្នុងការកំណត់វិធានក្នុងការថតបញ្ចូលបណ្តោះអាសន្នដោយអង្គភាពទូរផ្សាយតាមរយៈការប្រើប្រាស់ឧបករណ៍ផ្ទាល់ខ្លួន និងប្រើប្រាស់សម្រាប់ការផ្សាយរបស់ខ្លួន។ ការរក្សាទុកនូវការថតចម្លងនេះនៅក្នុងបណ្ណសារដ្ឋានផ្លូវការអាចត្រូវបានអនុញ្ញាត ដោយច្បាប់ដោយមូលហេតុនៃចរិតលក្ខណៈពិសេសរបស់ឯកសារ។

## មាត្រា១១(ស្ទួន)៣

## សិទ្ធិមួយចំនួននៃស្នាដៃអក្សរសាស្ត្រ : ១- សិទ្ធិសូត្រជាសាធារណៈនិងសិទ្ធិផ្សព្វផ្សាយជាសាធារណៈនៃការសូត្រ ២- ចំពោះការបកប្រែ

(១) អ្នកនិពន្ធស្នាដៃអក្សរសាស្ត្រ ត្រូវទទួលបានសិទ្ធិផ្តាច់មុខក្នុងការអនុញ្ញាតៈ

(i) ការសូត្រជាសាធារណៈនូវស្នាដៃរបស់ខ្លួន រួមទាំងការសូត្រជាសាធារណៈតាមរយៈវិធីណាមួយ ឬរបៀបណាមួយក៏ដោយ

(ii) ការផ្សព្វផ្សាយជាសាធារណៈ នៃការសូត្រស្នាដៃរបស់ខ្លួន។

(២) អ្នកនិពន្ធនៃស្នាដៃអក្សរសាស្ត្រ ត្រូវទទួលបានសិទ្ធិដូចគ្នាចំពោះការបកប្រែស្នាដៃទាំងនេះក្នុងកំឡុងពេលនៃការអនុវត្តសិទ្ធិលើស្នាដៃដើមរបស់ខ្លួន។

## មាត្រា១២

## សិទ្ធិយកលំនាំតាម សិទ្ធិសម្រួល និងសិទ្ធិកែប្រែផ្សេងទៀត

អ្នកនិពន្ធស្នាដៃអក្សរសាស្ត្រឬសិល្បៈ ត្រូវទទួលបានសិទ្ធិផ្តាច់មុខក្នុងការអនុញ្ញាតឱ្យមានការយកលំនាំតាមការសម្រួល ឬការកែប្រែផ្សេងទៀតទៅលើស្នាដៃរបស់ខ្លួន។

## មាត្រា១៣

## លទ្ធភាពនៃការកម្រិតសិទ្ធិថតបញ្ចូលស្នាដៃតូរ្យតន្ត្រីនិងទំនុកច្រៀងដែលមានក្នុងស្នាដៃនេះ : ១- អាជ្ញាបណ្ណបញ្ជា ២-វិធានការបណ្តោះអាសន្ន ៣- ការរឹបអូស ការនាំចូលច្បាប់ចម្លងដែលធ្វើឡើងដោយគ្មានការអនុញ្ញាតពីអ្នកនិពន្ធ

(១) ប្រទេសនីមួយៗនៃសហភាព អាចបង្កើតឱ្យមានខរក្សាសិទ្ធិនិងលក្ខខណ្ឌស្តីពីសិទ្ធិផ្តាច់មុខ ដែលផ្តល់ឱ្យអ្នកនិពន្ធស្នាដៃតូរ្យតន្ត្រីនិងអ្នកនិពន្ធទំនុកច្រៀង ដែលការថតបញ្ចូលទំនុកច្រៀងរួមជាមួយស្នាដៃតូរ្យតន្ត្រីបាន

ទទួលការអនុញ្ញាតរួចហើយពីអ្នកនិពន្ធ នូវសិទ្ធិអនុញ្ញាតការថតបញ្ចូលជាសំឡេងនៃស្នាដៃតូរ្យតន្ត្រី រួមទាំងទំនុកច្រៀងប្រសិនបើមាន ក៏ប៉ុន្តែខរក្សាសិទ្ធិនិងលក្ខខណ្ឌទាំងនេះអាចយកមកអនុវត្តបានតែក្នុងប្រទេសណា ដែលបានចែងនូវខរក្សាសិទ្ធិនិងលក្ខខណ្ឌទាំងនេះតែប៉ុណ្ណោះ ហើយមិនត្រូវធ្វើឱ្យប៉ះពាល់ក្នុងករណីណាក៏ដោយដល់សិទ្ធិរបស់អ្នកនិពន្ធទាំងនេះក្នុងការទទួលបានលាភការសមរម្យ ដែលត្រូវកំណត់ដោយអាជ្ញាធរមានសមត្ថកិច្ចប្រសិនបើគ្មានការព្រមព្រៀង។

(២) ការថតបញ្ចូលនូវស្នាដៃតូរ្យតន្ត្រីដែលបានបង្កើតនៅក្នុងប្រទេសមួយនៃសហភាពតាមមាត្រា១៣(៣) នៃអនុសញ្ញានានាដែលបានចុះហត្ថលេខានៅទីក្រុងរ៉ូម ថ្ងៃទី២ ខែមិថុនា ឆ្នាំ១៩២៨ និងនៅទីក្រុងព្រុច សែល ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ១៩៤៨ អាចនឹងត្រូវបានផលិតឡើងវិញនៅក្នុងប្រទេសនោះដោយពុំចាំបាច់សុំការអនុញ្ញាតពីអ្នកនិពន្ធស្នាដៃតូរ្យតន្ត្រីឡើយ រហូតដល់កាលកំណត់២(ពីរ)ឆ្នាំ បន្ទាប់ពីប្រទេសនោះបានចងភ្ជាប់ ដោយច្បាប់នេះ។

(៣) ការថតបញ្ចូល ដែលធ្វើតាមកថាខណ្ឌ(១)និង(២)នៃមាត្រានេះ ហើយបាននាំចូលដោយគ្មានការអនុញ្ញាតពីភាគីពាក់ព័ន្ធក្នុងប្រទេសមួយ ដែលត្រូវបានចាត់ទុកថាបានរំលោភបំពានការថតបញ្ចូលនេះ អាចធ្វើការរឹបអូសបាន។

## មាត្រា ១៤

## សិទ្ធិថតបញ្ចូលជាភាពយន្តនិងសិទ្ធិពាក់ព័ន្ធ : ១- ការយកលំនាំតាមភាពយន្តនិងការផលិតឡើងវិញ ការចែកចាយ ការសម្តែងជាសាធារណៈ និងការផ្សព្វផ្សាយជាសាធារណៈតាមខ្សែនៃស្នាដៃ ដែលបានយកលំនាំតាម ឬដែលបានផលិតឡើងវិញ ២- ការយកលំនាំការផលិតភាពយន្ត ៣- គ្មានអាជ្ញាប័ណ្ណបញ្ជា

(១) អ្នកនិពន្ធស្នាដៃអក្សរសាស្ត្រឬសិល្បៈ ត្រូវមានសិទ្ធិផ្តាច់មុខក្នុងការអនុញ្ញាតៈ

(i) ការយកលំនាំតាមនិងការផលិតឡើងវិញនូវស្នាដៃភាពយន្ត និងការចែកចាយនូវស្នាដៃទាំងនេះដែលត្រូវបានយកលំនាំតាម ឬត្រូវបានផលិតឡើងវិញ

(ii) ការសម្តែងជាសាធារណៈ និងការផ្សព្វផ្សាយជាសាធារណៈតាមខ្សែនៃស្នាដៃដែលបានយកលំនាំតាម ឬបានផលិតឡើងវិញ។

(២) ការយកលំនាំតាម ក្នុងទម្រង់សិល្បៈផ្សេងៗណាមួយនៃផលិតផលភាពយន្តដែលកើតចេញពី ស្នាដៃអក្សរសាស្ត្រឬសិល្បៈ ត្រូវមានការអនុញ្ញាតពីអ្នកនិពន្ធនៃស្នាដៃដើម ដោយមិនធ្វើឱ្យប៉ះពាល់ដល់ការអនុញ្ញាតរបស់អ្នកនិពន្ធនៃផលិតផលភាពយន្តឡើយ។

(៣) បទប្បញ្ញត្តិនៃមាត្រា១៣(១) មិនត្រូវយកមកអនុវត្តទេ។

## មាត្រា ១៤(ស្ទួន)

## បទប្បញ្ញត្តិពិសេសទាក់ទងនឹងស្នាដៃភាពយន្ត : ១- ការប្រដូចនឹងស្នាដៃដើម ២- ម្ចាស់សិទ្ធិ ការកម្រិតសិទ្ធិរបស់អ្នកចូលរួមមួយចំនួន ៣- អ្នកចូលរួមផ្សេងទៀត

(១) ដោយមិនប៉ះពាល់ដល់សិទ្ធិអ្នកនិពន្ធស្នាដៃណាមួយ ដែលអាចយកលំនាំតាមឬផលិតឡើងវិញ ស្នាដៃភាពយន្តនឹងត្រូវទទួលកិច្ចការពារដូចស្នាដៃដើម។ ម្ចាស់សិទ្ធិអ្នកនិពន្ធស្នាដៃភាពយន្ត ត្រូវមានសិទ្ធិដូចនឹងអ្នកនិពន្ធស្នាដៃដើមដែរ រួមទាំងសិទ្ធិតាមមាត្រាខាងលើ។

(២)

(ក) ម្ចាស់សិទ្ធិអ្នកនិពន្ធនៃស្នាដៃភាពយន្ត ត្រូវកំណត់ដោយច្បាប់នៃប្រទេសដែលបានអះអាងឱ្យការពារ។

(ខ) ប៉ុន្តែក្នុងប្រទេសនានានៃសហភាព ដែលមានច្បាប់ទទួលស្គាល់ម្ចាស់សិទ្ធិអ្នកនិពន្ធស្នាដៃភាពយន្តទាំងឡាយដែលបានចូលរួមវិភាគទានក្នុងការបង្កើតស្នាដៃ ប្រសិនបើអ្នកនិពន្ធទាំងឡាយនោះបានយល់ព្រមនឹងការចូលរួមវិភាគទាន ហើយបើគ្មានបទប្បញ្ញត្តិផ្ទុយឬបទប្បញ្ញត្តិពិសេស ពួកគាត់មិនអាចជំទាស់នឹងការផលិតឡើងវិញ ការចែកចាយ ការសម្តែងជាសាធារណៈ ការផ្សព្វផ្សាយ ជាសាធារណៈតាមខ្សែ ការផ្សាយតាមទូរផ្សាយ ឬការផ្សព្វផ្សាយជា សាធារណៈផ្សេងទៀត ឬការដាក់ចំណងជើង ឬការបញ្ចូលសំឡេងនៃអត្ថបទរបស់ស្នាដៃឡើយ ។

(គ) ដើម្បីអនុវត្តអនុកថាខណ្ឌ(ខ)ខាងលើ សំណួរថាតើទម្រង់នៃកិច្ចព្រមព្រៀងដូចមានចែងខាងលើ គួរតែធ្វើឬមិនគួរតែធ្វើជាកិច្ចសន្យាលាយលក្ខណ៍អក្សរ ឬជាលិខិតលាយលក្ខណ៍អក្សរដែលមានតម្លៃស្មើ ត្រូវកំណត់ដោយច្បាប់របស់ប្រទេសនៃទីស្នាក់ការឬទីលំនៅអចិន្ត្រៃយ៍របស់ផលិតករស្នាដៃភាពយន្តនោះ។ ក៏ប៉ុន្តែវាស្ថិតនៅលើច្បាប់របស់ប្រទេសនៃសហភាពដែលបានអះអាងឲ្យការពារ ជាអ្នកកំណត់ថាកិច្ចព្រមព្រៀងខាងលើត្រូវធ្វើជាកិច្ចសន្យាលាយលក្ខណ៍អក្សរ ឬជាលិខិតលាយលក្ខណ៍អក្សរដែលមានតម្លៃស្មើ។ ប្រទេសទាំងឡាយដែលមានច្បាប់ចែងបែបនេះ ត្រូវជូនដំណឹងទៅអគ្គនាយកតាមរយៈសេចក្តីប្រកាសជាលាយលក្ខណ៍អក្សរ ហើយអគ្គនាយក ត្រូវជូនដំណឹងភ្លាមទៅប្រទេសផ្សេងទៀតទាំងអស់នៃសហភាព។

(ឃ) "បទប្បញ្ញាត្តិផ្ទុយឬពិសេស" មានន័យថាលក្ខខណ្ឌរឹតត្បិតណាមួយដែលទាក់ទងទៅនឹងកិច្ចព្រមព្រៀងខាងលើ។

(៣) បទប្បញ្ញាត្តិនៃកថាខណ្ឌ២(ខ)ខាងលើ មិនត្រូវយកមកអនុវត្តចំពោះអ្នកនិពន្ធស្នាដៃសេណារីយ៉ូ ស្នាដៃសន្ទនា និងស្នាដៃតូរ្យតន្ត្រីដែលបានបង្កើតក្នុងពេលផលិតស្នាដៃភាពយន្ត ឬមិនអនុវត្តចំពោះសមិទ្ធិករនៃស្នាដៃទាំងនេះឡើយ លើកលែងតែច្បាប់ជាតិចែងផ្ទុយពីនេះ។ ប៉ុន្តែប្រទេសទាំងឡាយនៃសហភាព ដែលគ្មាន

ច្បាប់ចែងអំពីវិធានក្នុងការអនុវត្តកថាខណ្ឌ២(ខ)ចំពោះសមិទ្ធិករ ត្រូវជូនដំណឹងទៅអគ្គនាយកតាមរយៈសេចក្ដីប្រកាសជាលាយលក្ខណ៍អក្សរ ហើយអគ្គនាយកត្រូវជូនដំណឹងភ្លាមទៅប្រទេសផ្សេងទៀតទាំងអស់នៃសហភាព។

## មាត្រា១៤(ស្ទួន)៣

## បទប្បញ្ញត្តិមរតកសាសន៍ចំពោះស្នាដៃសិល្បៈ និងអត្ថបទសរសេរដោយដៃ: ១- សិទ្ធិទទួលបានប្រយោជន៍ចំពោះការលក់ឡើងវិញ ២- ច្បាប់ដែលត្រូវអនុវត្ត ៣- នីតិវិធី

(១) ចំពោះស្នាដៃសិល្បៈដើមនិងអត្ថបទសរសេរដោយដៃដើមរបស់អ្នកនិពន្ធនិងរបស់អ្នកនិពន្ធបទភ្លេង អ្នកនិពន្ធឬបន្ទាប់ពីមរណភាពរបស់អ្នកនិពន្ធ បុគ្គលឬស្ថាប័នទាំងឡាយដែលច្បាប់ជាតិបានអនុញ្ញាត ត្រូវទទួលបានសិទ្ធិដែលមិនអាចកែប្រែបាន ដែលមានប្រយោជន៍ចំពោះការលក់ស្នាដៃណាមួយ បន្ទាប់ពីមានការផ្ទេរសិទ្ធិលើកដំបូងដោយអ្នកនិពន្ធនៃស្នាដៃ ។

(២) កិច្ចការពារតាមកថាខណ្ឌខាងលើ អាចត្រូវបានអះអាងក្នុងប្រទេសនៃសហភាព លុះណាតែច្បាប់នៃប្រទេសរបស់អ្នកនិពន្ធនោះនិងច្បាប់នៃប្រទេសដែលអះអាងឱ្យការពារ បានអនុញ្ញាត។

(៣) នីតិវិធីនិងចំនួននៃការប្រមូលកម្រៃ ត្រូវកំណត់ដោយច្បាប់ជាតិ។

## មាត្រា១៥

## សិទ្ធិក្នុងការអនុវត្តសិទ្ធិដែលបានការពារ : ១- នៅពេលដែលឈ្មោះរបស់អ្នកនិពន្ធត្រូវបានបញ្ជាក់ ឬនៅពេលហេស្សនាមបានបង្ហាញដោយគ្មានការសង្ស័យចំពោះអត្តសញ្ញាណរបស់អ្នកនិពន្ធ ២- ករណីស្នាដៃភាពយន្ត ៣- ករណីស្នាដៃអនាមិកនិងហេស្សនាម ៤- ករណីស្នាដៃមួយចំនួនដែលបានបោះពុម្ពដោយមិនស្គាល់ឈ្មោះអ្នកនិពន្ធ

(១) ដើម្បីឱ្យអ្នកនិពន្ធស្នាដៃអក្សរសាស្ត្រ ឬសិល្បៈការពារដោយអនុសញ្ញានេះ លើកលែងតែមានភស្តុតាងផ្ទុយ ត្រូវទទួលបាននូវកិច្ចការពារហើយមានសិទ្ធិប្ដឹងតាមនីតិវិធីនៃប្រទេសរបស់សហភាព ឈ្មោះរបស់អ្នកនិពន្ធ ត្រូវបានបង្ហាញជាធម្មតាលើស្នាដៃនោះ។ កថាខណ្ឌនេះត្រូវយកមកអនុវត្តបានផងដែរចំពោះហេស្សនាម ឱ្យតែហេស្សនាម ដែលអ្នកនិពន្ធបានយកមកប្រើ បានបង្ហាញដោយគ្មានការសង្ស័យចំពោះអត្តសញ្ញាណរបស់អ្នកនិពន្ធ។

(២) រូបវន្តបុគ្គលឬនីតិបុគ្គល ដែលមានឈ្មោះនៅលើស្នាដៃភាពយន្តក្នុងលក្ខណៈធម្មតា ត្រូវបានទទួលសច្ចាធារណ៍ថាជាផលិតករនៃស្នាដៃនេះលើកលែងតែមានភស្តុតាងផ្ទុយ។

(៣) ក្នុងករណីស្នាដៃអនាមិកនិងហេស្សនាមផ្សេងពីស្នាដៃដែលមានចែងក្នុងកថាខណ្ឌ(១)ខាងលើ អ្នកបោះពុម្ពផ្សាយដែលមានឈ្មោះនៅលើស្នាដៃ លើកលែងតែមានភស្តុតាងផ្ទុយ ត្រូវចាត់ទុកថាជាតំណាងរបស់អ្នកនិពន្ធ ហើយក្នុងឋានៈនេះ អ្នកបោះពុម្ពផ្សាយមានសិទ្ធិការពារនិងអនុវត្តសិទ្ធិអ្នកនិពន្ធ។ បទប្បញ្ញត្តិនៃកថាខណ្ឌនេះនឹងមិនយកមកអនុវត្តទេ នៅពេលអ្នកនិពន្ធបង្ហាញឱ្យដឹងពីអត្តសញ្ញាណរបស់ខ្លួន ហើយធ្វើការស្នើសុំឋានៈជាអ្នកនិពន្ធលើស្នាដៃ។

(៤)

(ក) ក្នុងករណីដែលស្នាដៃមិនបានបោះពុម្ពផ្សាយ ហើយអត្តសញ្ញាណរបស់អ្នកនិពន្ធមិនត្រូវបានស្គាល់ ប៉ុន្តែមានមូលដ្ឋានគ្រប់គ្រាន់ដើម្បីធ្វើសច្ចាធារណ៍ថាអ្នកនិពន្ធជាពលរដ្ឋរបស់ប្រទេសនៃសហភាព វាស្ថិតនៅលើច្បាប់នៃប្រទេសនោះក្នុងការចាត់តាំងអាជ្ញាធរមានសមត្ថកិច្ចឱ្យតំណាងអ្នកនិពន្ធ ហើយមានសិទ្ធិការពារនិងអនុវត្តសិទ្ធិអ្នកនិពន្ធក្នុងប្រទេសនៃសហភាព។

(ខ) ប្រទេសទាំងឡាយនៃសហភាព ដែលធ្វើការចាត់តាំងក្រោមលក្ខខណ្ឌនៃបទប្បញ្ញត្តិនេះ ត្រូវជូនដំណឹងទៅអគ្គនាយកតាមរយៈសេចក្តីប្រកាសលាយលក្ខណ៍អក្សរ ដែលផ្តល់ព័ត៌មានគ្រប់គ្រាន់ទាក់ទងនឹងអាជ្ញាធរដែលបានចាត់តាំងនេះ។ អគ្គនាយក ត្រូវផ្សព្វផ្សាយសេចក្តីប្រកាសនេះភ្លាមទៅកាន់ប្រទេសផ្សេងទៀតទាំងអស់នៃសហភាព។

## មាត្រា១៦

### ការថតចម្លងដោយរំលោភបំពាន : ១- ការរឹបអូស ២- ការរឹបអូសចំពោះការនាំចូល ៣- ច្បាប់ដែលត្រូវអនុវត្ត

(១) ការថតចម្លងដោយរំលោភបំពាននៃស្នាដៃមួយ អាចត្រូវបានរឹបអូសក្នុងប្រទេសណាមួយនៃសហភាព នៅពេលដែលស្នាដៃទទួលបានកិច្ចការពារស្របច្បាប់។

(២) បទប្បញ្ញត្តិនៃកថាខណ្ឌខាងលើ ត្រូវអនុវត្តផងដែរចំពោះការផលិតឡើងវិញ នូវស្នាដៃមកពីប្រទេសដែលស្នាដៃនោះមិនត្រូវទទួលបានកិច្ចការពារ ឬកិច្ចការពារត្រូវបានបញ្ចប់។

(៣) ការរឹបអូសត្រូវធ្វើឡើងតាមច្បាប់នៃប្រទេសនីមួយៗ។

## មាត្រា១៧

### លទ្ធភាពក្នុងការត្រួតពិនិត្យលើការធ្វើចរាចរណ៍ ការបង្ហាញ និងការតាំងពិព័រណ៍ស្នាដៃ

បទប្បញ្ញត្តិនៃអនុសញ្ញានេះ មិនអាចធ្វើឱ្យប៉ះពាល់ដល់សិទ្ធិរបស់រដ្ឋាភិបាលនៃប្រទេសនីមួយៗនៃសហភាព តាមច្បាប់ឬបទបញ្ជាក្នុងការអនុញ្ញាត ត្រួតពិនិត្យ ឬហាមឃាត់ចំពោះចរាចរណ៍ ការបង្ហាញឬការតាំងពិព័រណ៍នូវស្នាដៃ ឬផលិតផលណាមួយដែលអាជ្ញាធរមានសមត្ថកិច្ចយល់ឃើញថាចាំបាច់ក្នុងការអនុវត្តសិទ្ធិនេះ។

## មាត្រា១៨

## ស្នាដៃពេលដែលអនុសញ្ញាចូលជាធរមាន : ១- អាចការពារបាននៅពេលដែលកិច្ចការពារមិនទាន់ផុតអាជ្ញាយុកាលក្នុងប្រទេសដើម ២- មិនអាចការពារបាននៅពេលដែលកិច្ចការពារបានផុតអាជ្ញាយុកាលនៅក្នុងប្រទេសដែលអះអាងឲ្យការពារ ៣- ការអនុវត្តគោលការណ៍ទាំងនេះ ៤- ករណីពិសេស

(១) នៅពេលដែលអនុសញ្ញាចូលជាធរមាន អនុសញ្ញានេះត្រូវអនុវត្តទៅលើគ្រប់ស្នាដៃទាំងអស់ដែលមិនទាន់បានដាក់ជាទ្រព្យសម្បត្តិសាធារណជនក្នុងប្រទេសដើម តាមរយៈការផុតកំណត់កិច្ចការពារ។

(២) ប៉ុន្តែតាមរយៈការផុតកំណត់នៃកិច្ចការពារដែលបានផ្ដល់ឱ្យពីមុន ប្រសិនបើស្នាដៃដែលបានដាក់ជាទ្រព្យសម្បត្តិសាធារណជននៅក្នុងប្រទេសដែលបានអះអាងឱ្យការពារ ស្នាដៃនោះនឹងមិនទទួលបានកិច្ចការពារសាជាថ្មីទេ។

(៣) ការអនុវត្តគោលការណ៍នេះ នឹងត្រូវធ្វើឡើងស្របតាមបទប្បញ្ញត្តិណាមួយ ដែលមានក្នុងអនុសញ្ញាពិសេសដែលមានស្រាប់ឬអនុសញ្ញាដែលនឹងធ្វើឡើងរវាងប្រទេសនានានៃសហភាព។ ក្នុងករណីគ្មានបទប្បញ្ញត្តិនេះទេ ប្រទេសនីមួយៗត្រូវកំណត់ពីលក្ខខណ្ឌរៀងៗខ្លួនដើម្បីការអនុវត្តគោលការណ៍នេះ។

(៤) បទប្បញ្ញត្តិខាងលើក៏ត្រូវយកមកអនុវត្តផងដែរក្នុងករណី ដែលមានការចូលជាសមាជិកថ្មីនៃសហភាព និងចំពោះករណីដែលកិច្ចការពារត្រូវពង្រីកវិសាលភាពតាមការអនុវត្តមាត្រា៧ឬតាមរយៈការបោះបង់ចោលខរក្សាសិទ្ធិ។

## មាត្រា១៩

## កិច្ចការពារដែលប្រសើរជាងការផ្ដល់ដោយអនុសញ្ញា

ការផ្ដល់អត្ថប្រយោជន៍នៃកិច្ចការពារណាមួយ ដោយច្បាប់របស់ប្រទេសណាមួយនៃសហភាព ដែលមានលក្ខណៈប្រសើរជាងបទប្បញ្ញត្តិនៃអនុសញ្ញានេះ គឺមិនត្រូវបានហាមឃាត់ឡើយ។

## មាត្រា២០

## កិច្ចព្រមព្រៀងពិសេសរវាងបណ្ដាប្រទេសជាសមាជិកសហភាព]

រដ្ឋាភិបាលរបស់ប្រទេសទាំងឡាយនៃសហភាព រក្សាសិទ្ធិដើម្បីចុះកិច្ចព្រមព្រៀងពិសេសរវាងគ្នា លុះត្រាតែកិច្ចព្រមព្រៀងនោះផ្ដល់ឱ្យអ្នកនិពន្ធនូវសិទ្ធិច្រើនជាងសិទ្ធិដែលបាន ផ្ដល់ឱ្យដោយអនុសញ្ញាឬមានបទប្បញ្ញត្តិផ្សេងទៀតដែលមិនផ្ទុយនឹងអនុសញ្ញានេះ។ បទប្បញ្ញត្តិនៃកិច្ចព្រមព្រៀងមានស្រាប់ដែលបំពេញលក្ខខណ្ឌទាំងនេះនៅតែត្រូវអនុវត្តបាន។

## មាត្រា២១

## បទប្បញ្ញត្តិពិសេសទាក់ទងនឹងប្រទេសកំពុងអភិវឌ្ឍ : ១- ការយោងលើច្បាប់បន្ថែម ២- ផ្នែកបន្ថែមនៃច្បាប់

(១) បទប្បញ្ញត្តិពិសេសទាក់ទងនឹងប្រទេសកំពុងអភិវឌ្ឍ ត្រូវបានបញ្ចូលក្នុងច្បាប់បន្ថែម។

(២) លើកលែងតែបទប្បញ្ញត្តិនៃមាត្រា២៨(១)(ខ) ច្បាប់បន្ថែមជាផ្នែកនៃច្បាប់នេះ។

## មាត្រា២២

## សន្និបាត : ១- ការបង្កើតនិងសមាសភាព ២- មុខងារ ៣- កូរ៉ុម ការបោះឆ្នោត អ្នកសង្កេតការណ៍ ៤- ការកោះប្រជុំ ៥- បទបញ្ជាផ្ទៃក្នុង

(១)

(ក) សហភាពត្រូវមានសន្និបាតមួយដែលរួមមានប្រទេសនៃសហភាពដែលចងភ្ជាប់ដោយមាត្រា ២២ ដល់មាត្រា២៦។

(ខ) រដ្ឋាភិបាលនៃប្រទេសនីមួយៗ ត្រូវមានតំណាងដោយប្រតិភូ១(មួយ)រូបដែលអាចអមដោយ តំណាងជំនួស ទីប្រឹក្សា និងអ្នកជំនាញមួយចំនួន។

(គ) ការចំណាយរបស់គណៈប្រតិភូនីមួយៗ ជាបន្ទុករបស់រដ្ឋាភិបាលដែលតែងតាំងគណៈប្រតិភូនេះ។

(២)

(ក) សន្និបាតត្រូវ៖

(i) ដោះស្រាយរាល់បញ្ហាទាំងអស់ដែលទាក់ទងនឹងការរក្សានិងការអភិវឌ្ឍនៃសហភាព និងការអនុវត្តអនុសញ្ញានេះ

(ii) ណែនាំអំពីការរៀបចំសន្និសីទកែប្រែជូនការិយាល័យអន្តរជាតិកម្មសិទ្ធិបញ្ញា (តទៅហៅថា"ការិយាល័យអន្តរជាតិ") ដែលបានកំណត់ក្នុងអនុសញ្ញាស្តីពី ការបង្កើតអង្គការ កម្មសិទ្ធិបញ្ញាពិភពលោក(តទៅហៅថា"អង្គការ") ដោយពិចារណារលើមតិយោបល់នៃ ប្រទេសក្នុងសហភាព ដែលមិនបានចងភ្ជាប់ដោយមាត្រា២២ ដល់មាត្រា២៦

(iii) ត្រួតពិនិត្យនិងអនុម័តរបាយការណ៍និងសកម្មភាពដែលទាក់ទងនឹងសហភាពរៀបចំ អគ្គនាយករបស់អង្គការ ហើយផ្តល់ការណែនាំតាមការចាំបាច់ដល់អគ្គនាយកដែល ទាក់ទងនឹងបញ្ហានៃសមត្ថកិច្ចរបស់សហភាព

(iv) បោះឆ្នោតជ្រើសរើសសមាជិកនៃគណៈកម្មាធិការប្រតិបត្តិរបស់សន្និបាត

(v) ពិនិត្យនិងអនុម័តរបាយការណ៍និងសកម្មភាពរបស់គណៈកម្មាធិការប្រតិបត្តិ ហើយផ្តល់ការណែនាំដល់គណៈកម្មាធិការនេះ

(vi) កំណត់កម្មវិធីនិងអនុម័តថវិកាពីរឆ្នាំម្តងនៃសហភាព ហើយអនុម័តការបិទបញ្ជីគណនីចុងក្រោយ

(vii) អនុម័តបទបញ្ញាស្តីពីហិរញ្ញវត្ថុរបស់សហភាព

(viii) បង្កើតគណៈកម្មាធិការជំនាញនិងក្រុមការងារដែលចាំបាច់សម្រាប់ការងាររបស់សហភាព

(ix) កំណត់ប្រទេសដែលមិនមែនជាសមាជិកនៃសហភាព និងអង្គការអន្តររដ្ឋាភិបាល និងអង្គការអន្តរជាតិក្រៅរដ្ឋាភិបាល ត្រូវបានអនុញ្ញាតឱ្យចូលរួមក្នុងកិច្ចប្រជុំក្នុងឋានៈជាអ្នកសង្កេតការណ៍

(x) អនុម័តវិសោធនកម្មមាត្រា២២ ដល់មាត្រា២៦

(xi) ចាត់វិធានការសមស្របផ្សេងទៀត ដើម្បីសម្រេចគោលបំណងរបស់សហភាព

(xii) បំពេញមុខងារផ្សេងទៀត ដែលស្របតាមអនុសញ្ញានេះ

(xiii) អនុវត្តសិទ្ធិដែលប្រគល់ឱ្យដោយអនុសញ្ញាស្តីពីការបង្កើតអង្គការ បើសន្និបាតយល់ព្រម។

(ខ) ចំពោះបញ្ហាដែលពាក់ព័ន្ធនឹងផលប្រយោជន៍របស់សហភាពផ្សេងទៀតដែលគ្រប់គ្រងដោយអង្គការសន្និបាតត្រូវធ្វើការសម្រេច បន្ទាប់ពីបានស្តាប់យោបល់របស់គណៈកម្មាធិការសម្របសម្រួលនៃអង្គការ។

(៣)

(ក) ប្រទេសនីមួយៗជាសមាជិកនៃសន្និបាត មានសំឡេងឆ្នោតតែមួយ។

(ខ) កូរ៉ុមនៃសន្និបាតត្រូវមានចំនួនពាក់កណ្តាលនៃប្រទេសជាសមាជិក។

(គ) ថ្វីបើមានចែងក្នុងបទប្បញ្ញត្តិនៃអនុកថាខណ្ឌ(ខ) ក្នុងសម័យប្រជុំនីមួយៗ ប្រសិនបើចំនួនប្រទេសតំណាងមានតិចជាង១/២(មួយភាគពីរ) ប៉ុន្តែស្មើឬច្រើនជាង១/៣(មួយភាគបី) នៃប្រទេសជាសមាជិកទាំងឡាយនៃសន្និបាត សន្និបាតអាចធ្វើសេចក្តីសម្រេចបាន ប៉ុន្តែសេចក្តីសម្រេចទាំងនេះ ត្រូវយកមកអនុវត្តបានតែក្នុងករណីបានបំពេញលក្ខខណ្ឌកំណត់ដូចខាងក្រោម លើកលែងតែសេចក្តីសម្រេចនោះទាក់ទងនឹងនីតិវិធីរបស់សន្និបាត។ ការិយាល័យអន្តរជាតិត្រូវជូនដំណឹងអំពីសេចក្តីសម្រេចនេះ ទៅប្រទេសសមាជិកសន្និបាតទាំងឡាយដែលអវត្តមាន និងត្រូវបញ្ជូនទៅប្រទេសទាំងនោះឱ្យបោះឆ្នោតជាលាយលក្ខណ៍អក្សរឬបោះឆ្នោតអនុប្បវាទក្នុងរយៈពេល៣(បី)ខែចាប់ពីថ្ងៃជូនដំណឹង។ បើផុតរយៈពេលនេះ ប្រសិនបើចំនួននៃប្រទេសដែលបាន បោះឆ្នោត

ឬបោះឆ្នោតអនុប្បវាទ ស្មើនឹងចំនួនប្រទេសដែលមិនបានចូលរួម សម្រាប់កូរ៉ុមក្នុងសម័យប្រជុំ សេចក្ដីសម្រេចនេះនឹងអាចយកមកអនុវត្តបាន ឱ្យតែបានគ្រប់សម្លេងភាគច្រើនដែលត្រូវការ។

(ឃ) លើកលែងតែបទប្បញ្ញត្តិ នៃមាត្រា២៦(២) សេចក្ដីសម្រេចនៃសន្និបាតត្រូវធ្វើឡើងដោយសំឡេងភាគច្រើន២/៣(ពីរភាគបី) នៃសំឡេងឆ្នោតដែលបានបោះ។

(ង) អនុប្បវាទមិនត្រូវចាត់ទុកជាសំឡេងឆ្នោតទេ។

(ច) ប្រតិភូម្នាក់អាចជាតំណាង និងបោះឆ្នោតបានក្នុងនាមប្រទេសតែមួយគត់។

(ឆ) ប្រទេសទាំងឡាយនៃសហភាព ដែលមិនមែនជាសមាជិកសន្និបាត ត្រូវអនុញ្ញាតឱ្យចូលរួមប្រជុំក្នុងឋានៈជាអ្នកសង្កេតការណ៍។

(៤)

(ក) សន្និបាតត្រូវប្រជុំជាសាមញ្ញរៀងរាល់២(ពីរ)ឆ្នាំម្ដង តាមការកោះប្រជុំរបស់អគ្គនាយក ហើយបើគ្មានករណីពិសេស ត្រូវប្រជុំក្នុងពេលនិងកន្លែងដូចគ្នានឹងមហាសន្និបាតរបស់អង្គការ។

(ខ) តាមសំណើសុំពីគណៈកម្មាធិការប្រតិបត្តិឬពីប្រទេសជាសមាជិកសន្និបាតចំនួន១/៤(មួយភាគបួន) សន្និបាតត្រូវប្រជុំជាវិសាមញ្ញបានតាមការកោះប្រជុំរបស់អគ្គនាយក។

(៥) សន្និបាតត្រូវអនុម័តបទបញ្ជាផ្ទៃក្នុងរបស់ខ្លួន។

## មាត្រា២៣

### គណៈកម្មាធិការប្រតិបត្តិ : ១- ការបង្កើត ២- សមាសភាព ៣- ចំនួនសមាជិក ៤- ការបែងចែកតាមភូមិសាស្ត្រ កិច្ចព្រមព្រៀងពិសេស ៥- អាណត្តិ ការកម្រិតការឈរឈ្មោះឱ្យគេបោះឆ្នោតសាជាថ្មី វិធាននៃការបោះឆ្នោត ៦- មុខងារ ៧- ការកោះប្រជុំ ៨- កូរ៉ុម ការបោះឆ្នោត ៩- អ្នកសង្កេតការណ៍ ១០- បទបញ្ជាផ្ទៃក្នុង

(១) សន្និបាតត្រូវមានគណៈកម្មាធិការប្រតិបត្តិមួយ។

(២)

(ក) គណៈកម្មាធិការប្រតិបត្តិ ត្រូវមានសមាជិកជាប្រទេសដែលបានជ្រើសតាំងដោយសន្និបាតក្នុងចំណោមប្រទេសជាសមាជិកទាំងឡាយនៃសន្និបាត។ ជាងនេះទៅទៀត ប្រទេសដែលតាំងទីស្នាក់ការរបស់អង្គការ លើកលែងតែបទប្បញ្ញត្តិមាត្រា២៥(៧)(ខ) ត្រូវមានអាសនៈមួយជាស្វ័យប្រវត្តិក្នុងគណៈកម្មាធិការនេះ។

(ខ) រដ្ឋាភិបាលនៃប្រទេសនីមួយៗនៃគណៈកម្មាធិការប្រតិបត្តិ ត្រូវបានតំណាងដោយប្រតិភូមួយរូបដែលអាចអមដោយតំណាងជំនួស ទីប្រឹក្សា និងអ្នកជំនាញមួយចំនួន។

(គ) ការចំណាយរបស់គណៈប្រតិភូនីមួយៗ ជាបន្ទុករបស់រដ្ឋាភិបាលដែលតែងតាំងគណៈប្រតិភូនេះ។

(៣) ចំនួនប្រទេសជាសមាជិកនៃគណៈកម្មាធិការប្រតិបត្តិ ត្រូវស្មើនឹងចំនួន១/៤(មួយភាគបួន) នៃចំនួនប្រទេសជាសមាជិកសន្និបាត។ ក្នុងការកំណត់ចំនួនអាសនៈដែលត្រូវបំពេញ អាសនៈដែលនៅសល់ពីការបែងចែកជាបួនហើយ នឹងត្រូវបដិសេធចោល។

(៤) ក្នុងការជ្រើសតាំងសមាជិកនៃគណៈកម្មាធិការប្រតិបត្តិ សន្និបាតត្រូវពិចារណាលើការបែងចែកតាមភូមិសាស្ត្រឱ្យបានសមធម៌ និងពិចារណាលើភាពចាំបាច់នៃប្រទេសដែលជាភាគីនៃកិច្ចព្រមព្រៀងពិសេសដែលនឹងត្រូវបង្កើតក្នុងទំនាក់ទំនងជាមួយសហភាព ដើម្បីឱ្យក្លាយជាប្រទេសដែលបង្កើតគណៈកម្មាធិការប្រតិបត្តិផងដែរ។

(៥)

(ក) សមាជិកនីមួយៗនៃគណៈកម្មាធិការប្រតិបត្តិ ត្រូវចូលបម្រើការចាប់ពីពេលបិទសម័យប្រជុំសន្និបាតដែលបានជ្រើសតាំងខ្លួន រហូតដល់ពេលបិទការប្រជុំសាមញ្ញលើកក្រោយនៃសន្និបាត។

(ខ) សមាជិកនៃគណៈកម្មាធិការប្រតិបត្តិ អាចឈរឈ្មោះឱ្យគេបោះឆ្នោតជាថ្មីបាន ប៉ុន្តែមិនអាចលើសពី២/៣ (ពីរភាគបី) នៃសមាជិកគណៈកម្មាធិការប្រតិបត្តិឡើយ។

(គ) សន្និបាតត្រូវបង្កើតបែបបទលម្អិតនៃច្បាប់គ្រប់គ្រងការបោះឆ្នោត និងបែបបទនៃការបោះឆ្នោតសារជាថ្មីរបស់សមាជិកគណៈកម្មាធិការប្រតិបត្តិ។

(៦)

(ក) គណៈកម្មាធិការប្រតិបត្តិត្រូវៈ

i. រៀបចំសេចក្តីព្រាងរបៀបវារៈរបស់សន្និបាត
ii. ដាក់ជូនសន្និបាតនូវសំណើដែលទាក់ទងទៅនឹងសេចក្តីព្រាងកម្មវិធីនិងថវិកាពីរឆ្នាំម្តងរបស់សហភាពដែលរៀបចំដោយអគ្គនាយក
iii. [លុបចោល]
iv. ដាក់ជូនសន្និបាត ដោយរួមជាមួយយោបល់សមរម្យនូវរបាយការណ៍របស់អគ្គនាយក និងរបាយការណ៍សវនកម្មគណនីប្រចាំឆ្នាំឬ
v. ចាត់វិធានការចាំបាច់ដើម្បីធានាការអនុវត្តកម្មវិធីរបស់សហភាពតាមរយៈអគ្គនាយក ដោយយោងតាមសេចក្តីសម្រេចរបស់សន្និបាត និងយោងតាមកាលៈទេសៈដែលកើតមានឡើងចន្លោះសម័យប្រជុំសាមញ្ញទាំងពីររបស់សន្និបាត
vi. អនុវត្តតួនាទីផ្សេងៗទៀតដែលបានផ្តល់ឱ្យដោយអនុសញ្ញានេះ។

(ខ) ចំពោះបញ្ហាដែលពាក់ព័ន្ធផងដែរនឹងផលប្រយោជន៍របស់សហភាពផ្សេងៗដែលគ្រប់គ្រងដោយអង្គការ គណៈកម្មាធិការប្រតិបត្តិត្រូវធ្វើការសម្រេចបន្ទាប់ពីបានស្តាប់យោបល់របស់គណៈកម្មាធិការសម្របសម្រួលនៃអង្គការ។

(៧)

(ក) គណៈកម្មាធិការប្រតិបត្តិ ត្រូវប្រជុំជាសាមញ្ញរៀងរាល់ពីរឆ្នាំម្តងតាមការកោះប្រជុំរបស់អគ្គនាយក ហើយបើអាចធ្វើទៅបាន ត្រូវប្រជុំក្នុងពេលនិងកន្លែងដូចគ្នានឹងគណៈកម្មាធិការសម្របសម្រួលនៃអង្គការ។

(ខ) តាមគំនិតផ្តួចផ្តើមរបស់គណៈកម្មាធិការប្រតិបត្តិ ឬតាមសំណើររបស់អគ្គនាយក ឬរបស់សមាជិក១/៤ (មួយភាគបួន) គណៈកម្មាធិការប្រតិបត្តិត្រូវប្រជុំជាវិសាមញ្ញបានតាមការកោះប្រជុំរបស់អគ្គនាយក។

(៨)

(ក) ប្រទេសនីមួយៗជាសមាជិកនៃគណៈកម្មាធិការប្រតិបត្តិ មានសំឡេងឆ្នោតតែមួយ។

(ខ) កូរ៉ុមនៃគណៈកម្មាធិការប្រតិបត្តិ ត្រូវមានចំនួនពាក់កណ្តាលនៃសមាជិកគណៈកម្មាធិការប្រតិបត្តិ។

(គ) សេចក្តីសម្រេច ត្រូវធ្វើឡើងដោយសំឡេងភាគច្រើន ធម្មតានៃសំឡេងឆ្នោតដែលបានបោះ។

(ឃ) អនុប្បវាទមិនត្រូវចាត់ទុកជាសំឡេងឆ្នោតទេ។

(ង) ប្រតិភូម្នាក់អាចជាតំណាង ហើយបោះឆ្នោតបានក្នុងនាមប្រទេសតែមួយគត់។

(៩) ប្រទេសទាំងឡាយនៃសហភាព ដែលមិនមែនជាសមាជិកគណៈកម្មាធិការប្រតិបត្តិ ត្រូវអនុញ្ញាតឱ្យចូលរួមប្រជុំក្នុងឋានៈជាអ្នកសង្កេតការណ៍។

(១០) គណៈកម្មាធិការប្រតិបត្តិត្រូវអនុម័តបទបញ្ជាផ្ទៃក្នុងរបស់ខ្លួន។

## មាត្រា២៤

**ការិយាល័យអន្តរជាតិ : ១- មុខងារទូទៅអគ្គនាយក ២- ព័ត៌មានទូទៅ ៣- ទស្សនាវដ្តី ៤- ការផ្តល់ព័ត៌មានទៅប្រទេសទាំងឡាយ ៥- ការសិក្សានិងសេវាកម្ម ៦- ការចូលរួមប្រជុំ ៧- សន្និសីទស្តីពីការកែប្រែ និង ៨- មុខងារផ្សេងៗ**

(១)

(ក) មុខងារខាងរដ្ឋបាលរបស់សហភាព ត្រូវបំពេញដោយការិយាល័យអន្តរជាតិដែលបន្តពីការិយាល័យសហភាព រួមបញ្ចូលជាមួយការិយាល័យសហភាពដែលត្រូវបានបង្កើតដោយអនុសញ្ញាអន្តរជាតិស្តីពីកិច្ចការពារកម្មសិទ្ធិឧស្សាហកម្ម។

(ខ) ជាពិសេស ការិយាល័យអន្តរជាតិ ត្រូវបម្រើការងារជាលេខាធិការដ្ឋានសម្រាប់អង្គភាពនានានៃសហភាព។

(គ) អគ្គនាយកនៃអង្គការ ត្រូវជានាយកប្រតិបត្តិនៃសហភាព និងជាតំណាងសហភាព។

(២) ការិយាល័យអន្តរជាតិ មានតួនាទីប្រមូលផ្តុំនិងផ្សព្វផ្សាយព័ត៌មានពាក់ព័ន្ធនឹងកិច្ចការពារសិទ្ធិអ្នកនិពន្ធ។ ប្រទេសនីមួយៗនៃសហភាពត្រូវធ្វើទំនាក់ទំនងភ្លាមទៅការិយាល័យអន្តរជាតិនូវរាល់ច្បាប់ថ្មី និងអត្ថបទផ្លូវការទាំងឡាយទាក់ទងនឹងកិច្ចការពារសិទ្ធិអ្នកនិពន្ធ។

(៣) ការិយាល័យអន្តរជាតិត្រូវធ្វើការបោះពុម្ពផ្សាយជាប្រចាំខែ។

(៤) បើមានការស្នើសុំ ការិយាល័យអន្តរជាតិត្រូវផ្តល់ដល់ប្រទេសណាមួយនៃសហភាពនូវព័ត៌មានស្តីពីបញ្ហាពាក់ព័ន្ធនឹងកិច្ចការពារសិទ្ធិអ្នកនិពន្ធ។

(៥) ការិយាល័យអន្តរជាតិត្រូវធ្វើការសិក្សានិងត្រូវផ្តល់សេវាកម្មដើម្បីជួយសម្រួលដល់កិច្ចការពារសិទ្ធិអ្នកនិពន្ធ។

(៦) អគ្គនាយកនិងបុគ្គលិកណាម្នាក់ដែលត្រូវចាត់តាំងដោយអគ្គនាយក ត្រូវចូលរួមរាល់កិច្ចប្រជុំសន្និបាត គណៈកម្មាធិការប្រតិបត្តិនិងគណៈកម្មាធិការជំនាញ ឬក្រុមការងារផ្សេងៗទៀត តែគ្មានសិទ្ធិបោះឆ្នោតទេ។ អគ្គនាយកឬបុគ្គលិកណាម្នាក់ដែលត្រូវចាត់តាំងដោយអគ្គនាយក គឺជាលេខាដោយស្វ័យប្រវត្តិរបស់អង្គភាពទាំងនេះ។

(៧)

(ក) តាមសេចក្តីណែនាំរបស់សន្និបាត និងដោយមានកិច្ចសហការប្រតិបត្តិការជាមួយគណៈកម្មាធិការប្រតិបត្តិ ការិយាល័យអន្តរជាតិត្រូវរៀបចំសន្និសីទកែប្រែបទប្បញ្ញត្តិនៃអនុសញ្ញា លើកលែងតែមាត្រា២២ ដល់មាត្រា២៦។

(ខ) ការិយាល័យអន្តរជាតិអាចប្រឹក្សាជាមួយអង្គការអន្តររដ្ឋាភិបាល និងអង្គការអន្តរជាតិមិនមែនរដ្ឋាភិបាលពាក់ព័ន្ធនឹងការរៀបចំសន្និសីទកែប្រែនេះ។

(គ) អគ្គនាយកនិងបុគ្គលដែលត្រូវចាត់តាំងដោយអគ្គនាយក ត្រូវចូលរួមក្នុងកិច្ចពិភាក្សាក្នុងសន្និសីទទាំងនោះតែគ្មានសិទ្ធិបោះឆ្នោតទេ។

(៨) ការិយាល័យអន្តរជាតិត្រូវអនុវត្តមុខងារផ្សេងៗទៀតដែលប្រគល់ឱ្យ។

## មាត្រា២៥

### ហិរញ្ញវត្ថុ : ១- ថវិកា ២- ការសម្របសម្រួលជាមួយសហភាពផ្សេងទៀត ៣- ធនធាន ៤- ការបង់វិភាគទាន លទ្ធភាពបន្តថវិកាចាស់ ៥- ពន្ធអាករនិងប្រាក់កម្រៃ ៦- មូលនិធិទុនបង្វិល ៧- បុរេប្រទានដោយរដ្ឋាភិបាលម្ចាស់ផ្ទះ ៨- សវនកម្មបញ្ជីគណនី

(១)

(ក) សហភាពត្រូវមានថវិការបស់ខ្លួន។

(ខ) ថវិការបស់សហភាពរួមមាន ខ្ទង់ចំណូលនិងខ្ទង់ចំណាយផ្ទាល់របស់សហភាព វិភាគទានចំពោះថវិកាសម្រាប់ការចំណាយរួមរបស់សហភាព និងបើមានចំនួនទឹកប្រាក់ដែលមានក្នុងថវិកាត្រូវប្រើសម្រាប់សន្និសីទរបស់អង្គការ។

(គ) ការចំណាយដែលមិនមែនជាចំណាយផ្តាច់មុខរបស់សហភាព ប៉ុន្តែជាការចំណាយរបស់សហភាពមួយឬច្រើនផ្សេងទៀតដែលស្ថិតក្រោមការគ្រប់គ្រងរបស់អង្គការ ត្រូវចាត់ទុកជាចំណាយរួមរបស់សហភាព។ ចំណែកនៃសហភាពក្នុងខ្ទង់ចំណាយរួមនេះ ត្រូវសមាមាត្រនឹងផលប្រយោជន៍ដែលសហភាពទទួលបានក្នុងចំណាយនោះ។

(២) ថវិការបស់សហភាព ត្រូវបង្កើតឡើងដោយផ្អែកលើតម្រូវការសម្របសម្រួលជាមួយថវិកានៃសហភាពផ្សេងទៀតដែលគ្រប់គ្រងដោយអង្គការ។

(៣) ថវិការបស់សហភាព ទទួលបានពីប្រភពនានាដូចខាងក្រោម៖

i. វិភាគទានពីប្រទេសនានានៃសហភាព
ii. កម្រៃនិងថ្លៃឈ្នួលសេវាកម្មដែលផ្តល់ឱ្យដោយការិយាល័យអន្តរជាតិក្នុងនាមសហភាព
iii. ការលក់ ឬលាភការ ពីការបោះពុម្ពផ្សាយរបស់ការិយាល័យអន្តរជាតិពាក់ព័ន្ធនឹងសហភាព
iv. អំណោយ អច្ច័យទាន និងឧបត្ថម្ភធន
v. ការជួល ការប្រាក់ និងចំណូលផ្សេងៗទៀត។

(៤)

(ក) ដើម្បីបង្កើតជាវិភាគទាននៃថវិកា ប្រទេសនីមួយៗនៃសហភាពត្រូវចាត់ជាចំណាត់ថ្នាក់ ហើយត្រូវបង់វិភាគទានប្រចាំឆ្នាំផ្អែកលើចំនួនឯកតានៃចំណាត់ថ្នាក់ដែលត្រូវកំណត់ដូចខាងក្រោម៖

| | |
|---|---|
| ថ្នាក់ទីI | ២៥ |
| ថ្នាក់ទីII | ២០ |
| ថ្នាក់ទីIII | ១៥ |
| ថ្នាក់ទីIV | ១០ |
| ថ្នាក់ទីV | ៥ |
| ថ្នាក់ទីVI | ៣ |
| ថ្នាក់ទីVII | ១ |

(ខ) លើកលែងតែបានធ្វើចំណាត់ថ្នាក់រួចហើយ ប្រទេសនីមួយៗត្រូវបញ្ជាក់ពីចំណាត់ថ្នាក់ដែលគេចង់បាននៅពេលតម្កល់លិខិតុបករណ៍នៃការផ្តល់សច្ចាប័នឬការចូលជាសមាជិក។ ប្រទេសនីមួយៗ

អាចប្តូរចំណាត់ថ្នាក់បាន។ ប្រសិនបើប្រទេសណាមួយជ្រើសរើសចំណាត់ថ្នាក់ទាប ប្រទេសនោះត្រូវប្រកាសពីការផ្លាស់ប្តូរនេះក្នុងសម័យប្រជុំសាមញ្ញណាមួយនៃសន្និបាត។ ការផ្លាស់ប្តូរណាមួយ នឹងមានសុពលភាពនៅដើមឆ្នាំប្រតិទិនបន្ទាប់ពីកិច្ចប្រជុំ។

(គ) វិភាគទានប្រចាំឆ្នាំនៃប្រទេសនីមួយៗ ត្រូវមានចំនួនសមាមាត្រទៅនឹងចំនួនសរុបដែលបានធ្វើវិភាគទានទៅថវិកាប្រចាំឆ្នាំរបស់សហភាពដោយប្រទេសទាំងអស់ ដូចនឹងចំនួនឯកតារបស់ខ្លួនទៅចំនួនសរុបនៃឯកតានៃប្រទេសផ្តល់វិភាគទានទាំងអស់។

(ឃ) ការបង់វិភាគទានត្រូវធ្វើឡើងនៅថ្ងៃទី១ ខែមករា ជារៀងរាល់ឆ្នាំ។

(ង) ប្រទេសដែលយឺតយ៉ាវក្នុងការបង់វិភាគទាន មិនអាចអនុវត្តសិទ្ធិបោះឆ្នោតរបស់ខ្លួនក្នុងអង្គភាពនៃសហភាពដែលខ្លួនជាសមាជិក ប្រសិនបើចំនួនដែលមិនបានបង់មានចំនួនស្មើឬលើសពីចំនួននៃវិភាគទានត្រូវបង់ចំនួន២(ពីរ)ឆ្នាំពេញ។ ប៉ុន្តែអង្គភាពណាមួយនៃសហភាព អាចអនុញ្ញាតឱ្យប្រទេសដែលយឺតយ៉ាវក្នុងការបង់វិភាគទានអាចបន្តអនុវត្តសិទ្ធិបោះឆ្នោតក្នុងអង្គភាពនោះបាន ដរាបណាបានផ្តល់ហេតុផលត្រឹមត្រូវពីការយឺតយ៉ាវក្នុងការបង់វិភាគទាន ដោយមានកាលៈទេសៈពិសេសនិងមិនអាចជៀសវាងបាន។

(ច) ប្រសិនបើថវិកាមិនត្រូវបានអនុម័តមុនការចាប់ផ្តើមនៃរយៈពេលហិរញ្ញវត្ថុថ្មីទេ ថវិកានោះត្រូវចាត់ទុកថាមានកម្រិតស្មើគ្នាទៅនឹងថវិកាឆ្នាំមុន ដូចមានចែងក្នុងបទបញ្ញាហិរញ្ញវត្ថុ។

(៥) បរិមាណនៃកម្រៃនិងថ្លៃឈ្នួលសេវាកម្មដែលផ្តល់ឱ្យដោយការិយាល័យអន្តរជាតិក្នុងនាមសហភាពនឹងត្រូវកំណត់ និងត្រូវរាយការណ៍ទៅសន្និបាត និងគណៈកម្មាធិការប្រតិបត្តិដោយអគ្គនាយក។

(៦)

(ក) សហភាពត្រូវមានមូលនិធិទុនបង្វិលដែលទទួលបានពីការបង់ប្រាក់សរុបរួមតែមួយពីប្រទេសនីមួយៗនៃសហភាព។ ប្រសិនបើមូលនិធិនេះមិនគ្រប់គ្រាន់ សន្និបាតអាចសម្រេចបង្កើតមូលនិធិបន្ថែមបាន។

(ខ) ចំនួននៃការបង់ប្រាក់ដំបូង របស់ប្រទេសនីមួយៗក្នុងមូលនិធិនេះឬនៃការចូលរួមរបស់ខ្លួនក្នុងការបង្កើតមូលនិធិ ត្រូវសមាមាត្រនឹងវិភាគទាននៃប្រទេសនោះសម្រាប់ឆ្នាំនៃការបង្កើតមូលនិធិនេះឬឆ្នាំនៃការសម្រេចការបង្កើតមូលនិធិបន្ថែម។

(គ) សមាមាត្រនិងលក្ខខណ្ឌនៃការបង់ប្រាក់ ត្រូវកំណត់ដោយសន្និបាតតាមសំណើរបស់អគ្គនាយកនិងបន្ទាប់ពីការស្តាប់យោបល់របស់គណៈកម្មាធិការសម្របសម្រួលនៃអង្គការ។

(៧)

(ក) នៅក្នុងទីស្នាក់ការកណ្តាល កិច្ចព្រមព្រៀងដែលបានចុះជាមួយប្រទេសដែលអង្គការដាក់ទីស្នាក់ការកណ្តាលនៅលើទឹកដីប្រទេសនោះ ដោយមានចែងថានៅពេលណាដែលមូលនិធិទុនបង្វិលមិនគ្រប់គ្រាន់ ប្រទេសនោះត្រូវបង់ប្រាក់ជាមុន។ ចំនួននៃប្រាក់បង់ជាមុននិងលក្ខខណ្ឌនៃការបង់ជាមុន ត្រូវកំណត់ដោយកិច្ច

ព្រមព្រៀងដោយឡែកពីគ្នារវាងប្រទេសនោះជាមួយអង្គការ។ ដរាបណាប្រទេសនោះនៅតែមានកាតព្វកិច្ចបង់ប្រាក់ជាមុន ប្រទេសនោះត្រូវមានអាសនៈជាស្វ័យប្រវត្តិក្នុងគណៈកម្មាធិការប្រតិបត្តិ។

(ខ) ប្រទេសដូចមានចែងក្នុងអនុកថាខណ្ឌ(ក) និងអង្គការមានសិទ្ធិបដិសេធកាតព្វកិច្ចបង់ប្រាក់ជាមុនដោយមានការជូនដំណឹងជាលាយលក្ខណ៍អក្សរ។ ការបដិសេធនេះត្រូវមានអានុភាពក្នុងរយៈពេល៣(បី)ឆ្នាំបន្ទាប់ពីដំណាច់ឆ្នាំនៃការជូនដំណឹង។

(៨) សវនកម្មគណនី ត្រូវធ្វើឡើងដោយប្រទេសមួយឬច្រើននៃសហភាព ឬដោយសវនករខាងក្រៅដូចមានចែងក្នុងបទបញ្ជាហិរញ្ញវត្ថុ ហើយត្រូវចាត់តាំងដោយសន្និបាតដោយមានការយល់ព្រមពីប្រទេសឬសវនករនេះ។

## មាត្រា២៦

### វិសោធនកម្ម : ១- បទប្បញ្ញត្តិដែលអាចធ្វើវិសោធនកម្មដោយសន្និបាត ការស្នើសុំ ២- ការអនុម័ត ៣- ការចូលជាធរមាន

(១) សំណើសុំវិសោធនកម្មចំពោះមាត្រា២២ មាត្រា២៣ មាត្រា២៤ មាត្រា២៥ និងមាត្រានេះ អាចត្រូវផ្តួចផ្តើមគំនិតដោយប្រទេសសមាជិកណាមួយនៃសន្និបាត ដោយគណៈកម្មាធិការប្រតិបត្តិ ឬដោយអគ្គនាយក។ សំណើនេះត្រូវជូនដំណឹងដោយអគ្គនាយកទៅកាន់ប្រទេសជាសមាជិកសន្និបាត យ៉ាងហោចណាស់រយៈពេល៦ (ប្រាំមួយ)ខែមុនពេលសន្និបាតលើកសំណើរនេះមកពិចារណា។

(២) វិសោធនកម្មចំពោះមាត្រាតាមកថាខណ្ឌ(១)ត្រូវអនុម័តដោយសន្និបាត។ ការអនុម័តនេះទាមទារឱ្យ មានសម្លេងឆ្នោត៣/៤(បីភាគបួន) តែវិសោធនកម្មចំពោះមាត្រា២២ និងកថាខណ្ឌនេះទាមទារឱ្យមានសំឡេងឆ្នោត ៤/៥ (បួនភាគប្រាំ)។

(៣) វិសោធនកម្មណាមួយចំពោះមាត្រាក្នុងកថាខណ្ឌ(១) ត្រូវចូលជាធរមានក្នុងរយៈពេល១(មួយ)ខែក្រោយពីអគ្គនាយកទទួលបានសេចក្តីជូនដំណឹងទទួលយកជាលាយលក្ខណអក្សរ ដែលបានធ្វើឡើងស្របតាមរដ្ឋធម្មនុញ្ញ ដោយប្រទេស៣/៤(បីភាគបួន) ដែលជាសមាជិកនៃសន្និបាតនេះ មានវត្តមាននៅពេលអនុម័តវិសោធនកម្មនេះ។ វិសោធនកម្មចំពោះមាត្រាទាំងនេះ ហើយប្រសិនបើត្រូវបានទទួលយក មានអានុភាពចងភ្ជាប់ប្រទេសទាំងឡាយដែលជាសមាជិកសន្និបាតនៅពេលដែលវិសោធនកម្មទាំងនោះចូលជាធរមាន ឬដែលក្លាយជាសមាជិកនាពេលក្រោយ តែវិសោធនកម្មណាដែលបង្កើនកាតព្វកិច្ចហិរញ្ញវត្ថុរបស់ប្រទេសនៃសហភាពមានអានុភាពចងតែប្រទេសណា ដែលប្រកាសយល់ព្រមវិសោធនកម្មនេះប៉ុណ្ណោះ។

## មាត្រា២៧

### ការកែប្រែ : ១- គោលបំណង ២- សន្និសីទ ៣- ការអនុម័ត

(១) អនុសញ្ញានេះនឹងដាក់ចេញនូវទស្សនៈទានកែប្រែមួយចំនួន ដែលណែនាំដល់ការធ្វើវិសោធនកម្មដើម្បីឱ្យប្រព័ន្ធនៃសហភាពមានលក្ខណៈកាន់តែប្រសើរឡើង។

(២) សម្រាប់គោលបំណងនេះ សន្និសីទត្រូវប្រារព្ធធ្វើជាបន្តបន្ទាប់ក្នុងប្រទេសណាមួយនៃបណ្ដាប្រទេសនៃសហភាពដោយប្រតិភូនៃប្រទេសទាំងនេះ។

(៣) ជាកម្មវត្ថុនៃបទប្បញ្ញត្តិនៃមាត្រា២៦ ដែលអនុវត្តចំពោះការធ្វើវិសោធនកម្មមាត្រា២២ ដល់មាត្រា២៦ រាល់ការកែប្រែលើច្បាប់នេះរួមទាំងច្បាប់បន្ថែមផង ទាមទារឲ្យមានសំឡេងឆ្នោតជាឯកច្ឆន្ទ។

## មាត្រា២៨

## ការទទួលយក និងការចូលជាធរមាននៃច្បាប់សម្រាប់ប្រទេសនៃសហភាព: ១- ការផ្ដល់សច្ចាប័ន ការចូលជាសមាជិក លទ្ធភាពនៃការមិនអនុវត្តបទប្បញ្ញត្តិមួយចំនួន ការដកការមិនអនុវត្ត ២- ការចូលជាធរមាននៃមាត្រា១ដល់មាត្រា២១ និងច្បាប់បន្ថែម ៣- ការចូលជាធរមាននៃមាត្រា២២ដល់មាត្រា៣៨

(១)

(ក) ប្រទេសណាមួយនៃសហភាពដែលបានចុះហត្ថលេខាលើច្បាប់នេះ អាចផ្ដល់សច្ចាប័នបាន ហើយប្រសិនបើប្រទេសនោះមិនបានចុះហត្ថលេខា អាចចូលជាសមាជិកនៃច្បាប់នេះបាន។ លិខិតុបករណ៍នៃការផ្ដល់សច្ចាប័ន និងការចូលជាសមាជិកត្រូវតម្កល់ជូនអគ្គនាយក។

(ខ) ប្រទេសណាមួយនៃសហភាព អាចប្រកាសនៅក្នុងលិខិតុបករណ៍នៃការផ្ដល់សច្ចាប័ន ឬការចូលជាសមាជិកថា ការផ្ដល់សច្ចាប័នឬការចូលជាសមាជិករបស់ខ្លួន មិនត្រូវអនុវត្តចំពោះមាត្រា១ដល់មាត្រា២១ និងច្បាប់បន្ថែម លុះត្រាតែប្រទេសនោះបានធ្វើសេចក្ដីប្រកាសរួចហើយក្រោមមាត្រា៦(១)នៃច្បាប់បន្ថែម ទើបប្រទេសនោះអាចប្រកាសក្នុងលិខិតុបករណ៍ខាងលើថា ការផ្ដល់សច្ចាប័នឬចូលជាសមាជិករបស់ខ្លួនមិនអនុវត្តចំពោះមាត្រា១ដល់មាត្រា២០។

(គ) ប្រទេសណាមួយនៃសហភាព ដែលបានដកអនុភាពចេញពីការផ្ដល់សច្ចាប័នឬការចូលជាសមាជិកនូវបទប្បញ្ញត្តិដែលបានចែងក្នុងអនុកថាខណ្ឌ(ខ)នាពេលក្រោយណាមួយ អាចប្រកាសទទួលយកអានុភាពនៃការផ្ដល់សច្ចាប័នឬការចូលជាសមាជិករបស់បទប្បញ្ញត្តិទាំងនោះវិញបាន។ សេចក្ដីប្រកាសនេះត្រូវតម្កល់ជូនអគ្គនាយក។

(២)

(ក) មាត្រា១ដល់មាត្រា២១និងច្បាប់បន្ថែម នឹងចូលជាធរមានក្នុងរយៈពេល៣(បី)ខែបន្ទាប់ពីបានបំពេញលក្ខខណ្ឌទាំងពីរខាងក្រោម ត្រូវបានបំពេញ៖

i. យ៉ាងហោចណាស់ប្រាំប្រទេសនៃសហភាពបានផ្ដល់សច្ចាប័ន ឬបានចូលជាសមាជិកនៃច្បាប់នេះ ដោយមិនបានធ្វើសេចក្ដីប្រកាសតាមកថាខណ្ឌ(១)(ខ)
ii. ប្រទេសបារាំង អេស្ប៉ាញ រាជាណាចក្ររួមចក្រភពអង់គ្លេសនិងអៀរឡង់ខាងជើង និងសហរដ្ឋអាមេរិក បានចងភ្ជាប់ដោយអនុសញ្ញាជាសាកលស្ដីពីសិទ្ធិអ្នកនិពន្ធ ដូចបានកែប្រែនៅទីក្រុងប៉ារីស ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ១៩៧១។

(ខ) ការចូលជាធរមាននៃអនុកថាខណ្ឌ(ក) ត្រូវអនុវត្តចំពោះបណ្តាប្រទេសទាំងឡាយនៃសហភាពដែលបានផ្តល់លិខិតុបករណ៍នៃការផ្តល់សច្ចាប័នឬក៏ការចូលជាសមាជិកដែលគ្មានសេចក្តីប្រកាសក្រោមកថាខណ្ឌ(១)(ខ) យ៉ាងហោចណាស់រយៈពេល៣(បី)ខែមុនការចូលជាធរមាននេះ។

(គ) ចំពោះប្រទេសណាមួយនៃសហភាពដែលពុំមានចែងក្នុងអនុកថាខណ្ឌ(ខ)ហើយបានផ្តល់សច្ចាប័ន ឬចូលជាសមាជិកនៃច្បាប់នេះដោយពុំបានធ្វើសេចក្តីប្រកាសតាមកថាខណ្ឌ(១)(ខ) មាត្រា១ដល់មាត្រា២១ និង ច្បាប់បន្ថែមត្រូវចូលជាធរមានក្នុងរយៈពេល៣(បី)ខែ បន្ទាប់ពីកាលបរិច្ឆេទដែលអគ្គនាយកបានជូនដំណឹងពីការតម្កល់លិខិតុបករណ៍នៃការផ្តល់សច្ចាប័នឬការចូលជាសមាជិកដែលពាក់ព័ន្ធ លើកលែងតែកាលបរិច្ឆេទបន្ទាប់មិនបានបង្ហាញក្នុងលិខិតុបករណ៍ដែលបានតម្កល់។ ក្នុងករណីក្រោយនេះ មាត្រា១ដល់២១ និងច្បាប់បន្ថែមត្រូវចូលជាធរមានចំពោះប្រទេសនោះតាមកាលបរិច្ឆេទដែលបានកំណត់។

(ឃ) បទប្បញ្ញត្តិនៃអនុកថាខណ្ឌ(ក)ដល់(គ) មិនប៉ះពាល់ដល់ការអនុវត្តមាត្រា៦នៃច្បាប់បន្ថែមទេ។

(៣) ចំពោះប្រទេសទាំងឡាយនៃសហភាព ដែលផ្តល់សច្ចាប័ន ឬចូលជាសមាជិកនៃច្បាប់នេះដោយបានឬពុំបានធ្វើសេចក្តីប្រកាសតាមកថាខណ្ឌ(១)(ខ) មាត្រា២២ដល់៣៨ ត្រូវចូលជាធរមានក្នុងរយៈពេល៣(បី)ខែបន្ទាប់ពីកាលបរិច្ឆេទដែលអគ្គនាយកបានជូនដំណឹងពីការតម្កល់លិខិតុបករណ៍ នៃការផ្តល់សច្ចាប័ន ឬការចូលជាសមាជិកដែលពាក់ព័ន្ធ លើកលែងតែកាលបរិច្ឆេទបន្ទាប់មិនបានបង្ហាញក្នុងលិខិតុបករណ៍ដែលបានតម្កល់។ ក្នុងករណីក្រោយនេះ មាត្រា២២ដល់៣៨ ត្រូវចូលជាធរមានចំពោះប្រទេសនោះតាមកាលបរិច្ឆេទដែលបានកំណត់។

## មាត្រា២៩

## ការទទួលយកនិងការចូលជាធរមានសម្រាប់ប្រទេសក្រៅសហភាព :
## ១- ការចូលជាសមាជិក ២- ការចូលជាធរមាន

(១) ប្រទេសក្រៅសហភាពណាមួយ អាចចូលជាសមាជិកនៃច្បាប់នេះ ហើយបន្ទាប់មកក្លាយជាភាគីនៃអនុសញ្ញានេះ ហើយនិងក្លាយជាសមាជិកនៃសហភាព។ លិខិតុបករណ៍នៃការចូលជាសមាជិក ត្រូវតម្កល់ជូនអគ្គនាយក។

(២)

(ក) ជាកម្មវត្ថុអនុកថាខណ្ឌ(ខ) អនុញ្ញានេះត្រូវចូលជាធរមានចំពោះប្រទេសក្រៅសហភាពណាមួយ ក្នុងរយៈពេល៣(បី)ខែបន្ទាប់ពីកាលបរិច្ឆេទ ដែលអគ្គនាយកបានជូនដំណឹងពីការតម្កល់លិខិតុបករណ៍នៃការចូលជាសមាជិក លើកលែងតែកាលបរិច្ឆេទបន្ទាប់មិនបានបង្ហាញក្នុងលិខិតុបករណ៍ដែលបានតម្កល់។ ក្នុងករណីចុងក្រោយនេះ អនុសញ្ញានេះត្រូវចូលជាធរមានចំពោះប្រទេសនោះ តាមកាលបរិច្ឆេទដែលបានកំណត់។

(ខ) ប្រសិនបើការចូលជាធរមានតាមអនុកថាខណ្ឌ(ក) មានមុនការចូលជាធរមាននៃមាត្រា១ដល់២១ និងមុនការចូលជាធរមាននៃច្បាប់បន្ថែមតាមមាត្រា២៨(២)(ក) ក្នុងចន្លោះពេលនេះ ប្រទេសខាងលើត្រូវចងភ្ជាប់ដោយមាត្រា១ដល់២០នៃច្បាប់ព្រុចសែលរបស់អនុសញ្ញានេះ ជំនួសមាត្រា១ដល់២១និងជំនួសច្បាប់បន្ថែម។

## មាត្រា២៩(ស្ទួន)

## អានុភាពនៃការទទួលយកច្បាប់ក្នុងគោលបំណងនៃមាត្រា១៤(២) នៃអនុសញ្ញាអង្គការកម្មសិទ្ធិបញ្ញាពិភពលោក

ការផ្តល់សច្ចាប័ននិងការចូលជាសមាជិកនៃច្បាប់នេះរបស់ប្រទេសណាមួយ ដែលមិនចងភ្ជាប់ដោយមាត្រា២២ដល់មាត្រា៣៨នៃច្បាប់ទីក្រុងស្តុកខុលរបស់អនុសញ្ញានេះ សម្រាប់តែក្នុងបំណងអនុវត្តមាត្រា១៤(២)នៃអនុសញ្ញាដែលបង្កើតអង្គការ មានតម្លៃជាសច្ចាប័នឬការចូលជាសមាជិកនៃច្បាប់ទីក្រុងស្តុកខុលនេះ ជាមួយនឹងការកម្រិតតាមមាត្រា២៨(១)(ខ)(i)នៃច្បាប់នេះ។

## មាត្រា៣០

## ខរក្សាសិទ្ធិ : ១- ការកម្រិតលទ្ធភាពនៃការដាក់ខរក្សាសិទ្ធិ ២- ខរក្សាសិទ្ធិលើកមុន ខរក្សាសិទ្ធិចំពោះសិទ្ធិបកប្រែ ការដកខរក្សាសិទ្ធិ

(១) ជាកម្មវត្ថុនៃអញ្ញត្រកម្មតាមកថាខណ្ឌ(២)នៃមាត្រានេះ តាមមាត្រា២៨(១)(ខ) តាមមាត្រា៣៣(២) និងតាមច្បាប់បន្ថែម ការផ្តល់សច្ចាប័ននិងការចូលជាសមាជិកតម្រូវឲ្យមានការទទួលស្គាល់ជាស្វ័យប្រវត្តិ ចំពោះបទប្បញ្ញត្តិនិងផលប្រយោជន៍ទាំងអស់នៃអនុសញ្ញានេះ។

(២)

(ក) ជាកម្មវត្ថុនៃមាត្រា៥(២)នៃច្បាប់បន្ថែម ប្រទេសណាមួយនៃសហភាពដែលបានផ្តល់សច្ចាប័នឬចូលជាសមាជិកនៃច្បាប់នេះ អាចរក្សាទុកនូវផលប្រយោជន៍នៃខរក្សាសិទ្ធិដែលខ្លួនបានធ្វើពីមុន ក្នុងលក្ខខណ្ឌដែលប្រទេសនេះធ្វើសេចក្តីប្រកាសនៅពេលតម្កល់លិខិតុបករណ៍នៃការផ្តល់សច្ចាប័នឬការចូលជាសមាជិក។

(ខ) ពេលចូលជាសមាជិកនៃអនុសញ្ញានេះ និងជាកម្មវត្ថុនៃមាត្រា៥(២)នៃច្បាប់បន្ថែម ប្រទេសក្រៅសហភាពណាមួយអាចប្រកាសថាខ្លួនមានបំណងជំនួស ជាបណ្តោះអាសន្នក៏ដោយនូវមាត្រា៨នៃច្បាប់ស្តីពីសិទ្ធិបកប្រែ នឹងបទប្បញ្ញត្តិនៃមាត្រា៥នៃអនុសញ្ញាសហភាពឆ្នាំ១៨៨៦ដែលបានបញ្ចប់នៅទីក្រុងប៉ារីសក្នុងឆ្នាំ១៨៩៦ ដោយមានការយល់ច្បាស់ថាបទប្បញ្ញត្តិខាងលើអាចអនុវត្តបានចំពោះតែការបកប្រែជាភាសាដែលគេប្រើប្រាស់ទូទៅក្នុងប្រទេសខាងលើប៉ុណ្ណោះ។ ជាកម្មវត្ថុនៃមាត្រា១(៦)(ខ)នៃច្បាប់បន្ថែម ចំពោះសិទ្ធិបកប្រែស្នាដៃដែលប្រទេសដើមជាប្រទេសមួយដែលប្រើប្រាស់ខរក្សាសិទ្ធិនេះ ប្រទេសណាក៏ដោយមានសិទ្ធិទទួលបានកិច្ចការពារស្មើនឹងកិច្ចការពារដែលប្រទេសដើមបានផ្តល់ឱ្យ។

(គ) ប្រទេសណាមួយអាចដកខរក្សាសិទ្ធិ នៅពេលណាក៏បានតាមការជូនដំណឹងទៅអគ្គនាយក។

## មាត្រា៣១

## ការអនុវត្តនៅលើដែនដីមួយចំនួន : ១- សេចក្តីប្រកាស ២- ការដកសេចក្តីប្រកាស ៣- កាលបរិច្ឆេទអានុភាព ៤- ការទទួលស្គាល់ស្ថានភាពអង្គហេតុដែលមិនបានចែង

(១) ប្រទេសណាមួយ អាចប្រកាសក្នុងលិខិតុបករណ៍នៃការផ្តល់សច្ចាប័ន ឬការចូលជាសមាជិក ឬអាចជូនដំណឹងទៅអគ្គនាយកជាលាយលក្ខណ៍អក្សរនាពេលបន្ទាប់ណាមួយថា អនុសញ្ញានេះអាចអនុវត្តបាន លើគ្រប់ដែនដី ឬដោយផ្នែកនៃដែនដីទាំងនោះដូចដែលមានកំណត់ក្នុងសេចក្តីប្រកាស ឬការជូនដំណឹងចំពោះ ទំនួលខុសត្រូវនៃទំនាក់ទំនងខាងក្រៅរបស់ខ្លួន។

(២) ប្រទេសណាមួយដែលបានធ្វើសេចក្តីប្រកាសឬជូនដំណឹងបែបបនេះ អាចជូនព័ត៌មានទៅអគ្គនាយក នៅពេលណាមួយក៏បានថា អនុសញ្ញានេះលែងយកមកអនុវត្តនៅលើគ្រប់ដែនដី ឬផ្នែកនៃដែនដីទាំងនេះ។

(៣)

(ក) សេចក្តីប្រកាសណាមួយដែលធ្វើតាមកថាខណ្ឌ(១) ត្រូវមានអានុភាពអនុវត្តក្នុងកាលបរិច្ឆេទ ដូចគ្នានឹងកាលបរិច្ឆេទនៃការផ្តល់សច្ចាប័នឬចូលជាសមាជិកដែលបានកំណត់ ហើយការជូនដំណឹងណាមួយ ដែលធ្វើឡើងតាមកថាខណ្ឌនេះ នឹងត្រូវមានអានុភាពអនុវត្តក្នុងរយៈពេល៣(បី)ខែ បន្ទាប់ពីមានការជូនដំណឹង របស់អគ្គនាយក។

(ខ) ការជូនដំណឹងណាមួយតាមកថាខណ្ឌ(២) ត្រូវមានអានុភាពអនុវត្តក្នុងរយៈពេល១២(ដប់ពីរ) ខែ បន្ទាប់ពីអគ្គនាយកបានទទួលការជូនដំណឹងនេះ។

(៤) មាត្រានេះមិនត្រូវយល់ថាជាការទទួលស្គាល់ឬការទទួលដោយតុណ្ហីភាពពីប្រទេសនៃសហភាពនូវ ស្ថានភាពអង្គហេតុទាក់ទងនឹងដែនដីមួយ ដែលអនុសញ្ញានេះយកទៅអនុវត្តដោយប្រទេសមួយទៀតនៃសហភាព ដោយអាស្រ័យតាមសេចក្តីប្រកាសនៃកថាខណ្ឌ(១)។

## មាត្រា៣២

## ការអនុវត្តច្បាប់នេះនិងច្បាប់ដែលមានពីមុនៈ ១- រវាងប្រទេសដែលក្លាយជាសមាជិក នៃសហភាពរួចហើយ ២- រវាងប្រទេសដែលនឹងក្លាយជាសមាជិកនៃសហភាពនិងប្រទេស ដទៃទៀតដែលជាសមាជិកនៃសហភាព ៣- ការអនុវត្តច្បាប់បន្ថែមនៅក្នុងទំនាក់ទំនងមួយចំនួន

(១) ដោយអាស្រ័យលើទំនាក់ទំនងរវាងប្រទេសទាំងឡាយនៃសហភាព និងវិសាលភាពនៃការអនុវត្ត ច្បាប់នេះត្រូវជំនួសអនុសញ្ញាទីក្រុងប៊ែន ចុះថ្ងៃទី៩ ខែកញ្ញា ឆ្នាំ១៨៨៦ និងច្បាប់ដែលបានកែប្រែជាបន្តបន្ទាប់។ ច្បាប់ដែលចូលជាធរមានពីមុនៗត្រូវបន្តអនុវត្ត ទាំងមូលឬក្នុងករណីដែលច្បាប់នេះមិនជំនួសដោយច្បាប់មុនៗ តាមអត្ថន័យនៃវាក្យខណ្ឌខាងលើ ចំពោះទំនាក់ទំនងជាមួយប្រទេសទាំងឡាយនៃសហភាពដែលមិនបានផ្តល់ សច្ចាប័ន ឬមិនទាន់ចូលជាសមាជិកនៃច្បាប់នេះ។

(២) ជាកម្មវត្ថុនៃកថាខណ្ឌ(៣) ប្រទេសក្រៅសហភាពទាំងឡាយដែលក្លាយជាភាគីនៃច្បាប់នេះត្រូវ អនុវត្តច្បាប់នេះចំពោះប្រទេសណាមួយនៃសហភាពដែលមិនបានចងភ្ជាប់ដោយច្បាប់នេះ ឬបានចងភ្ជាប់ដោយ

ច្បាប់នេះក៏ដោយ តែបានធ្វើសេចក្តីប្រកាសតាមមាត្រា២៨(១)(ខ)។ ក្នុងទំនាក់ទំនងជាមួយប្រទេសក្រៅសហភាព ប្រទេសទាំងនេះទទួលស្គាល់ថាប្រទេសខាងលើនៃសហភាព៖

i. អាចអនុវត្តបទប្បញ្ញត្តិច្បាប់ថ្មីៗ ដែលច្បាប់នេះបានចងភ្ជាប់និង

ii. ជាកម្មវត្ថុនៃមាត្រា១(៦)នៃច្បាប់បន្ថែម មានសិទ្ធិយកលំនាំតាមកិច្ចការពារក្នុងកម្រិតដែលមានចែងក្នុងច្បាប់នេះ។

(៣) ប្រទេសណាមួយដែលបានប្រើប្រាស់លទ្ធភាពណាមួយដូចមានចែងក្នុងច្បាប់បន្ថែម អាចអនុវត្តបទប្បញ្ញត្តិនៃច្បាប់បន្ថែមដែលទាក់ទងនឹងលទ្ធភាពណាមួយ ដែលបានប្រើប្រាស់ក្នុងទំនាក់ទំនងជាមួយប្រទេសនៃសហភាពដទៃទៀតដែលមិនបានចងភ្ជាប់ដោយច្បាប់នេះ លុះត្រាតែប្រទេសនៃសហភាពដទៃទៀតនេះយល់ព្រមអនុវត្តបទប្បញ្ញត្តិដែលបានលើកឡើងខាងលើ។

## មាត្រា៣៣

### វិវាទ : ១- យុត្តាធិការនៃតុលាការយុត្តិធម៌អន្តរជាតិ២- ខក្សាសិទ្ធិចំពោះយុត្តាធិការនេះ ៣- ការដកខក្សាសិទ្ធិ

(១) ជម្លោះណាមួយរវាងប្រទេសនៃសហភាពពីរឬច្រើនទាក់ទងនឹងការបកស្រាយឬការអនុវត្តអនុសញ្ញានេះ គឺពុំអាចដោះស្រាយបញ្ចប់វិវាទដោយការចរចាបានទេដោយភាគីណាមួយនៃប្រទេសដែលពាក់ព័ន្ធ អាចត្រូវបាននាំយកទៅដោះស្រាយនៅតុលាការយុត្តិធម៌អន្តរជាតិដោយអនុវត្តស្របតាមលក្ខន្តិកៈរបស់តុលាការ លើកលែងតែប្រទេសដែលជាប់ពាក់ព័ន្ធនោះព្រមព្រៀងគ្នាចំពោះវិធីសាស្ត្រក្នុងការដោះស្រាយវិវាទផ្សេងទៀត។ ប្រទេសដែលធ្វើពាក្យបណ្តឹងទៅតុលាការត្រូវជូនព័ត៌មានទៅការិយាល័យអន្តរជាតិ ហើយការិយាល័យអន្តរជាតិត្រូវលើកបញ្ហានេះដើម្បីឱ្យប្រទេសផ្សេងទៀតនៃសហភាពចាប់អារម្មណ៍។

(២) នៅពេលចុះហត្ថលេខាលើច្បាប់នេះ ឬតម្កល់លិខិតុបករណ៍នៃការផ្តល់សច្ចាប័ន ឬការចូលជាសមាជិកប្រទេសនីមួយៗអាចប្រកាសថា ខ្លួនមិនចងភ្ជាប់ទៅនឹងបទប្បញ្ញត្តិនៃកថាខណ្ឌ(១) ខាងលើទេ។ ចំពោះជម្លោះណាមួយរវាងប្រទេសដែលបានប្រកាសនោះនិងប្រទេសនៃសហភាពដទៃទៀត បទប្បញ្ញត្តិនៃកថាខណ្ឌ(១) នឹងមិនយកមកអនុវត្តឡើយ។

(៣) ប្រទេសណាមួយដែលបានធ្វើសេចក្តីប្រកាសតាមបទប្បញ្ញត្តិនៃកថាខណ្ឌ(២) អាចដកសេចក្តីប្រកាសរបស់ខ្លួនវិញពេលណាមួយក៏បាន ដោយប្រកាសជូនដំណឹងទៅអគ្គនាយក។

## មាត្រា៣៤

### ការបញ្ចប់បទប្បញ្ញត្តិដែលមានពីមុនមួយចំនួន : ១- ច្បាប់ដែលមានពីមុន ២-ពិធីសារ នៃច្បាប់នៃទីក្រុងស្តុកខុល

(១) ជាកម្មវត្ថុនៃមាត្រា២៩ស្ទួន គ្មានប្រទេសណាមួយអាចផ្តល់សច្ចាប័ននិងចូលជាសមាជិកនៃច្បាប់ដែលមានពីមុននៃអនុសញ្ញានេះទេ បន្ទាប់ពីមាត្រា១ដល់មាត្រា២១ និងច្បាប់បន្ថែមឧបសម្ព័ន្ធបានចូលជាធរមាន។

(២) បន្ទាប់ពីមាត្រា១ដល់មាត្រា២១និងច្បាប់បន្ថែមឧបសម្ព័ន្ធបានចូលជាធរមាន គ្មានប្រទេសណាមួយអាចធ្វើសេចក្តីប្រកាសតាមមាត្រា៥នៃពិធីសារទាក់ទងនឹងប្រទេសកំពុងអភិវឌ្ឍដែលភ្ជាប់នឹងច្បាប់ ទីក្រុងស្តុកខុលបានឡើយ។

## មាត្រា៣៥

### រយៈពេលនៃអនុសញ្ញា ការប្រកាសដកខ្លួនចេញ : ១- រយៈពេលមិនកំណត់ ២- លទ្ធភាពនៃការប្រកាសដកខ្លួនចេញ ៣- កាលបរិច្ឆេទអានុភាពនៃការប្រកាសដកខ្លួនចេញ ៤- ការផ្អាកការប្រកាសដកខ្លួនចេញ

(១) អនុសញ្ញានេះមានអានុភាពរហូត ដោយមិនកំណត់ពេលវេលា។

(២) ប្រទេសណាមួយអាចប្រកាសដកខ្លួនចេញពីច្បាប់នេះដោយជូនដំណឹងទៅអគ្គនាយក។ ការប្រកាសដកខ្លួនចេញនេះ ក៏ត្រូវចាត់ទុកជាការដកខ្លួនចេញពីច្បាប់មុនៗទាំងអស់ ហើយប៉ះពាល់ចំពោះតែប្រទេស ដែលបានប្រកាសដកខ្លួនចេញតែប៉ុណ្ណោះ។ អនុសញ្ញានេះនៅតែអនុវត្ត និងមានអានុភាពចំពោះប្រទេសផ្សេង នៃសហភាព។

(៣) ការប្រកាសដកខ្លួនចេញត្រូវមានអានុភាពក្នុងរយៈពេល១(មួយ)ឆ្នាំ ក្រោយថ្ងៃដែលអគ្គនាយកបានទទួលសេចក្តីជូនដំណឹង។

(៤) សិទ្ធិប្រកាសដកខ្លួនចេញដែលបានចែងក្នុងមាត្រានេះ មិនអាចអនុវត្តដោយប្រទេសណាមួយមុនផុតសុពលភាពរយៈពេល៥(ប្រាំ)ឆ្នាំ ដោយរាប់ចាប់ពីកាលបរិច្ឆេទដែលប្រទេសនេះក្លាយជាសមាជិកនៃសហភាព។

## មាត្រា៣៦

### ការអនុវត្តអនុសញ្ញា : ១- កាតព្វកិច្ចអនុម័តវិធានការចាំបាច់ ២- កាលបរិច្ឆេទបង្កើតកាតព្វកិច្ច

(១) ប្រទេសណាមួយជាភាគីនៃអនុសញ្ញានេះ សន្យាថានឹងអនុម័តវិធានការចាំបាច់ដើម្បីធានាការអនុវត្តអនុសញ្ញានេះ ដោយអនុលោមតាមរដ្ឋធម្មនុញ្ញរបស់ប្រទេសខ្លួន។

(២) ត្រូវយល់ថា នៅពេលដែលប្រទេសមួយបានចងកាតព្វកិច្ចដោយអនុសញ្ញានេះ ច្បាប់ក្នុងស្រុកត្រូវមានអានុភាពអនុវត្តបទប្បញ្ញត្តិនៃអនុសញ្ញានេះ។

## មាត្រា៣៧

### អវសានប្បញ្ញត្តិ : ១- ភាសានៃច្បាប់ ២- ហត្ថលេខា ៣- ច្បាប់ចម្លងដែលបានបញ្ជាក់ ៤- ការចុះបញ្ជី ៥-ការជូនដំណឹង

(១)

(ក) ជាកម្មវត្ថុនៃកថាខណ្ឌ(២) ច្បាប់នេះត្រូវបានចុះហត្ថលេខាលើច្បាប់ចម្លងតែមួយគត់ ជាភាសាបារាំងនិងជាភាសាអង់គ្លេស និងត្រូវតម្កល់ជូនអគ្គនាយក។

(ខ) អត្ថបទផ្លូវការត្រូវធ្វើឡើងដោយអគ្គនាយក បន្ទាប់ពីប្រឹក្សាយោបល់ជាមួយនឹងរដ្ឋាភិបាលដែលពាក់ព័ន្ធ ជាភាសាអារ៉ាប់ អាល្លឺម៉ង់ អ៊ីតាលី ព័រទុយហ្កាល់ និងអេស្ប៉ាញ និងភាសាដទៃទៀត ដែលសន្និបាតអាចកំណត់។

(គ) ករណីមានយោបល់ខុសគ្នាលើការបកស្រាយអត្ថបទផ្សេងៗ អត្ថបទជាភាសាបារាំងត្រូវយកជាគោល។

(២) ច្បាប់នេះនៅតែបើកចំហសម្រាប់ការចុះហត្ថលេខា រហូតដល់ថ្ងៃទី៣១ ខែមករា ឆ្នាំ១៩៧២។ រហូតដល់កាលបរិច្ឆេទនេះ ច្បាប់ចម្លងតាមកថាខណ្ឌ(១)(ក) ត្រូវបានតម្កល់ជូនរដ្ឋាភិបាលនៃសាធារណរដ្ឋបារាំង។

(៣) អគ្គនាយកត្រូវបញ្ជាក់ថាត្រឹមត្រូវ និងបញ្ជូនច្បាប់ចម្លង២(ពីរ)ច្បាប់នៃអត្ថបទដែលបានចុះហត្ថលេខានៃច្បាប់នេះ ទៅរដ្ឋាភិបាលនៃប្រទេសទាំងអស់នៃសហភាព និងទៅរដ្ឋាភិបាលនៃប្រទេសណាមួយផ្សេងទៀតតាមការស្នើសុំ។

(៤) អគ្គនាយកត្រូវចុះបញ្ជីច្បាប់នេះនៅលេខាធិការដ្ឋាននៃអង្គការសហប្រជាជាតិ។

(៥) អគ្គនាយកត្រូវជូនដំណឹងដល់រដ្ឋាភិបាលនៃប្រទេសទាំងអស់នៃសហភាពអំពីការចុះហត្ថលេខា ការតម្កល់លិខិតុបករណ៍នៃការផ្តល់សច្ចាប័ន ឬការចូលជាសមាជិកនិងសេចក្តីប្រកាសណាមួយដែលមានភ្ជាប់ទៅក្នុងលិខិតុបករណ៍ទាំងនោះ ឬសេចក្តីប្រកាសដែលធ្វើឡើងតាមមាត្រា២៨(១) (គ) ៣០(២)(ក)និង(ខ) និងមាត្រា៣៣(២)ការចូលជាធរមាននៃបទប្បញ្ញត្តិណាមួយនៃច្បាប់នេះ សេចក្តីជូនដំណឹងនៃការប្រកាសដកខ្លួនចេញ និងសេចក្តីជូនដំណឹងតាមមាត្រា៣០(២)(គ) មាត្រា៣១ (១) និង(២) មាត្រា៣៣(៣) និងមាត្រា៣៨(១) ក៏ដូចជាច្បាប់បន្ថែម។

## មាត្រា ៣៨

## អន្តរប្បញ្ញត្តិ : ១- ការអនុវត្តនូវ "បុព្វសិទ្ធិប្រាំឆ្នាំ" ២- ការិយាល័យរបស់សហភាព ប្រធានការិយាល័យ ៣- ការទទួលតំណែងបន្តពីការិយាល័យរបស់សហភាព

(១) រហូតដល់ថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៧៥ ប្រទេសទាំងឡាយនៃសហភាព ដែលមិនបានផ្តល់សច្ចាប័នឬចូលជាសមាជិកនៃច្បាប់នេះ និងដែលមិនចងភ្ជាប់តាមមាត្រា២២ដល់មាត្រា២៦នៃច្បាប់ទីក្រុងស្តុកខុលនៃអនុសញ្ញានេះ បើចង់អាចអនុវត្តសិទ្ធិតាមមាត្រាខាងលើ បីដូចជាប្រទេសទាំងនេះចងភ្ជាប់តាមមាត្រាទាំងនោះដែរ។ ប្រទេសណាមួយដែលចង់អនុវត្តសិទ្ធិនេះ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅអគ្គនាយក។ ការជូនដំណឹងនេះ ត្រូវមានអានុភាពគិតចាប់ពីកាលបរិច្ឆេទនៃការទទួល។ ប្រទេសទាំងនេះត្រូវចាត់ទុកជាសមាជិកសន្និបាតរហូតដល់ពេលផុតកំណត់នៃរយៈពេលនេះ។

(២) នៅពេលដែលប្រទេសទាំងឡាយនៃសហភាព មិនទាន់ក្លាយជាសមាជិកនៃអង្គការ ការិយាល័យអន្តរជាតិនៃអង្គការ ត្រូវដើរតួជាការិយាល័យនៃសហភាព ហើយអគ្គនាយកជានាយកនៃការិយាល័យផងដែរ។

(៣) នៅពេលដែលប្រទេសទាំងឡាយនៃសហភាព បានក្លាយជាសមាជិកនៃអង្គការ សិទ្ធិកាតព្វកិច្ច និងទ្រព្យសម្បត្តិនៃការិយាល័យនៃសហភាព ត្រូវប្រគល់ឱ្យការិយាល័យអន្តរជាតិនៃអង្គការ។

# ឧបសម្ព័ន្ធ

# បទប្បញ្ញត្តិពិសេសទាក់ទងនឹងប្រទេសកំពុងអភិវឌ្ឍ

## មាត្រា១

## លទ្ធភាពដែលផ្តល់ឱ្យប្រទេសកំពុងអភិវឌ្ឍ : ១- អត្ថិភាពនៃលទ្ធភាពមួយចំនួន សេចក្តីប្រកាស ២-រយៈពេលសុពលភាពនៃសេចក្តីប្រកាស ៣- ការបាត់បង់ឋានៈជាប្រទេសកំពុងអភិវឌ្ឍ ៤- ច្បាប់ចម្លងដែលមានក្នុងស្តុក ៥- សេចក្តីប្រកាសទាក់ទងនឹងដែនដីមួយចំនួន ៦- ការកម្រិតបដិការ

(១) ដោយផ្តោតទៅលើស្ថានភាពនិងតម្រូវការនៃសេដ្ឋកិច្ច សង្គមកិច្ច ឬវប្បធម៌ ប្រទេសណាមួយដែលត្រូវបានចាត់ទុកជាប្រទេសកំពុងអភិវឌ្ឍ គឺបានត្រូវបង្កើតឡើងដោយអនុវត្តន៍ស្របតាមមហាសន្និបាតទូទៅនៃអង្គការសហប្រជាជាតិ ហើយប្រទេសនោះបានផ្តល់សច្ចាប័ន ឬចូលជាសមាជិកនៃច្បាប់នេះដែលបានបញ្ចូលនូវផ្នែកនៃច្បាប់បន្ថែមទាំងស្រុងផង ហើយចាត់ទុកថាខ្លួនពុំទាន់អាចបង្កើតបទប្បញ្ញត្តិបានភ្លាមៗសម្រាប់កិច្ចការពារសិទ្ធិទាំងឡាយដូចមានចែងនៅក្នុងច្បាប់នេះ គឺអាចធ្វើសេចក្តីជូនដំណឹងទៅអគ្គនាយកជាមួយគ្នានៅពេលដែលខ្លួនតម្កល់លិខិតុបករណ៍នៃការផ្តល់សច្ចាប័ន ឬការចូលជាសមាជិករបស់ខ្លួន ឬកម្មវត្ថុនៃមាត្រា៥(១)(គ) នៅពេលបន្ទាប់ណាមួយក៏បាន អាចប្រកាសថាខ្លួននឹងទទួលយកនូវសិទ្ធិអំណាចផ្តល់ក្នុងមាត្រា២ ឬមាត្រា៣ ឬក៏ទទួលយកសិទ្ធិអំណាចទាំងពីរនេះ។ ជំនួសឱ្យការប្រើប្រាស់នូវសិទ្ធិអំណាចតាមមាត្រា២ គឺអាចធ្វើសេចក្តីប្រកាសអនុលោមតាមមាត្រា ៥(១)(ក)បាន។

(២)

(ក) រាល់សេចក្តីជូនដំណឹងដូចមានចែងកថាខណ្ឌ(១) គឺត្រូវជូនដំណឹងមុនការផុតអាជ្ញាយុកាលរយៈពេល១០(ដប់)ឆ្នាំ គិតចាប់ពីថ្ងៃចូលជាធរមាននៃមាត្រា១ ដល់មាត្រា២១ និងច្បាប់បន្ថែម ដោយយោងតាមមាត្រា២៨(២) នឹងត្រូវមានអានុភាពអនុវត្តរហូតដល់ផុតរយៈពេលខាងលើ។ សេចក្តីប្រកាសនេះអាចធ្វើជាថ្មីទាំងស្រុង ឬមួយផ្នែកសម្រាប់រយៈពេល១០(ដប់)ឆ្នាំបន្តបន្ទាប់ តាមរយៈការជូនដំណឹងដែលតម្កល់ជូនអគ្គនាយកមិនលើសពីរយៈពេល១៥(ដប់ប្រាំ)ខែ និងមិនតិចជាង៣(បី)ខែ មុនផុតរយៈពេល១០(ដប់)ឆ្នាំ។

(ខ) រាល់សេចក្តីប្រកាសតាមកថាខណ្ឌ(១) ការជូនដំណឹងក្រោយពេលផុតសុពលភាពនៃរយៈពេល១០(ដប់)ឆ្នាំ គិតចាប់ពីការចូលជាធរមាននៃមាត្រា១ដល់មាត្រា២១និងច្បាប់បន្ថែមនេះ អនុលោមតាមមាត្រា២៨(២) នឹងត្រូវមានអានុភាពអនុវត្តរហូតដល់ផុតរយៈពេល១០(ដប់)ឆ្នាំទៀត។ រាល់សេចក្តីប្រកាសទាំងនោះ អាចធ្វើសាជាថ្មីតាមវាក្យខណ្ឌ២នៃអនុកថាខណ្ឌ(ក)។

(៣) ប្រទេសណាមួយនៃសហភាព ដែលលែងចាត់ទុកជាប្រទេសកំពុងអភិវឌ្ឍ ដូចដែលបានលើកឡើងក្នុងកថាខណ្ឌ(១) លែងមានសិទ្ធិចេញសេចក្តីប្រកាសសាជាថ្មីតាមកថាខណ្ឌ(២) ហើយ ទោះបីបានដកឬមិនបានដកសេចក្តីប្រកាសជាផ្លូវការក៏ដោយ ប្រទេសនេះត្រូវបានដកចេញពីការប្រើប្រាស់លទ្ធភាពនៃកថាខណ្ឌ(១) ដោយគិតចាប់ពីផុតរយៈពេល១០(ដប់)ឆ្នាំ ឬដោយគិតចាប់ពីផុតរយៈពេល៣ (បី)ឆ្នាំ បន្ទាប់ពីប្រទេសនេះលែងត្រូវបានចាត់ទុកជាប្រទេសកំពុងអភិវឌ្ឍ ដោយយកកាលបរិច្ឆេទ ដែលចប់ក្រោយគេ។

(៤) នៅពេលសេចក្ដីប្រកាសតាមកថាខណ្ឌ(១)ឬកថាខណ្ឌ(២)លែងមានអានុភាព ហើយច្បាប់ចម្លងនៃស្នាដៃដែលផលិតឡើងតាមអាជ្ញាបណ្ណមាននៅសេសសល់ក្នុងស្តុក ដែលផ្តល់ឱ្យតាមរយៈច្បាប់បន្ថែមនេះនឹងបន្តធ្វើការចែកចាយរហូតអស់ពីស្តុក។

(៥) ប្រទេសទាំងឡាយដែលចងភ្ជាប់ដោយបទប្បញ្ញត្តិនៃច្បាប់នេះ និងដែលបានតម្កល់សេចក្តីប្រកាស ឬការជូនដំណឹងតាមមាត្រា៣១(១) ចំពោះការអនុវត្តច្បាប់នេះក្នុងដែនដីជាក់លាក់ណាមួយ ដែលស្ថានភាពនៃដែនដីនេះអាចចាត់ទុកថាដូចនឹងស្ថានភាពនៃប្រទេសដែលមានចែងក្នុងកថាខណ្ឌ(១) អាចធ្វើសេចក្តីប្រកាសតាមកថាខណ្ឌ(១)ចំពោះដែនដីនេះ ហើយការជូនដំណឹងជាថ្មីតាមកថាខណ្ឌ(២)។ ដរាបណាសេចក្តីប្រកាសឬការជូនដំណឹងទាំងនេះនៅមានសុពលភាព បទប្បញ្ញត្តិនៃច្បាប់បន្ថែមនេះនឹងត្រូវយកមកអនុវត្តនៅលើដែនដីដែលបានធ្វើសេចក្តីប្រកាសឬការជូនដំណឹងនោះ។

(៦)

(ក) ការណ៍ដែលប្រទេសមួយប្រកាសទទួលយកសិទ្ធិអំណាចផ្តល់ជូនតាមកថាខណ្ឌ(១) ការណ៍នេះ គឺមិនអនុញ្ញាតឱ្យប្រទេសណាមួយផ្សេងទៀតដែលបានទទួលយកសិទ្ធិអំណាចនេះ ផ្តល់នូវកិច្ចការពារស្នាដៃតិចជាងប្រទេសដើមដែលជាប្រទេសដំបូងនៃស្នាដៃ ត្រូវអនុវត្តកាតព្វកិច្ចដូចមានចែងក្នុងមាត្រា១ដល់មាត្រា២០។

(ខ) សិទ្ធិក្នុងការអនុវត្តបដិការតាមមាត្រា៣០(២)(ខ)វាក្យខណ្ឌទី២ មិនត្រូវយកមកអនុវត្តទេចំពោះស្នាដៃនៃប្រទេសដើមដែលជាប្រទេសមួយបានធ្វើសេចក្ដីប្រកាសតាមមាត្រាV(១)(ក) រហូតដល់ពេលបញ្ចប់កាលបរិច្ឆេទនៃរយៈពេលដែលអនុវត្តតាមមាត្រា ១(៣)។

## មាត្រា២

### ការកម្រិតសិទ្ធិបកប្រែ : ១- អាជ្ញាប័ណ្ណដែលផ្តល់ឱ្យដោយអាជ្ញាធរមានសមត្ថកិច្ច ២-ដល់ ៤-លក្ខខណ្ឌក្នុងការផ្តល់អាជ្ញាបណ្ណ ៥- គោលបំណងក្នុងការផ្តល់អាជ្ញាប័ណ្ណ ៦- ការបញ្ចប់អាជ្ញាបណ្ណ ៧-ស្នាដៃដែលមានភាគច្រើនជារូបភាពពន្យល់ ៨-ស្នាដៃដែលដកចេញពីការធ្វើចរាចរណ៍ ៩-អាជ្ញាបណ្ណសម្រាប់អង្គភាពទូរផ្សាយ

(១) ប្រទេសណាមួយដែលបានប្រកាសថានឹងប្រើនូវសិទ្ធិអំណាចផ្តល់ជូនដោយមាត្រានេះ ចំពោះស្នាដៃទាំងឡាយណាដែលបានបោះពុម្ពផ្សាយក្នុងទម្រង់នៃការផលិតឡើងវិញជាការបោះពុម្ព ឬទម្រង់ដែលមានលក្ខណៈស្រដៀង មានសិទ្ធិជំនួសសិទ្ធិផ្តាច់មុខក្នុងការបកប្រែតាមមាត្រា៨ ដោយប្រព័ន្ធអាជ្ញាបណ្ណមិនផ្តាច់មុខនិងមិនអាចផ្ទេរបាន ដែលផ្តល់ឱ្យដោយអាជ្ញាធរមានសមត្ថកិច្ចតាមលក្ខខណ្ឌខាងក្រោម និងលើកលែងតែមាត្រា៤។

(២)

(ក) លើកលែងតែកថាខណ្ឌ(៣) បន្ទាប់ពីផុតរយៈពេល៣(បី)ឆ្នាំឬផុតរយៈពេលណាមួយដែលវែងជាងនេះ ហើយដែលបានកំណត់ដោយច្បាប់ជាតិនៃប្រទេសនោះ ដោយគិតចាប់ពីកាលបរិច្ឆេទបោះពុម្ពផ្សាយលើកដំបូងនៃស្នាដៃ ប្រសិនបើការបកប្រែស្នាដៃនេះមិនបានបោះពុម្ពផ្សាយជាភាសាមួយឲ្យប្រើប្រាស់ជាទូទៅក្នុងប្រទេសនោះ ដោយម្ចាស់សិទ្ធិនៃការបកប្រែ ឬដោយមានការអនុញ្ញាតពីម្ចាស់សិទ្ធិ ពលរដ្ឋណាម្នាក់នៃប្រទេសនោះ

អាចទទួលអាជ្ញាបណ្ណក្នុងការបកប្រែស្នាដៃនេះជាភាសាខាងលើ ហើយអាចបោះពុម្ពផ្សាយការបកប្រែក្នុងទម្រង់នៃការផលិតឡើងវិញជាការបោះពុម្ពឬទម្រង់ដែលដូចគ្នា។

(ខ) លក្ខខណ្ឌនៃអាជ្ញាបណ្ណដូចមានចែងក្នុងមាត្រានេះ ក៏អាចផ្តល់ផងដែរ ប្រសិនបើស្នាដៃបកប្រែទាំងអស់ដែលបានបោះពុម្ពផ្សាយក្នុងភាសាជាតិនោះត្រូវបានចែកចាយអស់។

(៣)

(ក) ក្នុងរយៈពេល៣(បី)ឆ្នាំដូចកថាខណ្ឌ(២)(ក) នឹងត្រូវជំនួសដោយរយៈពេល១(មួយ)ឆ្នាំវិញ ក្នុងករណីការបកប្រែជាភាសាណាមួយ ដែលមិនមែនជាភាសាដែលគេប្រើប្រាស់ជាទូទៅនៅក្នុងចំណោមប្រទេសអភិវឌ្ឍណាមួយ ឬច្រើនដែលជាសមាជិកនៃសហភាព។

(ខ) កិច្ចព្រមព្រៀងជាឯកច្ឆន្ទដែលធ្វើឡើង រវាងប្រទេសអភិវឌ្ឍទាំងឡាយ ជាសមាជិកនៃសហភាព ដែលប្រើប្រាស់ភាសាផ្លូវការដូចគ្នា ក្នុងករណីបកប្រែជាភាសានោះដូចមានចែងក្នុងកថាខណ្ឌ(១) រយៈពេល៣(បី)ឆ្នាំក្នុងកថាខណ្ឌ(២)(ក) អាចជំនួសដោយរយៈពេលខ្លីជាងដូចបានកំណត់ដោយកិច្ចព្រមព្រៀងនេះ តែមិនឱ្យតិចជាង១(មួយ)ឆ្នាំ។ ប៉ុន្តែបទប្បញ្ញត្តិខាងដើមនេះនឹងមិនយកមកអនុវត្តទេ ល្គឹកណាភាសានោះ គឺជាភាសាអង់គ្លេស បារាំង ឬអេស្ប៉ាញ។ គេត្រូវជូនដំណឹងពីកិច្ចព្រមព្រៀងដែលធ្វើឡើងរវាងរដ្ឋាភិបាលទាំងនេះទៅអគ្គនាយក។

(៤)

(ក) អាជ្ញាបណ្ណអនុលោមតាមមាត្រានេះ មិនអាចផ្តល់ឱ្យមុនពេលផុតរយៈពេលបន្ថែម៦(ប្រាំមួយ)ខែ ចំពោះអាជ្ញាបណ្ណដែលអាចទទួលបានពេលបញ្ចប់រយៈពេល៣(បី)ឆ្នាំ ហើយមិនអាចផ្តល់ឱ្យមុនផុតរយៈពេលបន្ថែម៩(ប្រាំបួន)ខែ ចំពោះអាជ្ញាបណ្ណដែលអាចទទួលបានពេលបញ្ចប់រយៈពេល១(មួយ)ឆ្នាំ។

i. គិតចាប់ពីកាលបរិច្ឆេទដែលអ្នកដាក់ពាក្យបានបំពេញតាមលក្ខខណ្ឌនៃមាត្រា៤(១) ឬ
ii. នៅពេលមិនស្គាល់អត្តសញ្ញាណឬអាសយដ្ឋានរបស់ម្ចាស់សិទ្ធិបកប្រែ គិតចាប់ពីកាលបរិច្ឆេទដែលអ្នកស្នើសុំបានធ្វើច្បាប់ចម្លងនៃសំណុំបែបបទរបស់ខ្លួន ទៅអាជ្ញាធរមានសមត្ថកិច្ច ដើម្បីឱ្យចេញអាជ្ញាបណ្ណ តាមមាត្រា៤(២)។

(ខ) ក្នុងអំឡុងពេល៦(ប្រាំមួយ)ឬ៩(ប្រាំបួន)ខែខាងលើ ប្រសិនបើការបកប្រែជាភាសាណាមួយ តាមការដាក់ពាក្យសុំត្រូវបានបោះពុម្ពផ្សាយដោយម្ចាស់សិទ្ធិនៃការបកប្រែ ឬដោយមានការអនុញ្ញាតពីម្ចាស់សិទ្ធិ មិនត្រូវផ្តល់អាជ្ញាបណ្ណតាមមាត្រានេះឡើយ។

(៥) អាជ្ញាបណ្ណណាមួយដែលមានចែងក្នុងច្បាប់នេះ ត្រូវបានផ្តល់តែចំពោះគោលបំណងបង្រៀនសិក្សា ឬស្រាវជ្រាវប៉ុណ្ណោះ។

(៦) ប្រសិនបើការបកប្រែស្នាដៃណាមួយ ត្រូវបានបោះពុម្ពផ្សាយដោយម្ចាស់សិទ្ធិបកប្រែ ឬដោយមានការអនុញ្ញាតពីម្ចាស់ក្នុងតម្លៃសមរម្យ បើប្រៀបធៀបជាមួយតម្លៃដែលយកជាធម្មតានៅក្នុងប្រទេសនោះចំពោះស្នាដៃដែលប្រហាក់ប្រហែលគ្នា អាជ្ញាប័ណ្ណណាដែលបានផ្តល់តាមមាត្រានេះត្រូវបញ្ចប់ប្រសិនបើមានការបក

ប្រែមានភាសាតែមួយហើយដែលមានមាតិកា ដូចគ្នាទៅនឹងការបកប្រែដែលបានបោះពុម្ពផ្សាយតាមអាជ្ញាបណ្ណ នោះ។ ច្បាប់ចម្លងទាំងឡាយណាដែលបានធ្វើឡើងមុនការបញ្ចប់នៃអាជ្ញាបណ្ណ អាចបន្តធ្វើការចែកចាយបានរហូតដល់អស់ពីស្តុក។

(៧) ចំពោះស្នាដៃទាំងឡាយណាដែលបង្កើតឡើង ដោយប្រើរូបភាពពន្យល់ជាចំបងអាជ្ញាប័ណ្ណដើម្បីបកប្រែនិងបោះពុម្ពផ្សាយនូវការបកប្រែអត្ថបទនិងអាជ្ញាប័ណ្ណដើម្បីផលិតឡើងវិញ និងដើម្បីបោះពុម្ពផ្សាយរូបភាពពន្យល់ អាចត្រូវបានផ្តល់ឲ្យតែការបំពេញលក្ខខណ្ឌទាំងឡាយនៃមាត្រា៣។

(៨) តាមមាត្រានេះ អាជ្ញាបណ្ណនឹងមិនត្រូវបានផ្តល់ជូនទេ ប្រសិនបើអ្នកនិពន្ធបានដកច្បាប់ចម្លងទាំងអស់ពីស្នាដៃរបស់គាត់ចេញពីការចរាចរណ៍។

(៩)

(ក) អាជ្ញាបណ្ណក្នុងការបកប្រែស្នាដៃណាមួយដែលបានបោះពុម្ពផ្សាយក្នុងទម្រង់នៃការផលិតឡើងវិញជាការបោះពុម្ព ឬដែលមានទម្រង់ដូចគ្នា អាចត្រូវបានផ្តល់ឲ្យផងដែរទៅអង្គភាពទូរផ្សាយណាដែលមានទីស្នាក់ការនៅក្នុងប្រទេសមួយដូចមានចែងក្នុងកថាខណ្ឌ(១) បន្ទាប់ពីអង្គភាពទូរផ្សាយបានដាក់ពាក្យសុំទៅអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសនោះ លុះត្រាតែបានបំពេញលក្ខខណ្ឌដូចខាងក្រោម៖

i. ការបកប្រែចេញពីច្បាប់ចម្លងដែលបានផលិតនិងបានទទួលស្របតាមច្បាប់នៃប្រទេសនោះ
ii. ការបកប្រែធ្វើឡើងសម្រាប់ការប្រើប្រាស់ដើម្បីចាក់ផ្សាយសម្រាប់តែការបង្រៀន ឬសម្រាប់ការផ្សព្វផ្សាយលទ្ធផលនៃការស្រាវជ្រាវបច្ចេកទេសឬវិទ្យាសាស្ត្រឯកទេស ឱ្យទៅអ្នកឯកទេសក្នុងវិជ្ជាជីវៈដោយឡែកណាមួយ
iii. ការបកប្រែត្រូវបានប្រើប្រាស់ជាក់លាក់ សម្រាប់គោលបំណងទាំងឡាយដូចមានចែងក្នុងលក្ខខណ្ឌ(ii) តាមរយៈការផ្សព្វផ្សាយស្របច្បាប់ និងធ្វើឡើងសម្រាប់អ្នកទទួលក្នុងដែនដីនៃប្រទេសនោះ ដោយរាប់បញ្ចូលទាំងការផ្សព្វផ្សាយដោយធ្វើឡើងតាមរយៈការថតបញ្ចូលជាសំឡេងឬថតជារូបភាពស្របច្បាប់ និងសម្រាប់តែគោលបំណងនៃការផ្សាយទាំងនេះ
iv. ការប្រើប្រាស់ការបកប្រែទាំងអស់ត្រូវធ្វើឡើងដោយគ្មានបំណងពាណិជ្ជកម្ម។

(ខ) ការថតទុកជាសំឡេង ឬជារូបភាពនៃការបកប្រែដែលធ្វើឡើងតាមរយៈអង្គភាពទូរផ្សាយណាដែលមានអាជ្ញាប័ណ្ណតាមកថាខណ្ឌនេះ ក្នុងគោលបំណងនិងតាមលក្ខខណ្ឌដូចមានចែងក្នុងកថាខណ្ឌ(ក) និងមានការយល់ស្របពីអង្គភាពទូរផ្សាយ ក៏អាចត្រូវបានប្រើប្រាស់ដោយអង្គភាពទូរផ្សាយផ្សេងទៀតដែលមានទីស្នាក់ការក្នុងប្រទេសនោះ ហើយដែលអាជ្ញាធរមានសមត្ថកិច្ចបានផ្តល់អាជ្ញាបណ្ណរួចហើយ។

(គ) ប្រសិនបើបានបំពេញគ្រប់លក្ខណៈវិនិច្ឆ័យនិងលក្ខខណ្ឌ តាមអនុកថាខណ្ឌ(ក) ក៏អាចផ្តល់អាជ្ញាប័ណ្ណផងដែរចំពោះអង្គភាពទូរផ្សាយដើម្បីបកប្រែអត្ថបទ ដែលបានដាក់បញ្ចូលជាទម្រង់ស្នាដៃសោតទស្សន៍នៅពេលដែលការបញ្ចូលនេះត្រូវបានរៀបចំនិងបោះពុម្ពផ្សាយសម្រាប់តែគោលបំណងប្រើប្រាស់ទាក់ទងនឹងសកម្មភាពអប់រំជាប្រព័ន្ធតែប៉ុណ្ណោះ។

(ឃ) លើកលែងតែអនុកថាខណ្ឌ(ក)ដល់(គ) បទប្បញ្ញត្តិនៃកថាខណ្ឌខាងលើត្រូវអនុវត្តចំពោះការផ្តល់ និងការអនុវត្តអាជ្ញាបណ្ណណាដែលបានផ្តល់ក្នុងកថាខណ្ឌនេះ។

## មាត្រា៣

## ការកម្រិតសិទ្ធិផលិតឡើងវិញ : ១- អាជ្ញាប័ណ្ណដែលអាចផ្តល់ឲ្យដោយអាជ្ញាធរមានសមត្ថកិច្ច ២-ដល់៥- លក្ខខណ្ឌក្នុងការផ្តល់អាជ្ញាបណ្ណ ៦- ការបញ្ចប់អាជ្ញាបណ្ណ ៧- ស្នាដៃដែលអនុវត្តក្នុងមាត្រានេះ

(១) ប្រទេសណាមួយដែលបានប្រកាសថា ខ្លួននឹងទទួលយកនូវសិទ្ធិអំណាចតាមមាត្រានេះនឹងអាចផ្តល់សិទ្ធិជំនួសចំពោះសិទ្ធិផ្តាច់មុខក្នុងការផលិតឡើងវិញដូចមានចែងក្នុងមាត្រា៩ ដោយប្រព័ន្ធនៃអាជ្ញាបណ្ណមិនផ្តាច់មុខនិងមិនអាចផ្ទេរបានដែលផ្តល់ឱ្យដោយអាជ្ញាធរមានសមត្ថកិច្ច តាមលក្ខខណ្ឌដូចខាងក្រោមនិងជាកម្មវត្ថុនៃមាត្រា៤។

(២)

(ក) ការអនុវត្តតាមកថាខណ្ឌ(៧)នៃមាត្រានេះ ប្រសិនបើទាក់ទងនឹងស្នាដៃបន្ទាប់ពីការផុតរលត់នៃៈ

i. រយៈពេលដែលបានកំណត់ក្នុងកថាខណ្ឌ(៣) គិតចាប់ពីកាលបរិច្ឆេទនៃការបោះពុម្ពផ្សាយលើកដំបូង នៃចំនួនបោះពុម្ពផ្សាយជាក់លាក់នៃស្នាដៃ ឬ
ii. រយៈពេលវែងជាងនេះដែលកំណត់ដោយច្បាប់ជាតិនៃប្រទេសណាមួយដូចកថាខណ្ឌ(១) គិតដូចគ្នាចំពោះកាលបរិច្ឆេទនៃច្បាប់ចម្លងស្នាដៃដែលបានកែប្រែថ្មី ហើយមិនទាន់បានចែកចាយក្នុងប្រទេសនោះទៅកាន់សាធារណជន ឬសកម្មភាពទាំងឡាយទាក់ទងនឹងប្រព័ន្ធអប់រំ ដោយម្ចាស់សិទ្ធិផលិតឡើងវិញ ឬការអនុញ្ញាតពីម្ចាស់សិទ្ធិក្នុងតម្លៃសមរម្យ បើប្រៀបធៀបជាមួយតម្លៃធម្មតានៃស្នាដៃស្រដៀងគ្នានៅក្នុងប្រទេសនោះ ពលរដ្ឋណាម្នាក់នៃប្រទេសនេះអាចទទួលបានអាជ្ញាបណ្ណផលិតឡើងវិញនិងផ្សព្វផ្សាយស្នាដៃបោះពុម្ពនេះនៅក្នុងតម្លៃខាងលើ ឬតម្លៃមួយទាបជាងនេះសម្រាប់សកម្មភាពប្រើប្រាស់ទាក់ទងនឹងប្រព័ន្ធអប់រំ ។

(ខ) អាជ្ញាបណ្ណផលិតឡើងវិញនិងផ្សព្វផ្សាយស្នាដៃបោះពុម្ពដែលត្រូវបានចែកចាយ ដូចបានរៀបរាប់ក្នុងអនុកថាខណ្ឌ(ក) អាចផ្តល់ជូនស្របតាមលក្ខខណ្ឌនៃមាត្រានេះ ប្រសិនបើផុតកំណត់ការអនុញ្ញាតនឹងត្រូវអនុវត្តបានក្នុងរយៈពេល៦(ប្រាំមួយ)ខែទៀត បន្ទាប់ពីនោះ គឺពុំអនុញ្ញាតឱ្យជាក់លក់ច្បាប់ចម្លងស្នាដៃបោះពុម្ពបានឡើយ ឬសកម្មភាពប្រើប្រាស់ទាក់ទងនឹងប្រព័ន្ធអប់រំក្នុងតម្លៃសមរម្យ បើប្រៀបធៀបជាមួយតម្លៃធម្មតានៃស្នាដៃប្រហែលគ្នានៅក្នុងប្រទេសដែលបានអនុញ្ញាតនោះឡើយ ។

(៣) រយៈពេលដែលបានលើកឡើងនៅក្នុងកថាខណ្ឌ(២)(ក)(i)មានកំណត់៥(ប្រាំ)ឆ្នាំ លើកលែងតែៈ

i. ចំពោះស្នាដៃនៃវិទ្យាសាស្ត្រធម្មជាតិ និងរូបវិទ្យា ដោយរួមបញ្ចូលគណិតវិទ្យា និងស្នាដៃបច្ចេកវិទ្យារយៈពេលដែលត្រូវកំណត់ គឺ៣(បី)ឆ្នាំ

ii. ចំពោះស្នាដៃនៃរឿងប្រឌិត កំណាព្យ រឿងល្ខោន តូរ្យតន្ត្រី និងសៀវភៅ សិល្បៈ រយៈពេលត្រូវកំណត់ គឺ៧(ប្រាំពីរ)ឆ្នាំ។

(៤)

(ក) មិនមានអាជ្ញាបណ្ណណាមួយដែលទទួលបានទេក្នុងរយៈពេល៣(បី)ឆ្នាំ អាចនឹងផ្តល់ឱ្យបានក្នុងមាត្រានេះរហូតផុតរយៈពេល៦(ប្រាំមួយ)ខែក្រោយទៀយត្រូវបានផុតរលត់

i. គិតចាប់ពីកាលបរិច្ឆេទដែលអ្នកដាក់ពាក្យសុំបានបំពេញនូវលក្ខខណ្ឌដែលបានលើកឡើងតាមមាត្រា៤(១) ឬ

ii. នៅពេលមិនស្គាល់អត្តសញ្ញាណឬអាសយដ្ឋានរបស់ម្ចាស់សិទ្ធិនៃការផលិតឡើងវិញស្របតាមមាត្រា៤(២) ចាប់ពីកាលបរិច្ឆេទដែលអ្នកស្នើសុំបានផ្ញើច្បាប់ចម្លងនៃពាក្យសុំរបស់ខ្លួនទៅកាន់អាជ្ញាធរមានសមត្ថកិច្ចដើម្បីផ្តល់អាជ្ញាបណ្ណ។

(ខ) ក្នុងករណីដែលអាចទទួលបានអាជ្ញាបណ្ណ បន្ទាប់មករយៈពេលផ្សេងទៀតនិងមាត្រា៤(២) ត្រូវបានអនុវត្ត មិនមានអាជ្ញាបណ្ណណាមួយអាចផ្តល់បានឡើយរហូតដល់ផុតរយៈពេល៣(បី)ខែ គិតចាប់កាលបរិច្ឆេទនៃការបញ្ជូននៃពាក្យស្នើសុំ។

(គ) ក្នុងអំឡុងពេល៦(ប្រាំមួយ) ឬ៣(បី)ខែតាមអនុកថាខណ្ឌ(ក)និង(ខ) ប្រសិនបើមានការចែកចាយកើតឡើងដូចមានរៀបរាប់ក្នុងកថាខណ្ឌ(២)(ខ) អាជ្ញាបណ្ណមិនអាចផ្តល់បានឡើយតាមមាត្រានេះ។

(ឃ) មិនត្រូវផ្តល់អាជ្ញាបណ្ណទេ ប្រសិនបើអ្នកនិពន្ធ បានដកការដាក់ឱ្យចរាចរនូវច្បាប់ចម្លងផលិតឡើងវិញទាំងអស់នៃស្នាដៃបោះពុម្ព និងពេលដែលត្រូវបានដាក់ពាក្យស្នើសុំអាជ្ញាបណ្ណបោះពុម្ពផ្សាយ។

(៥) មិនត្រូវមានអាជ្ញាបណ្ណផលិតឡើងវិញនិងការបោះពុម្ពផ្សាយការបកប្រែស្នាដៃមួយតាមមាត្រានេះក្នុងករណីដូចខាងក្រោមៈ

i. ប្រសិនបើស្នាដៃបកប្រែមិនត្រូវបានបោះពុម្ពផ្សាយដោយម្ចាស់សិទ្ធិបកប្រែ ឬដោយគ្មានការអនុញ្ញាតពីម្ចាស់សិទ្ធិ ឬ

ii. ប្រសិនបើស្នាដៃបកប្រែមិនមែនជាភាសាដែលប្រើប្រាស់ជាទូទៅក្នុងប្រទេសដែលត្រូវបានដាក់ពាក្យសុំអាជ្ញាបណ្ណ។

(៦) ប្រសិនបើច្បាប់ចម្លងនៃស្នាដៃបោះពុម្ពមួយត្រូវបានចែកចាយក្នុងប្រទេសដូចចែងក្នុងកថាខណ្ឌ(១) ជូនដល់សាធារណជនទូទៅ ឬសកម្មភាពប្រើប្រាស់ទាក់ទងនឹងប្រព័ន្ធអប់រំដោយម្ចាស់សិទ្ធិផលិតឡើងវិញ ឬដោយមានការអនុញ្ញាតពីម្ចាស់សិទ្ធិក្នុងតម្លៃសមរម្យ បើប្រៀបធៀបជាមួយនឹងតម្លៃធម្មតានៃស្នាដៃប្រហាក់ប្រហែលគ្នានៅក្នុងប្រទេសនោះ អាជ្ញាបណ្ណណាដែលបានផ្តល់តាមមាត្រានេះត្រូវបញ្ចប់ ប្រសិនបើការបោះពុម្ពនេះមានភាសាតែមួយ ហើយដែលមានមាតិកាដូចគ្នាភាគច្រើនទៅនឹងស្នាដៃបោះពុម្ពដែលបានមានអាជ្ញាបណ្ណ។ ច្បាប់ចម្លងទាំងឡាយណាដែលបានផលិតឡើងមុនពេលអាជ្ញាបណ្ណបញ្ចប់ គឺអាចបន្តធ្វើការចែកចាយបានរហូតដល់អស់ស្តុក។

(៧)

(ក) ស្នាដៃដែលជាកម្មវត្ថុអនុកថាខណ្ឌ(ខ)នៃមាត្រានេះ នឹងត្រូវបានកម្រិតចំពោះស្នាដៃទាំងឡាយណាដែលបានបោះពុម្ពផ្សាយក្នុងលក្ខណៈបោះពុម្ពឬផលិតឡើងវិញក្នុងទម្រង់អាណាឡូក។

(ខ) មាត្រានេះត្រូវយកមកអនុវត្តផងដែរចំពោះការផលិតឡើងវិញជាទម្រង់សោតទស្សន៍ ចំពោះការថតបញ្ចូលសោតទស្សន៍ដែលធ្វើឡើងដោយស្របច្បាប់ រាប់បញ្ចូលទាំងស្នាដៃដែលបានការពារណាមួយដែលបានភ្ជាប់ក្នុងការថតបញ្ចូលនោះ និងការបញ្ចូលអត្ថបទបកប្រែជាភាសាដែលប្រើប្រាស់ទូទៅក្នុងប្រទេសដែលបានដាក់ពាក្យស្នើសុំអាជ្ញាបណ្ណ លុះត្រាតែការថតបញ្ចូលសោតទស្សន៍នេះត្រូវបានរៀបចំនិងបោះពុម្ពផ្សាយក្នុងគោលបំណងតែមួយគត់ ដើម្បីសកម្មភាពប្រើប្រាស់ទាក់ទងនឹងប្រព័ន្ធអប់រំ។

## មាត្រា៤

## [បទប្បញ្ញត្តិរួមស្តីពីអាជ្ញាបណ្ណតាមមាត្រា២ និងមាត្រា៣ : ១និង២- នីតិវិធី ៣- ការបញ្ជាក់ឈ្មោះអ្នកនិពន្ធ និងចំណងជើងនៃស្នាដៃ ៤- ការនាំចេញនៃច្បាប់ចម្លង ៥- ការជូនដំណឹង ៦- ប្រាក់សំណង]

(១) អាជ្ញាបណ្ណតាមមាត្រា២ ឬមាត្រា៣ អាចត្រូវបានផ្តល់ឱ្យលុះត្រាតែអ្នកស្នើសុំ អនុលោមតាមនីតិវិធីនៃប្រទេសនោះ ដើម្បីសុំការអនុញ្ញាត បកប្រែ និងបោះពុម្ពផ្សាយ ឬដើម្បីផលិតឡើងវិញនិងផ្សព្វផ្សាយការបោះពុម្ពតាមករណីនីមួយៗ ប៉ុន្តែត្រូវបានបដិសេធឬបង្ហាញថា បន្ទាប់ពីការខិតខំយកចិត្តទុកដាក់យ៉ាងណាក៏ដោយ ក៏អ្នកស្នើសុំពុំអាចរកឃើញម្ចាស់សិទ្ធិដែរ។ ស្របពេលជាមួយនឹង ការស្នើសុំនេះ អ្នកស្នើសុំត្រូវជូនដំណឹងដល់មជ្ឈមណ្ឌលព័ត៌មានជាតិឬអន្តរជាតិណាមួយតាមកថាខណ្ឌ(២)។

(២) ប្រសិនបើម្ចាស់សិទ្ធិមិនអាចទាក់ទងបាន អ្នកស្នើសុំអាជ្ញាបណ្ណ ត្រូវផ្ញើច្បាប់ចម្លងរបស់ខ្លួន តាមប្រៃសណីយ៍ទៅនឹងអាជ្ញាធរមានសមត្ថកិច្ចចេញអាជ្ញាប័ណ្ណទៅឱ្យអ្នកបោះពុម្ពផ្សាយដែលមានឈ្មោះនៅលើស្នាដៃ និងទៅឱ្យមជ្ឈមណ្ឌលព័ត៌មានជាតិ ឬអន្តរជាតិណាមួយដែលអាចត្រូវបានចាត់តាំងដោយរាជរដ្ឋាភិបាលនៃប្រទេសអ្នកបោះពុម្ពផ្សាយដែលត្រូវបានជឿថាមានទីស្នាក់ការកណ្តាលនៅក្នុងប្រទេសនោះ ដោយជូនដំណឹងទៅអគ្គនាយក។

(៣) ឈ្មោះរបស់អ្នកនិពន្ធត្រូវបញ្ជាក់នៅលើច្បាប់ចម្លងទាំងអស់នៃការបកប្រែ ឬការផលិតឡើងវិញដែលបានបោះពុម្ពផ្សាយតាមអាជ្ញាបណ្ណនៃមាត្រា២ ឬមាត្រា៣។ ចំណងជើងនៃស្នាដៃ ត្រូវដាក់នៅលើច្បាប់ចម្លងទាំងអស់។ ក្នុងករណីការបកប្រែចំណងជើងដើមនៃស្នាដៃត្រូវបានដាក់គ្រប់ករណីនៅលើច្បាប់ចម្លងទាំងអស់ខាងលើ។

(៤)

(ក) តាមមាត្រា២ឬមាត្រា៣នេះ អាជ្ញាបណ្ណនឹងមិនត្រូវបានផ្តល់ជូនទេចំពោះវិសាលភាពនៃការនាំចេញច្បាប់ចម្លង ហើយអាជ្ញាបណ្ណនេះត្រូវមានសុពលភាពត្រឹមតែការបោះពុម្ពផ្សាយការបកប្រែ ឬការបោះពុម្ពផ្សាយការផលិតឡើងវិញតាមករណីនីមួយៗ ក្នុងដែនដីនៃប្រទេសដែលអាជ្ញាបណ្ណ ត្រូវបានដាក់ពាក្យសុំ។

(ខ) ជាគោលបំណងនៃអនុកថាខណ្ឌ(ក) សញ្ញាណនៃការនាំចេញ ត្រូវរួមបញ្ចូលទាំងការផ្ញើច្បាប់ចម្លងពីដែនដីមួយទៅឲ្យប្រទេស ដែលធ្វើសេចក្តីប្រកាសតាមមាត្រា១(៥) ចំពោះដែនដីនោះ។

(គ) នៅពេលដែលអង្គភាពរដ្ឋាភិបាលឬអង្គភាពសាធារណៈផ្សេងៗទៀតនៃប្រទេសមួយ ដែលបានផ្តល់អាជ្ញាបណ្ណដើម្បីបកប្រែតាមមាត្រា២ ជាភាសាណាមួយក្រៅពីភាសាអង់គ្លេស បារាំង ឬ អេស្ប៉ាញ ត្រូវធ្វើច្បាប់ចម្លងនៃការបកប្រែដែលបានបោះពុម្ពផ្សាយតាមអាជ្ញាបណ្ណនេះទៅឲ្យប្រទេសដទៃទៀត។ ជាគោលបំណងអនុកថាខណ្ឌ(ក) ការធ្វើច្បាប់ចម្លងទាំងនេះមិនត្រូវចាត់ទុកជាការនាំចេញទេប្រសិនបើបានបំពេញលក្ខខណ្ឌទាំងអស់ខាងក្រោម៖

i. អ្នកទទួល ជាបុគ្គលដែលជាពលរដ្ឋនៃប្រទេសដែលអាជ្ញាធរមានសមត្ថកិច្ច បានចេញអាជ្ញាបណ្ណ ឬជាអង្គការដែលជាបណ្តុំនៃបុគ្គលទាំងនេះ
ii. ច្បាប់ចម្លងត្រូវបានប្រើប្រាស់ក្នុងគោលដៅត្រឹមតែជាការបង្រៀន ការសិក្សា ឬស្រាវជ្រាវ
iii. ការធ្វើច្បាប់ចម្លង និងការចែកចាយជាបន្តទៅឲ្យអ្នកទទួល គ្មានគោលបំណងធ្វើពាណិជ្ជកម្ម ហើយ
iv. ប្រទេសដែលទទួលបានច្បាប់ចម្លង បានព្រមព្រៀងជាមួយប្រទេសដែលអាជ្ញាធរមានសមត្ថកិច្ចបានចេញអាជ្ញាបណ្ណដើម្បីអនុញ្ញាតឱ្យមានការទទួលឬការចែកចាយ ឬទាំងការទទួលនិងការចែកចាយ ហើយរដ្ឋាភិបាលនៃប្រទេសដែលផ្តល់អាជ្ញាបណ្ណ ត្រូវជូនដំណឹងទៅអគ្គនាយក អំពីកិច្ចព្រមព្រៀងនេះ។

(៥) ច្បាប់ចម្លងទាំងអស់ ដែលបានបោះពុម្ពផ្សាយតាមអាជ្ញាបណ្ណនៃមាត្រា២ឬមាត្រា៣ ត្រូវភ្ជាប់មកជាមួយនូវការជូនដំណឹងជាភាសាសមស្របណាមួយ ដោយបញ្ជាក់ថាច្បាប់ចម្លងអាចធ្វើការចែកចាយបានតែក្នុងប្រទេស ឬដែនដីដែលអនុវត្តអាជ្ញាបណ្ណខាងលើប៉ុណ្ណោះ។

(៦)

(ក) ត្រូវបង្កើតឱ្យមានបទប្បញ្ញត្តិសមរម្យក្នុងថ្នាក់ជាតិ ដើម្បីធានា៖

i. ថាអាជ្ញាបណ្ណជាប្រយោជន៍នៃម្ចាស់សិទ្ធិអ្នកបកប្រែឬសិទ្ធិផលិតឡើងវិញតាមករណីនីមួយៗ ចែងឱ្យមានសំណងសមរម្យដែលស្របតាមស្តង់ដាលាភការ ដែលធម្មតាទទួលបានពីអាជ្ញាបណ្ណ ដែលបានចរចាដោយសេរីរវាងបុគ្គលនានាក្នុងប្រទេសដែលពាក់ព័ន្ធទាំងពីរហើយ
ii. ការបង់កម្រៃនិងការផ្ទេរសំណង : បើមានបទប្បញ្ញត្តិជាតិស្តីពីរូបិយវត្ថុ អាជ្ញាធរមានសមត្ថកិច្ចត្រូវខិតខំឱ្យអស់លទ្ធភាព ដើម្បីប្រើប្រាស់យន្តការអន្តរជាតិ ដើម្បីធានាឱ្យមានការផ្ទេរជារូបិយវត្ថុដែលអាចប្តូរបានជាអន្តរជាតិ ឬរូបិយវត្ថុប្រហាក់ប្រហែលគ្នា។

(ខ) ត្រូវបង្កើតឱ្យមានបទប្បញ្ញត្តិសមរម្យក្នុងថ្នាក់ជាតិ ដើម្បីធានាឱ្យមានការបកប្រែឱ្យបានត្រឹមត្រូវនៃស្នាដៃ ឬធានាឱ្យមានការផលិតឡើងវិញឱ្យបានត្រឹមត្រូវ តាមការបោះពុម្ពជាក់លាក់តាម ករណីនីមួយៗ។

## មាត្រា៥

### លទ្ធភាពដទៃទៀតក្នុងការកម្រិតសិទ្ធិបកប្រែ : ១- របបគតិយុត្តិចែងដោយច្បាប់ឆ្នាំ១៨៨៦ និងច្បាប់ឆ្នាំ១៨៩៦ ២- ភាពមិនអាចផ្លាស់ប្តូរបាននៃរបបគតិយុត្តិតាមមាត្រា២ ៣- រយៈពេលក្នុងការជ្រើសរើសលទ្ធភាពដទៃទៀត

(១)

(ក) ការប្រកាសថាខ្លួននឹងប្រើប្រាស់នូវសិទ្ធអំណាចដែលបានផ្តល់ក្នុងមាត្រា២ របស់ប្រទេសណាមួយដែលមានសិទ្ធិ គឺធ្វើឡើងនៅពេលផ្តល់សច្ចាប័នឬចូលជាសមាជិកនៃច្បាប់នេះ៖

(i) ប្រសិនបើមាត្រា៣០(២)(ក)ត្រូវបានអនុវត្តក្នុងប្រទេសណាមួយដែលធ្វើសេចក្តីប្រកាសចំពោះសិទ្ធិបកប្រែស្របតាមបទប្បញ្ញត្តិនោះ

(ii) ប្រសិនបើមាត្រា៣០(២)(ក)មិនត្រូវបានអនុវត្តក្នុងប្រទេសណាមួយ ហើយបើទោះបីជាប្រទេសនោះពុំមែនជាប្រទេសក្រៅសហភាពក៏ដោយ គឺអាចធ្វើសេចក្តីប្រកាសបានអនុលោមតាមមាត្រា៣០(២)(ខ)វាក្យខណ្ឌទី១។

(ខ) ក្នុងករណីប្រទេសមួយលែងចាត់ទុកជាប្រទេសកំពុងអភិវឌ្ឍតាមមាត្រា១(១) សេចក្តីប្រកាសមួយបានបង្កើតស្របតាមកថាខណ្ឌនេះ ត្រូវមានសុពលភាពរហូតដល់ការបរិច្ឆេទផុតកំណត់នៃរយៈពេលដែលត្រូវអនុវត្តដូចមានចែងក្នុងមាត្រា១(៣)។

(គ) ប្រទេសណាមួយដែលធ្វើសេចក្តីប្រកាសតាមកថាខណ្ឌនេះ មិនអាចបន្តប្រើប្រាស់នូវសិទ្ធិអំណាចផ្តល់ដោយមាត្រា២ ទេ ទោះបីជាប្រទេសនេះបានដកសេចក្តីប្រកាសវិញក៏ដោយ។

(២) កម្មវត្ថុនៃកថាខណ្ឌ(៣) ប្រទេសណាមួយដែលបានប្រើប្រាស់សិទ្ធិអំណាចដែលផ្តល់ជូនក្នុងមាត្រា២ មិនអាចបន្តធ្វើសេចក្តីប្រកាសណាមួយតាមកថាខណ្ឌ(១)បានទេ។

(៣) ប្រទេសណាមួយដែលលែងចាត់ទុកជាប្រទេសកំពុងអភិវឌ្ឍតាមមាត្រា១(១) អាចធ្វើសេចក្តីប្រកាសតាមមាត្រា៣០(២)(ខ)វាក្យខណ្ឌទី១ក្នុងរយៈពេលមិនលើសពី២ឆ្នាំមុនផុតកំណត់រយៈពេលត្រូវអនុវត្តដូចមានចែងក្នុងមាត្រា១(៣) ទោះបីជាមិនមែនជាប្រទេសក្រៅសហភាពក៏ដោយ។ សេចក្តីប្រកាសនេះនឹងត្រូវមានអនុភាពអនុវត្តចាប់ពីកាលបរិច្ឆេទរយៈពេលអនុវត្តមានចែងក្នុងមាត្រា១(៣)។

## មាត្រា៦

### លទ្ធភាពអនុវត្ត ឬយល់ព្រមអនុវត្តបទប្បញ្ញត្តិមួយចំនួននៃច្បាប់បន្ថែម មុននឹងជាប់កាតព្វកិច្ចដោយច្បាប់នេះ : ១- សេចក្តីប្រកាស ២- កន្លែងតម្កល់ និងកាលបរិច្ឆេទអានុភាពនៃសេចក្តីប្រកាស

(១) តាមកាលបរិច្ឆេទនៃច្បាប់នេះ ហើយនៅពេលណាមួយក៏បានមុនការចងភ្ជាប់ដោយមាត្រា១ដល់មាត្រា២១ និងច្បាប់បន្ថែមនេះ ប្រទេសណាមួយនៃសហភាពអាចប្រកាសថា៖

(i) ប្រសិនបើប្រទេសមួយបានចងភ្ជាប់ដោយមាត្រា១ដល់មាត្រា២១និងច្បាប់បន្ថែមនេះ នឹងមានសិទ្ធិប្រើប្រាស់អំណាចយោងតាមមាត្រា១(១) អាចប្រកាសថាខ្លួននឹងអនុវត្ត បទប្បញ្ញត្តិនៃមាត្រា២ ឬ មាត្រា៣ ឬនៃមាត្រាទាំងពីរចំពោះស្នាដៃរបស់ប្រទេសដើម ដែលជាប្រទេសទទួលស្គាល់ការអនុវត្តមាត្រាទាំងនេះចំពោះស្នាដៃទាំងនោះអនុលោម តាមកថាខណ្ឌ(ii) ខាងក្រោម ឬប្រទេសដែលចងភ្ជាប់ដោយមាត្រា១ដល់មាត្រា២១ និងច្បាប់បន្ថែមនេះ។ សេចក្ដីប្រកាសបែបនេះអាចយកមាត្រា៥ មកអនុវត្តជំនួស មាត្រា២ បាន

(ii) ប្រទេសទាំងឡាយដែលប្រកាសថាខ្លួនទទួលយកអនុវត្តច្បាប់បន្ថែមនេះ ចំពោះស្នាដៃ នៃប្រទេសដើម ដែលខ្លួនបានធ្វើសេចក្ដីប្រកាសតាមចំណុច(i)ខាងលើ ឬតាមរយៈ ការជូនដំណឹងក្នុងមាត្រា១។

(២) សេចក្ដីប្រកាសណាមួយដែលបានធ្វើតាមកថាខណ្ឌ(១) ត្រូវធ្វើជាលាយលក្ខណ៍អក្សរនិងតម្កល់ជូនអគ្គនាយក។ សេចក្ដីប្រកាសនេះនឹងមានអានុភាពចាប់ពីកាលបរិច្ឆេទនៃការតម្កល់។